## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរទន្លេសាប**

# ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប
# ២០១៦-២០២០

**រៀបចំដោយ ៖ អាជ្ញាធរទន្លេសាប**
**សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប**
**ខែធ្នូ ឆ្នាំ ២០១៥**

# អារម្ភកថា

បឹងទន្លេសាប គឺជាបឹងទឹកសាបធម្មជាតិ ដែលធំជាងគេបំផុតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងជាបេះដូងនៃប្រទេសកម្ពុជា ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន ។ ទន្លេសាប និងបឹងទន្លេសាប គឺជាប្រព័ន្ធផ្លូវទឹកដែលមានទំនាក់ទំនងគ្នាយ៉ាងសំខាន់បំផុត ដែលទទួលរងនូវឥទ្ធិពលរបបទឹកពីទន្លេមេគង្គ ។ ផលិតភាពធនធានជលផលប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធចលនាចរន្តទឹកជំនន់ (Flood pulse system) នៅតំបន់ទន្លេសាប បានជំរុញឲ្យមានការអភិវឌ្ឍដល់វិស័យសេដ្ឋកិច្ចសង្គមយ៉ាងខ្លាំង ពិសេសចាប់ពីសតវត្សទី ៩ មក ។ បឹងទន្លេសាប ដែលស្រូបយកទឹកពីទន្លេមេគង្គនៅរដូវវស្សា និងបញ្ចេញទឹកទៅទន្លេមេគង្គវិញនៅរដូវប្រាំង បង្កើតបានជាបាតុភូតជលសាស្ត្រធម្មជាតិមួយដ៏កម្រមាននៅលើពិភពលោក និងបាននាំមកនូវដីល្បាប់ដ៏មានជីជាតិទៅចាក់បំពេញវាលទំនាប និងតំបន់ព្រៃលិចទឹកដ៏ធំល្វឹងល្វើយជុំវិញបឹងទន្លេសាប បង្កើតបាននូវជម្រក និងចំណីដ៏សម្បូរបែប សម្រាប់ជីវៈចម្រុះគ្រប់ប្រភេទ ដូចជា ពពួកមច្ឆាជាតិ បក្សី ល្មូន ថនិកសត្វ និងរុក្ខជាតិគ្រប់ប្រភេទ ព្រមជាមួយនឹងរបរកសិកម្មដែលជាមូលដ្ឋានសំខាន់នៃសន្តិសុខស្បៀង និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជារាប់លាននាក់ ។

បច្ចុប្បន្នសម្ពាធនៃការអភិវឌ្ឍ និងកំណើនប្រជាជន ដែលពឹងផ្អែកទាំងស្រុងទៅលើធនធានធម្មជាតិនៃបឹងទន្លេសាបបាននឹងកំពុងធ្វើឲ្យហានិភ័យរបស់បឹងទទួលរងនូវការគម្រាមកំហែងដ៏ធ្ងន់ធ្ងរទៅលើសុខមាលភាពរបស់បឹង បរិស្ថាន ជីវៈចម្រុះ និងធនធានធម្មជាតិនៃបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ដូចជា ការកើនឡើងនូវការប្រើប្រាស់បច្ចេកវិជ្ជាខុសបទដ្ឋានបច្ចេកទេស ការកាប់បំផ្លាញរុករានទន្ទ្រានយកដីព្រៃលិចទឹក ការធ្វើអាជីវកម្មហួសកម្រិតមកលើធនធានជលផល បម្រែបម្រួលអាកាសធាតុ និងការសាងសង់ទំនប់វារីអគ្គិសនី ជាដើម ។

ដោយមើលឃើញពីសារសំខាន់របស់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ និងដើម្បីធានាដល់ការគ្រប់គ្រងអភិរក្ស និងការអភិវឌ្ឍប្រកបដោយនិរន្តភាព សម្រាប់រក្សាទុកជាកេរ្តិ៍មរតកដ៏ប្រពៃរបស់មនុស្សជាតិឲ្យបានយូរអង្វែង ។ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុងអាណត្តិទី ៥ នៃរដ្ឋសភា បានកំណត់នូវគោលនយោបាយអាទិភាពសំខាន់ៗ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ក្នុងការបន្តពង្រឹង និងពង្រីកបន្ថែមទៀតនូវការគ្រប់គ្រងធនធានធម្មជាតិសំដៅរក្សា " **តុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្ស** " ។

ដើម្បីរួមចំណែកការអនុវត្តគោលនយោបាយអាទិភាពសំខាន់ៗ របស់រាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរទន្លេសាប ដែលជាស្ថាប័នថ្មីមួយ និងជាសេនាធិការបន្ថែមជួយដល់រាជរដ្ឋាភិបាល ក្នុងបេសកកម្ម " **សម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប** " ។ អាជ្ញាធរទន្លេសាប បានរៀបចំឡើងនូវផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ (២០១៦-២០២០) សម្រាប់អាជ្ញាធរទន្លេសាប ដែលជាផែនការយុទ្ធសាស្ត្រដំណាក់កាលដំបូង សម្រាប់ធ្វើជាឧបករណ៍បង្ហាញទិស ក្នុងការអនុវត្តសកម្មភាពនានា ដើម្បីសម្រេចឲ្យបានតាមទិសដៅជាយុទ្ធសាស្ត្រ និងជាផែនទីបង្ហាញទិសដល់ក្រសួង ស្ថាប័នទាំងកម្រិតថ្នាក់ជាតិ និងកម្រិតថ្នាក់ក្រោមជាតិពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដែលមានគោលបំណងសហការ និងគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់អាជ្ញាធរទន្លេសាប ។ ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការពិនិត្យពិចារណាក្នុងការវិភាជន៍ថវិកាជួយគាំទ្រដល់ដំណើរការអនុវត្តន៍ផែនការយុទ្ធសាស្ត្ររយៈពេល៥ ឆ្នាំ របស់អាជ្ញាធរទន្លេសាប ប្រកបដោយភាពជោគជ័យ ។

ផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប ២០១៦-២០២០ ត្រូវបានរៀបរាប់ពន្យល់ដោយលម្អិត អំពីទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗក្នុងរយៈពេល ៥ ឆ្នាំ ដោយមានកំណត់នូវអាទិភាពនានា សូចនាករ ក្របខ័ណ្ឌពេលវេលាច្បាស់លាស់ និងយន្តការសម្រាប់តាមដានត្រួតពិនិត្យវាយតម្លៃផ្អែកលើក្របខ័ណ្ឌលទ្ធផល ដើម្បីអនុវត្តន៍សកម្មភាពជាយុទ្ធសាស្ត្រឲ្យបានជោគជ័យ។ ជាក់ស្តែង ផែនការយុទ្ធសាស្ត្រនេះ មានចែកជា ៨ ផ្នែកសំខាន់គឺ ៖ **ផ្នែកទី ១** សេចក្តីផ្តើម បង្ហាញពីដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប ។ **ផ្នែកទី ២** វិភាគពីស្ថានភាពតំបន់ទន្លេសាប បង្ហាញពីភាពប្រឈមនៃធនធានកម្រនៅតំបន់ទន្លេសាបនាបច្ចុប្បន្ន និងអនាគត ។ **ផ្នែកទី ៣** អាជ្ញាធរទន្លេសាប បង្ហាញពីបទដ្ឋានគតិយុត្ត បេសកកម្មអាណត្តិការងារ និងរចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប ។ **ផ្នែកទី ៤** ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងភាពប្រឈម ដែលអាជ្ញាធរទន្លេសាប បាននឹងកំពុងអនុវត្តន៍ការងារ ។ **ផ្នែកទី ៥** ទិសដៅជាយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ក្នុងការអនុវត្តការងារឲ្យបានជោគជ័យក្នុងអំឡុងពេល ៥ ឆ្នាំ (២០១៦-២០២០) ។ **ផ្នែកទី ៦** មធ្យោបាយប្រតិបត្តិ បង្ហាញពីមធ្យោបាយគន្លឹះ ក្នុងការប្រតិបត្តិការងារ ដើម្បីសម្រេចទិសដៅជាយុទ្ធសាស្ត្រ។ **ផ្នែកទី ៧** ថវិកាសម្រាប់អាជ្ញាធរទន្លេសាប បង្ហាញពីតម្រូវការថវិកាគាំទ្រដល់ដំណើរការផែនការយុទ្ធសាស្ត្រ ។ **ផ្នែកទី ៨** តាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រ បង្ហាញពីវឌ្ឍនភាពអនុវត្តផែនការ និងភាពជោគជ័យនៃផែនការយុទ្ធសាស្ត្រ ។

ជាមួយនេះដែរ ខ្ញុំសូមកោតសរសើរដោយស្មោះ ចំពោះឯកឧត្តមថ្នាក់ដឹកនាំ អស់លោក-លោកស្រី ដែលជាប្រធាន អនុប្រធាននៃនាយកដ្ឋាន និងការិយាល័យក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ដែលបានប្រឹងប្រែងខិតខំយកចិត្តទុកដាក់រៀបចំផែនការយុទ្ធសាស្ត្រនេះ ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី តំណាងពីក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍នានា អង្គការជាតិ-អន្តរជាតិ និងគ្រឹះស្ថានអប់រំសិក្សាស្រាវជ្រាវ ដែលបានសហការក្នុងការចូលរួមផ្តល់យោបល់ និងអនុសាសន៍ល្អៗ ដើម្បីគាំទ្រដល់ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ ប្រកបដោយជោគជ័យ ។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមថា ផែនការយុទ្ធសាស្ត្រនេះ នឹងជួយតម្រែតម្រង់ទិសការងារដល់នាយកដ្ឋានជំនាញក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប និងផ្តល់ការណែនាំដល់ក្រសួង ស្ថាប័នទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពាក់ព័ន្ធ ព្រមជាមួយដៃគូអភិវឌ្ឍនានា ដែលមានគោលបំណងសហការ និងជួយគាំទ្រដល់អាជ្ញាធរទន្លេសាប ដើម្បីសម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តទិសដៅជាយុទ្ធសាស្ត្រសម្រាប់រយៈពេល ៥ ឆ្នាំ ២០១៦-២០២០ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**លឹម គានហោ**

# មាតិកា


**អារម្ភកថា** ..... i

**តារាងមាតិកា** ..... iii

**១. សេចក្តីផ្តើម** ..... ១

១.១. សាវតា ..... ១

១.២. គោលបំណងនៃការសិក្សា និងលទ្ធផលរំពឹងទុក ..... ២

១.៣. វិធីសាស្ត្រ ..... ៣

**២. ការវិភាគស្ថានភាពតំបន់ទន្លេសាប** ..... ៤

២.១. ទិដ្ឋភាពទូទៅតំបន់បឹងទន្លេសាប ..... ៤

២.២. ភាពប្រឈមធនធានទឹក និងបរិស្ថាន ..... ៧

២.២.១. បម្រែបម្រួលរបបជលសាស្ត្រ ..... ៧

២.២.២. ការបំពុល និងគុណភាពទឹក ..... ៨

២.២.៣. ការរានដីព្រៃលិចទឹក និងវាលទំនាបលិចទឹក ..... ៩

២.២.៤. ផលិតភាពធនធានជលផល និងជីវៈចម្រុះ ..... ១១

២.២.៥. បម្រែបម្រួលអាកាសធាតុ ..... ១២

២.៣. ភាពប្រឈមសេដ្ឋកិច្ច សង្គមកិច្ច ..... ១៣

២.៣.១. ការទ្រទ្រង់ជីវភាពរស់នៅ ..... ១៣

២.៣.២. ស្ថានភាពសេដ្ឋកិច្ចសង្គម ..... ១៤

**៣. អាជ្ញាធរទន្លេសាប** ..... ១៦

៣.១. បទបញ្ញត្តិបង្កើតអាជ្ញាធរទន្លេសាប ..... ១៦

៣.១.១. អាណត្តិ និងភារកិច្ចរបស់អាជ្ញាធរទន្លេសាប ..... ១៦

៣.១.២. រចនាសម្ព័ន្ធ និងអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ..... ១៨

៣.១.៣. វិសាលភាពអនុវត្តន៍ការងាររបស់អាជ្ញាធរទន្លេសាប ..... ១៩

៣.២. ចក្ខុវិស័យ ..... ២២

៣.៣. បេសកកម្ម ..... ២២

៣.៤. គុណប្រយោជន៍គន្លឹះ ..... ២៣

**៤. ការវិភាគចំនុចខ្លាំង ខ្សោយ កាលានុវត្តភាព និងភាពប្រឈម (SWOT)** ..... ២៣

**៥. ទិសដៅជាយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប** ..... ២៧

៥.១. សេចក្តីផ្តើម ..... ២៧

៥.២. ទិសដៅជាយុទ្ធសាស្ត្រ......................................................................................ៈ៣២
៥.២.១. ការពង្រឹងគោលនយោបាយ, បទបញ្ញត្តិ, និងអង្គភាព/ស្ថាប័ន..............................៣២
៥.២.២. ការពង្រឹងការយល់ដឹងជាមូលដ្ឋាន អំពីតំបន់ទន្លេសាប......................................៣៣
៥.២.៣. សម្របសម្រួល កសាងផែនការ និងការគ្រប់គ្រង..................................................៣៤
៥.២.៤. ការទំនាក់ទំនង និងការកសាងសមត្ថភាពគ្រប់អ្នកពាក់ព័ន្ធ.................................៣៥
៥.២.៥. ការកសាងសមត្ថភាពខាងក្នុង........................................................................៣៦
**៦. មធ្យោបាយប្រតិបត្តិ**................................................................................ ៣៧
៦.១. សេចក្តីផ្តើម.............................................................................................៣៧
៦.២. អាទិភាពអន្តរាគមន៍របស់អាជ្ញាធរទន្លេសាប.........................................................៣៧
៦.២.១. អាទិភាពគន្លឹះរបស់អាជ្ញាធរទន្លេសាប.................................................................៣៧
៦.២.២. ការរៀបចំកម្មវិធីភាពជាដៃគូអាជ្ញាធរទន្លេសាប.......................................................៤១
៦.២.៣. ក្រសួងស្ថាប័នសំខាន់ៗ ដែលពាក់ព័ន្ធនឹងអាជ្ញាធរទន្លេសាប...................................៤៣
**៧. ថវិកាសម្រាប់ផែនការយុទ្ធសាស្ត្រ**...................................................................... ៤៨
**៨. តាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រ**............................................ ៥០
**ឧបសម្ព័ន្ធ ១ ៖** ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩/៧០៥ ស្តីពីការបង្កើត អាជ្ញាធរទន្លេសាប.................................................................................. ៥២
**ឧបសម្ព័ន្ធ ២ ៖** ព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ស្តីពីការកែសម្រួល មាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦៩/៧០៥ ស្តីពីការបង្កើត អាជ្ញាធរទន្លេសាប.................................................................................. ៥៩
**ឧបសម្ព័ន្ធ ៣ ៖** អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប.....................................៦៤
**ឧបសម្ព័ន្ធ ៤ ៖** ប្រកាសលេខ ០២៥ អទស ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ ការិយាល័យចំណុះបណ្តានាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប.......................................................................៦៩
**ឧបសម្ព័ន្ធ ៥ ៖** អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ស្តីពីការកំណត់ដែនព្រៃលិចទឹក ចំនួន ៦៤៧.៤០៦ ហិកតា ក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប..........៧៦

# ១. សេចក្តីផ្តើម

## ១.១. សាវតា

ដោយទទួលស្គាល់ពីវិសាលភាពអត្ថប្រយោជន៍ដ៏ធំធេងរបស់បឹងទន្លេសាប ដែលជាតំបន់ប្រកបទៅដោយប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ក្នុងការផ្តល់នូវសន្តិសុខស្បៀង និងជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា ទូទាំងប្រទេស ។ ជាពិសេស គឺជាមរតកវប្បធម៌ និងប្រវត្តិសាស្ត្រដ៏សំខាន់ កំណត់ពីអត្តសញ្ញាណជាតិនៃប្រទេសកម្ពុជា ។ បឹងទន្លេសាប ត្រូវបានកំណត់ដោយព្រះរាជក្រឹត្យ នាខែ វិច្ឆិកា ឆ្នាំ១៩៩៣ ថាជាតំបន់ការពារការប្រើប្រាស់ចម្រុះ (Multiple-Use Protected Area) និងត្រូវបានប្រកាសជា ឋបនីយជីវមណ្ឌលបឹងទន្លេសាប លក្ខណៈជាតិ និងអន្តរជាតិ ដោយអង្គការសហប្រជាជាតិ សម្រាប់ការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO) នៅឆ្នាំ ១៩៩៧ និងបានកំណត់ជាផ្លូវការដោយ ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០១ ស្តីពីការបង្កើត ការគ្រប់គ្រងឋបនីយ ជីវមណ្ឌលបឹងទន្លេសាប ។

ដើម្បីជាទឡ្ហីករណ៍ប្រសើរបំផុត សម្រាប់ការអភិវឌ្ឍជាយុទ្ធសាស្ត្រទៅលើគ្រប់វិស័យ (Sector wide approach) ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនដែលអាស្រ័យតាមដងទន្លេសាប ក្នុងយុទ្ធសាស្ត្រគាំពារជនក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចិរភាព ។ នាឆ្នាំ ២០០២ ក្រោមការរៀបចំឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) ហើយត្រូវបានរាជរដ្ឋាភិបាលកម្ពុជាអនុម័តក្នុងឆ្នាំ ២០០៣ នូវ**គំនិតផ្តួចផ្តើមបឹងទន្លេសាប (Tonle Sap Initiative)** ដែលផ្តល់នូវក្របខ័ណ្ឌការងារ សម្រាប់ការគ្រប់គ្រងអាងទន្លេសាប ទូលំទូលាយស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និងប្រសិទ្ធភាព ។

ស្តែងចេញពីលទ្ធផលការងារ **គំនិតផ្តួចផ្តើមបឹងទន្លេសាប** តាមរយៈវេទិកាជាតិ កាលពីថ្ងៃទី ០៥-០៦ ខែមីនា ឆ្នាំ ២០០៧ ស្តីពី "**កម្រងគម្រោងអភិរក្ស និងអភិវឌ្ឍន៍បឹងទន្លេសាប**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។ រាជរដ្ឋាភិបាល បានសម្រេចបង្កើត " **អាជ្ញាធរអាងទន្លេសាប** " នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០០៧ ។ ក៏ប៉ុន្តែដោយពិនិត្យលើស្ថានភាពជាក់ស្តែង និងបញ្ហាប្រឈមមួយចំនួន ដែលបង្កឲ្យជាន់ទៅនឹងតួនាទី ភារកិច្ចការងារជាមួយនឹងក្រសួង ស្ថាប័នផ្សេងទៀត ។ រាជរដ្ឋាភិបាល បានធ្វើការកំណែទម្រង់ឡើងវិញទៅលើរចនាសម្ព័ន្ធគ្រប់គ្រង តួនាទី ភារកិច្ច ក៏ដូចជាដែនសមត្ថកិច្ចវិសាលភាពនៃការគ្រប់គ្រងរបស់**អាជ្ញាធរអាងទន្លេសាប** ដែលមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើត " **អាជ្ញាធរទន្លេសាប** " និងបានធ្វើការកែសម្រួលទៅលើមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ។

តំបន់ទន្លេសាប មានសកម្មភាព និងគម្រោងជាច្រើន បាននឹងកំពុងតែអនុវត្តន៍តាមរយៈកម្មវិធី/គម្រោងពីបណ្តាក្រសួង ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ដោយបានចំណាយអស់ថវិកាជាច្រើន ដើម្បីធ្វើការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ។ ការផ្តួចផ្តើមកម្មវិធី/គម្រោងទាំងអស់នេះ ស្ថិតក្នុងការគិតគូរពីការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) បញ្ហាបរិស្ថាន និងការអភិវឌ្ឍ និងបរិបទផ្សេងៗ ។ ជាក់ស្តែងមកទល់នឹងបច្ចុប្បន្ននេះ រាល់សកម្មភាព និងកម្មវិធី/គម្រោង បាននឹងកំពុងតែអនុវត្តន៍នៅក្នុងតំបន់ទន្លេសាប នៅមិនទាន់បានផ្តល់កិច្ចសហការឲ្យបានរលូន ដើម្បីបន្សុីគ្នាជាមួយនឹងតួនាទី ភារកិច្ចទទួលខុសត្រូវរបស់ **អាជ្ញាធរទន្លេសាប** ក្នុងការសម្របសម្រួលឲ្យបានល្អប្រសើរ ជាមួយនឹងគំនិតផ្តួចផ្តើមផ្សេងទៀត ក្នុងអាងទាំងមូល ។ បញ្ហាទាំងអស់ខាងលើនេះ គឺជាកត្តានៃហានិភ័យទៅលើការអនុវត្តសកម្មភាពការងារជាន់គ្នា ដែលគួរធ្វើការសិក្សា និងពិចារណាឡើងវិញ អំពីគម្រោងធំៗមួយចំនួន ។

រាល់ក្របខ័ណ្ឌកម្មវិធី ត្រូវរៀបចំដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដែលត្រូវចាត់ទុកជាការងារអាទិភាពរបស់អាជ្ញាធរទន្លេសាប ក្នុងការជួយដល់ក្រសួង ស្ថាប័នដៃគូ និងគម្រោងជាច្រើន ដើម្បីបន្សុីគ្នាជាមួយនឹងសកម្មភាពការងាររបស់ **អាជ្ញាធរទន្លេសាប** ក្នុងការសម្របសម្រួល ដើម្បីបញ្ចៀសឲ្យបាននូវសកម្មភាពការងារត្រួតស៊ីគ្នា នៅក្នុងតំបន់តែមួយ លើការងារតែមួយ ។

## ១.២. គោលបំណងនៃការសិក្សា និងលទ្ធផលរំពឹងទុក

គោលបំណងសំខាន់នៃការសិក្សា រួមមាន ៖

- រៀបចំបង្កើតក្របខ័ណ្ឌកម្មវិធី ដែលជាគ្រោងប្លង់អាទិភាពសំខាន់ៗ សម្រាប់អាជ្ញាធរទន្លេសាប និងពង្រឹងប្រសិទ្ធភាពការងារសម្របសម្រួលដោយបង្កើតនូវយន្តការ នៃកិច្ចសហប្រតិបត្តិការរួមគ្នា (Cross-cutting sectorial mechanism) ក្នុងការបម្រើសេចក្តីត្រូវការ និងអាទិភាពការងារចម្បងក្នុងតំបន់ទន្លេសាប ដើម្បីឈានទៅរកទិសដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព
- សិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ ព័ត៌មាន ដើម្បីធ្វើការវិភាគ និងធ្វើបច្ចុប្បន្នភាព សម្រាប់ធ្វើការផ្សព្វផ្សាយ ចែករំលែក និងបណ្តុះបណ្តាល ដល់អ្នកពាក់ព័ន្ធ
- ប្រមូល វិភាគទិន្នន័យ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែង មធ្យម និងរយៈពេលខ្លី ឲ្យបានច្បាស់លាស់ ដែលជាទិសដៅ និងគោលដៅអាទិភាព របស់អាជ្ញាធរទន្លេសាប ដាក់ជូនរាជរដ្ឋាភិបាល ។

លទ្ធផលរំពឹងទុក នៃការសិក្សារួមមាន ៖

- ក្របខ័ណ្ឌកម្មវិធីអាទិភាពអាជ្ញាធរទន្លេសាប ត្រូវបានរៀបចំឡើងប្រកបដោយភាពច្បាស់លាស់
- ផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ត្រូវបានអនុម័ត និងធ្វើការផ្សព្វផ្សាយ ដើម្បីដាក់ឲ្យអនុវត្តន៍នៅដើមឆ្នាំ ២០១៦ ។

## ១.៣. វិធីសាស្ត្រ

ផ្អែកលើការផ្តួចផ្តើមនៃផែនការការងាររៀបចំផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ។ គម្រោងកម្មវិធីអភិវឌ្ឍន៍វិស័យគ្រប់គ្រងធនធានទឹក ADB CDTA-7610 CAM បានជួយគាំទ្រថវិកាដល់អាជ្ញាធរទន្លេសាបក្នុងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធបានចំនួន ២ លើក ដែលលើកទី ១ នៅថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៥ និងលើកទី ២ នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ ។ ទិសដៅនៃសិក្ខាសាលាពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធ ដើម្បីរៀបចំបង្កើតឡើងនូវក្របខ័ណ្ឌកម្មវិធី ដែលផ្តល់នូវចំណុច អាទិភាពរបស់អាជ្ញាធរទន្លេសាប និងពង្រឹងប្រសិទ្ធភាពការងារសម្របសម្រួលជាមួយដៃគូពាក់ព័ន្ធឲ្យកាន់ តែប្រសើរឡើងបម្រើដល់តម្រូវការ និងអាទិភាពតំបន់ទន្លេសាប ក្នុងការបញ្ចៀសឲ្យបាននូវការងារត្រួតស៊ីគ្នា ។

មន្ត្រីបច្ចេកទេសតំណាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ខេត្ត ដែលជាសមាជិករបស់អាជ្ញាធរទន្លេសាប វិទ្យាស្ថាន សាកលវិទ្យាល័យសិក្សាស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលធ្វើការផ្តោតទៅលើការគ្រប់គ្រងធនធានទឹកចម្រុះ បញ្ហាបរិស្ថាន ការអភិវឌ្ឍ និងបរិបទផ្សេងៗក្នុងតំបន់បឹងទន្លេសាប ដែលបានចូលរួម ។ ការពិភាក្សា ត្រូវបានរៀបចំចាត់ចែង តាមរយៈនៃការពិភាក្សាពេញលេញ និងការបែងចែកតាមក្រុម ដើម្បីជានាបាននូវការចូលរួមមតិ យោបល់ពីអ្នកពាក់ព័ន្ធ ។

ការប្រជុំពិភាក្សា បានជួយឲ្យភាគីពាក់ព័ន្ធ បញ្ចេញនូវរាល់គំនិតយោបល់សំខាន់ៗ និងចែករំលែកបទពិសោធន៍ការងារ ដើម្បីជានាបាននូវការរៀបចំនូវសេចក្តីព្រាងផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាបរយៈពេល ៥ ឆ្នាំ ។ សិក្ខាសាលាពិគ្រោះយោបល់ចំនួន ២ លើក ក៏បានផ្តល់ផងដែរនូវកម្មវិធីប្រកបដោយភាពស្និតស្នាលសម្រាប់ភាគីពាក់ព័ន្ធ ក្នុងការប្រមូលផ្តុំគំនិតយោបល់ ទស្សនវិស័យ អំពីការគ្រប់គ្រងធនធានទឹកចម្រុះ បញ្ហាបរិស្ថាន ការអភិវឌ្ឍ និងបរិបទផ្សេងៗទៀត នៅតំបន់បឹងទន្លេសាប ។ ចុងបញ្ចប់ ការពិភាក្សាបានផ្តល់នូវការយល់ដឹងកាន់តែស៊ីជម្រៅពីតួនាទីរបស់អាជ្ញាធរទន្លេសាប ។

ជាមួយនឹងការប្រមូលផ្តុំយោបល់ អនុសាសន៍ល្អៗពីក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ក្រុមការងារបច្ចេកទេសអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប សម្រាប់រៀបចំកសាងផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប ក៏បានប្រជុំពិភាក្សាប្រមូលផ្តុំរាល់របកគំហើញ គំនិតបន្ថែម តាមរយៈការសិក្សា ការអនុវត្តការងារផ្ទាល់នៅក្នុងអង្គភាព/ស្ថាប័ន ធ្វើការទំនាក់ទំនងដោយស្រង់ព័ត៌មាន ទិន្នន័យជាមួយក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីបញ្ហា ភាពប្រឈម និងកាលានុវត្តភាពដំណោះស្រាយ ក្នុងដំណើរការការងារឲ្យបានរលូន សម្រាប់ទិសដៅជាយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ។

ជាក់ស្តែង ផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប ត្រូវបានរៀបចំ និងបញ្ចប់នូវសេចក្តីព្រាង ដោយក្រុមការងារបច្ចេកទេសអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប និងធ្វើជូនទៅដល់បណ្តាក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ដើម្បីស្នើសុំការពិនិត្យ និងផ្តល់យោបល់បន្ថែមលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រនេះ ។ ជាមួយនឹងសេចក្តីព្រាងចុងក្រោយនៃផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ត្រូវបានបញ្ចប់ និងទទួលបាន

ការអនុម័តពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប នាពាក់កណ្តាលខែធ្នូ ឆ្នាំ ២០១៥ សម្រាប់ដាក់ឲ្យអនុវត្តន៍ចាប់ពីឆ្នាំ ២០១៦-២០២០ ។

# ២. ការវិភាគស្ថានភាពតំបន់ទន្លេសាប

## ២.១. ទិដ្ឋភាពទូទៅតំបន់បឹងទន្លេសាប

បឹងទន្លេសាប គឺជាបឹងទឹកសាបដ៏ធំជាងគេនៅតំបន់អាស៊ីអាគ្នេយ៍ ។ បឹងនេះ មានបណ្តោយប្រមាណ ១១៦ គ.ម ទទឹងប្រមាណពី ៣ គ.ម ទៅ ៣៣ គ.ម និងមានឆ្នេរប្រវែង ប្រមាណ ៤៨២ គ.ម នៅរដូវប្រាំង ។ បឹងទន្លេសាប ជាបេះដូងនៃប្រទេសកម្ពុជា ដែលមានតម្លៃមិនអាចកាត់ថ្លៃបានលើផ្នែកសង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ។ បឹងទន្លេសាប ត្រូវបានភ្ជាប់ទៅនឹងទន្លេមេគង្គតាមរយៈទន្លេសាបចំងាយប្រវែង ១២០ គ.ម[២] ដោយប្រសព្វគ្នានៃទន្លេទាំងពីរនៅត្រង់រាជធានីភ្នំពេញនៃប្រទេសកម្ពុជា ។ អំឡុងពេលធ្លាក់ខ្យល់មូសុងពីទិសនិរតី កម្ពស់ទឹកនៅក្នុងទន្លេមេគង្គឡើងលឿនជាងកម្ពស់ទឹកនៅក្នុងបឹងទន្លេសាប ដែលធ្វើឲ្យទឹកជំនន់ពីទន្លេមេគង្គមួយផ្នែកធំហូរចាក់ចូលទៅក្នុងទន្លេសាប ។ លំហូរទឹកពីទន្លេមេគង្គ បានបណ្តាលឲ្យទឹកក្នុងទន្លេសាប ហូរបញ្ច្រាស់ទិសត្រឡប់ឆ្ពោះទៅបឹងទន្លេសាប បង្កបានជាបាតុភូតជលសាស្ត្រធម្មជាតិ ដែលកម្រមាននៅក្នុងសកលលោក (MRCS/WUP-FIN 2007; Kummu & Srkkula 2008; MRC 2010; Mak et al. 2012) ។ បាតុភូតដ៏អស្ចារ្យនេះ បានបង្កើតឡើងនូវតំបន់ដីសើមដ៏ធំល្វឹងល្វើយ ដែលផ្តល់ជម្រកដល់ជីវៈចម្រុះសម្បូរបែបដូចជា ៖ មច្ឆាជាតិ បក្សាបក្សី សត្វល្មូន ថនិកសត្វ និងរុក្ខជាតិគ្រប់ប្រភេទ ។

វិសាលភាព របស់បឹងទន្លេសាប មានការប្រែប្រួលតាមរដូវកាល នៅរដូវប្រាំងបឹងទន្លេសាប មានជម្រៅពី ១ ម ទៅ ២ ម មានផ្ទៃក្រឡាប្រមាណ ២៥០.០០០ ហ.ត ប៉ុន្តែនៅរដូវវស្សាបឹងទន្លេសាប មានជម្រៅពី ៨ ម ទៅ ១១ ម មានផ្ទៃក្រឡាប្រមាណ ១.៥០០.០០០ ហ.ត ។ ផ្ទៃក្រឡាបឹងទន្លេសាបនៅរដូវវស្សាមានទំហំធំជាងនៅរដូវប្រាំងប្រមាណពី ៥ ទៅ ៦ ដង ។ ទឹកក្នុងបឹងទន្លេសាបនៅរដូវវស្សាបានមកពីទន្លេមេគង្គ ៦២ % និង ៣៨ % ទៀត បានមកពីបណ្តាស្ទឹង ធំៗជុំវិញបឹងទន្លេសាបទាំង ១១ ស្ទឹង ។ មាឌទឹកបឹងទន្លេសាបប្រែប្រួលប្រមាណពី ៤.៥០០ លានម៉ែត្រគូប នៅរដូវប្រាំង ទៅ ១៣៥.០០០ លានម៉ែត្រគូប នៅរដូវវស្សា ។

ទឹកជំនន់មកពីទន្លេមេគង្គ មានឥទ្ធិពលទាំងបរិមាណទឹក និងគុណភាពទឹកទៅក្នុងបឹងទន្លេសាប ។ លំហូរដីល្បាប់កក់ ដែលបានហូរចាក់ពីទន្លេមេគង្គទៅកាន់ទន្លេសាប គឺច្រើនលើសលុប និងផ្តល់នូវជីជាតិយ៉ាងសម្បូរបែប សម្រាប់ប្រព័ន្ធវាលទំនាបលិចទឹកជុំវិញបឹងទន្លេសាប រួមទាំងធនធានជលផលផងដែរ ។ ចរន្តទឹកជំនន់ គឺជាកម្លាំងចលករដ៏សំខាន់ សម្រាប់ផលិតភាពប្រព័ន្ធអេកូឡូស៊ីនៅទន្លេសាប ដែលរួមមានផលិតភាពត្រី នៃប្រព័ន្ធបឹង ។ ម្យ៉ាងទៀត លំហូរដីល្បាប់កក់/កំទេចកំណរឹងដែលហូរចាក់ពីទន្លេមេគង្គ ទៅទន្លេសាប ផ្តល់នូវជីវជាតិយ៉ាងសំខាន់ ជាពិសេសពពួកផូស្វ័រ (Phosphorus) សម្រាប់ផលិតភាពចំណីអាហារក្នុងទឹក ព្រមទាំងសម្រាប់ជម្រកនៅលើគោកក្នុងតំបន់ទំនាបលិចទឹកជុំវិញបឹងទន្លេសាប ។ ប្រភេទព្រៃលិចទឹកខ្ពស់ៗនៅផ្នែកខាងលើ ដែលព័ទ្ធជុំវិញបឹងទន្លេសាបជាអចិន្ត្រៃយ៍ បង្កើតបានជាប្រព័ន្ធអេកូឡូស៊ី

ដ៏សំខាន់មួយ និងជារបាំងរូបសាស្ត្រដ៏សំខាន់ផងដែរ រវាងបឹងដ៏ល្បីល្បើយ និងវាលទំនាបលិចទឹក ដែលបង្កើតជាលក្ខខណ្ឌអនុគ្រោះ សម្រាប់ការហូរចាក់ដីល្បាប់ភក់នៅក្នុងតំបន់ដែលមានព្រៃជុះ ។ ចលនាចរន្តទឹកជំនន់ មានឥទ្ធិពលយ៉ាងខ្លាំងមកលើលក្ខខណ្ឌប្រព័ន្ធអេកូឡូស៊ី និងជម្រកនៅក្នុងវាលទំនាបលិចទឹក ដែលអាចកំណត់បាននូវការបែងចែកការប្រើប្រាស់ដី សម្រាប់ការអាស្រ័យផលដំណាំកសិកម្ម នៅក្នុងវាលទំនាបលិចទឹក ។

ដោយឡែក បច្ចុប្បន្នសម្ពាធនៃការអភិវឌ្ឍ កំណើនប្រជាជន វិសមភាពនៃសិទ្ធិទទួលផល និងភាពក្រីក្ររបស់ប្រជាជន ដែលពឹងផ្អែកធនធានធម្មជាតិទាំងនេះ បាននឹងកំពុងតែធ្វើឲ្យប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់យ៉ាងខ្លាំង ដែលប្រឈមនឹងគ្រោះគម្រាមកំហែងនៃការធ្វើអាជីវកម្មហួសកម្រិត ហើយប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប ត្រូវបានទទួលរងនូវការបំផ្លិចបំផ្លាញមកលើបរិស្ថាន ។ កំណើនប្រជាជននៅតាមដងទន្លេ នៅតែបន្តកើនឡើងឥតឈប់ឈរ ដែលមួយផ្នែកនៃការកើនឡើងនូវចំនួនប្រជាជននៅតំបន់នេះស្រាប់ផង និងមួយផ្នែកទៀតការហូរចូលប្រជាជនពីតំបន់ផ្សេងៗនៃបណ្តាខេត្តដទៃ ។ ចលនាផ្លាស់ប្តូរប្រជាជន ដើម្បីស្វែងរកមុខរបរចិញ្ចឹមជីវិត ដែលប្រការនេះ បានក្លាយជាទម្ងន់មួយថែមទៀតទៅលើការប្រើប្រាស់ធនធាននៅក្នុងបឹងទន្លេសាប ។ ការគម្រាមកំហែងជាចម្បងដល់បឹងទន្លេសាប រួមមាន ៖ ការធ្វើអាជីវកម្មហួសកំណត់លើធនធានជលផល និងធនធានសត្វព្រៃ ការប្រែក្លាយតំបន់ព្រៃលិចទឹកទៅជាផ្ទៃដីកសិកម្ម ការទន្ទ្រានយកដីក្នុងតំបន់លិចទឹក ការកាប់ឈើធ្វើអុសពីព្រៃលិចទឹក និងការនេសាទខុសច្បាប់ ។ ការបាត់បង់តំបន់ព្រៃលិចទឹក បានជះឥទ្ធិពលធ្ងន់ធ្ងរដល់ផលនេសាទ ដោយសារការទន្ទ្រានដីក្នុងគោលបំណងធ្វើកសិកម្ម ក្នុងទ្រង់ទ្រាយតូច ទ្រង់ទ្រាយធំ និងការកាប់ឈើធ្វើជាអុស ពីព្រោះធនធានថាមពលមានកម្រិត ។

ការធ្លាក់ចុះយ៉ាងលឿននៃធនធានធម្មជាតិនៅក្នុងអាងទន្លេសាប បណ្តាលឲ្យភាពក្រីក្រនៅតំបន់នោះមានកម្រិតខ្ពស់ ព្រមទាំងដាក់សម្ពាធទៅលើធនធាននៃបឹងទន្លេសាប ។ ការកើនឡើងនូវការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វល្អិតនៅតាមអាងទន្លេសាប អាចបង្កើតនូវការបំពុលបរិស្ថានក្នុងបឹងទន្លេសាបយ៉ាងធ្ងន់ធ្ងរ ។ ការគ្រប់គ្រងទឹកនៅប្រភពទឹកខាងលើ បាននឹងកំពុងតែគម្រាមកំហែងមកដល់ជម្រកធម្មជាតិរបស់ពូជសត្វជាច្រើន បានបណ្តាលឲ្យមានជម្លោះក្នុងការប្រើប្រាស់ទឹក ដើម្បីធ្វើវារីអគ្គិសនី ការប្រើប្រាស់ក្នុងស្រុក និងប្រព័ន្ធប្រឡាយទឹក ។ លើសពីនេះទៀត ការចាប់យកដីនៅក្នុងតំបន់ព្រៃលិចទឹក ដើម្បីបង្កើតអាងទឹក កាប់ឈើ កាប់អុស ឬទន្ទ្រានព្រៃយកដីធ្វើកសិកម្ម នឹងបំផ្លាញដល់ស្ថិរភាពនៃប្រព័ន្ធអេកូឡូស៊ី បង្កឲ្យមានការហូរច្រោះដី ការខូចគុណភាពដី បាត់បង់ដីល្បាប់ ទឹកជំនន់ និងល្អក់ប្រភពទឹកនៅខាងក្រោម ។


HYDROLOGICAL FLOW MAP IN CAMBODIA (DRY)
200
300
400
500
600
700
800
160
150
140
130
120


HYDROLOGICAL FLOW MAP IN CAMBODIA (WET)

## ២.២. ភាពប្រឈមធនធានទឹក និងបរិស្ថាន

ភាពសម្បូរបែបធនធានធម្មជាតិនៃបឹងទន្លេសាប បច្ចុប្បន្ន បាននឹងកំពុងតែទទួលរងនូវការគម្រាមកំហែង ហើយនឹងប្រឈមយ៉ាងធ្ងន់ធ្ងរនាពេលអនាគតមកលើប្រព័ន្ធអេកូឡូស៊ីដ៏កម្រនេះ ជាពិសេសមកលើធនធានជលផល (ត្រី) ដែលធ្លាប់ផ្តល់រហូតដល់ ៧៥ % នៃប្រូតេអ៊ីនសម្រាប់ប្រជាជនកម្ពុជានៅជនបទ ។ ការគម្រាមកំហែងមកលើធនធានធម្មជាតិនៃបឹងទន្លេសាបភាគច្រើន ត្រូវបានសង្កេតឃើញពាក់ព័ន្ធនឹងបញ្ហាការធ្វើអាជីវកម្មហួសកម្រិតមកលើធនធាន ដែលបណ្តាលមកពីការគ្រប់គ្រងច្បាប់ ស្ថាប័ន ភាពក្រីក្រ ការគ្មានដី ការធ្វើចំណាកស្រុក ចេញ-ចូលនៅតំបន់បឹងទន្លេសាប ការកើនឡើងនូវការអភិវឌ្ឍ ការពង្រីកផ្ទៃដីកសិកម្មនៅតំបន់ព្រៃលិចទឹក និងវាលទំនាបលិចទឹកជុំវិញបឹងទន្លេសាប ។

## ២.២.១. បម្រែបម្រួលរបបជលសាស្ត្រ

កំណើនសេដ្ឋកិច្ចយ៉ាងរហ័ស ជាពិសេសប្រទេសស្ថិតខាងលើអាងទន្លេមេគង្គ បានបង្កើនការផលិតនូវថាមពលវារីអគ្គិសនី និងផែនការអភិវឌ្ឍន៍ផ្សេងៗទៀត ។ កម្រិតលំហូរនៃទឹកទន្លេមេគង្គ និងដៃទន្លេ ត្រូវបានផ្លាស់ប្តូររូបរាងយ៉ាងរហ័ស និងសកម្មភាពអភិវឌ្ឍន៍នានា ដូចជា ៖ ការសាងសង់ទំនប់ សម្រាប់វារីអគ្គិសនី ការអភិវឌ្ឍផ្លូវនាវាចរ ការបង្វែទឹកទន្លេសម្រាប់ស្រោចស្រព ការអភិវឌ្ឍឧស្សាហកម្ម និងដំណោះស្រាយមនុស្ស ។ ការកសាងទំនប់សម្រាប់ការអភិវឌ្ឍវារីអគ្គិសនីនៅក្នុងតំបន់ ក៏បានធ្វើឲ្យប្រែប្រួលនូវរបបលំហូរក្នុងអាងទន្លេមេគង្គទាំងមូលផងដែរ ។

បឹងទន្លេសាប និងទំនាបលិចទឹក ត្រូវបានទទួលស្គាល់ថា ជាប្រព័ន្ធចរន្តទឹកជំនន់ (Flood pulse) ដ៏អស្ចារ្យ ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងទន្លេមេគង្គ ។ ចរន្តទឹកជំនន់ គឺជាកម្លាំងចលករដ៏សំខាន់សម្រាប់ផលិតភាពនៃប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប រួមជាមួយនឹងធនធានជលផល និងជីវៈចម្រុះ ។ លើសពីនេះទៀត ការហូរនាំដីល្បាប់ភក់/កំទេចកំទី ពីទន្លេមេគង្គទៅទន្លេសាប បានផ្តល់នូវជីជាតិយ៉ាងសំខាន់សម្រាប់ដីកសិកម្ម ស្ថិតនៅតាមវាលទំនាបលិចទឹកក្នុងតំបន់ទន្លេសាប ។ ចរន្តទឹកជំនន់ទន្លេសាប មានសញ្ញាណពីរ ដែលទំនាក់ទំនងគ្នាទៅវិញទៅមក ៖ ជាបរិមាណ (កម្រិតទឹក រួមទាំងពេលវេលា និងអំឡុងពេលតាមដំណាក់កាលខុសៗគ្នានៃចលនាចរន្តទឹកជំនន់) និងគុណភាព (គុណភាពទឹក រួមទាំងលំហូរល្បាប់ភក់/កំទេចកំទី)។

ហេតុនេះ ការអភិវឌ្ឍធនធានទឹកនៅផ្នែកខាងលើអាងទន្លេមេគង្គ អាចនាំឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់របបទឹកជំនន់ ពេលវេលា និងរយៈពេលទឹកជំនន់នៅក្នុងអាងទន្លេមេគង្គ នៅបឹងទន្លេសាប។ បម្រែបម្រួលនេះមិនត្រឹមតែបង្កបញ្ហាដល់របបជលសាស្ត្រ ប៉ុន្តែក៏មានផលប៉ះពាល់ជាអវិជ្ជមានទៅលើផលិតភាពនៃបឹងទន្លេសាប និងប្រព័ន្ធអេកូឡូស៊ីវាលទំនាបលិចទឹក។ ជាក់ស្តែងបញ្ហាខាងក្រោមនេះ គឺជាផលប៉ះពាល់បណ្តាលមកពីការអភិវឌ្ឍផ្នែកខាងលើទន្លេមេគង្គ ៖

- ✓ កាត់បន្ថយកម្រិតទឹកជំនន់នារដូវវស្សា និងកើនឡើងនូវកម្រិតទឹកជំនន់នារដូវប្រាំង នាំឲ្យមានបម្រែបម្រួលលំហូរទឹកនៅរដូវវស្សា និងរដូវប្រាំង ។ ការកើនឡើងកម្រិតទឹកនៅរដូវប្រាំង អាចបណ្តាលឲ្យ ហិនហោចនូវព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប ប្រសិនបើត្រូវបានលិចលង់ជាអចិន្ត្រៃយ៍ ។

ថែមទាំងប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីចលនាចរន្តទឹកជំនន់ទន្លេសាប ដោយកាត់បន្ថយជម្រក (លំនៅ ដ្ឋាន) ត្រី និងប៉ះពាល់ផលិតភាពប្រព័ន្ធអេកូឡូស៊ីទន្លេសាប ព្រមជាមួយនឹងកាត់បន្ថយកម្រិតទឹក និងតំបន់វាលទំនាបលិចទឹកក្នុងរដូវវស្សា ដែលអាចជះឥទ្ធិពលដល់ចរាចរត្រី ។

- ✓ ការយឺតពេលនៃទឹកជំនន់ នឹងបណ្តាលឲ្យភាពសម្បូរបែបនៃអុកស៊ីសែនក្នុងទឹកមានភាពយឺតយ៉ាវ ដែលអាចនឹងប៉ះពាល់ដល់ត្រី ក្នុងរដូវពងកូន ។ ជាមួយនឹងរយៈពេលយឺតយ៉ាវនៃទឹកជំនន់ និងពេលវេលានៃលំហូរទឹកចេញ ចូលបឹងទន្លេសាប តាមរយៈទន្លេសាប និងទន្លេមេគង្គ អាចប៉ះពាល់ដល់រយៈពេល និងផ្លូវចរាចរត្រី រួមទាំងរយៈពេលនៃការរីកធំធាត់របស់ត្រី
- ✓ ល្បាប់កក់ ចំណីអាហារហូរចាក់ទៅបឹង និងប្រព័ន្ធវាលទំនាបលិចទឹក ត្រូវបានកាត់បន្ថយ ដែលអាចប៉ះពាល់ប្រព័ន្ធចលនាចរន្តទឹកជំនន់ រួមជាមួយនឹងធនធានចំណីអាហារសម្រាប់ជីវៈចម្រុះ ។ ការបាត់បង់នូវល្បាប់កក់/កំទេចកំទីនៅក្នុងទឹកជំនន់ អាចបណ្តាលឲ្យបាត់បង់នូវជីប្រែកប ដោយជីជាតិធម្មជាតិ ដែលបញ្ហានេះ នឹងប៉ះពាល់ដល់ផលិតភាពប្រព័ន្ធអេកូឡូស៊ីនៃបឹងទន្លេសាប ។

ដោយឡែកការប្រកួតប្រជែងការអភិវឌ្ឍនៅតាមតំបន់វាលទំនាបលិចទឹកក្នុងតំបន់បឹងទន្លេសាប ក៏ជាសកម្មភាពមួយ ដែលបាននឹងកំពុងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់របបជលសាស្ត្រ និងប្រព័ន្ធអេកូឡូស៊ី នៃបឹងទន្លេសាបផងដែរ ។ ជាក់ស្តែង ប្រព័ន្ធស្រោចស្រពសម្រាប់ប្រពលវប្បកម្មដំណាំស្រូវ គឺស្ថិតក្នុងចំណោមសកម្មភាពអភិវឌ្ឍន៍សំខាន់ៗនៅតំបន់វាលទំនាបលិចទឹកជុំវិញបឹងទន្លេសាប ។ អាងទឹកជាច្រើន ត្រូវបានសាងសង់ឡើងនៅតំបន់វាលទំនាបលិចទឹកចន្លោះផ្លូវជាតិលេខ ៥ លេខ ៦ ខណៈពេលដែលទំនប់វារីអគ្គិសនីត្រូវបានកសាងឡើង និងស្ថិតក្នុងគម្រោងសាងសង់ នៅតាមដៃទន្លេនៃបឹងទន្លេសាប ។ អាងទឹកស្រោចស្រពជាច្រើន ត្រូវបានសាងសង់ ដើម្បីរក្សាទឹកជំនន់ទុកនៅរដូវប្រាំង កាត់បន្ថយទឹកទាញយកពីទន្លេសាប និងប្រភពទឹកផ្សេងៗ សម្រាប់ស្រោចស្រពដីស្រែនៅជុំវិញអាង ។ ភាគច្រើនការសាងសង់អាងទឹកនៅតំបន់វាល ទំនាបលិចទឹកជុំវិញបឹងទន្លេសាប មិនមានការពិគ្រោះយោបល់ជាផ្លូវការ និងមានការសាងសង់ខុសបច្ចេកទេស ដែលនាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅដល់សក្តានុពលនៃរបបជលសាស្ត្រ និងប្រព័ន្ធអេកូឡូស៊ី ព្រមជាមួយនឹងការមិនពេញចិត្តរបស់ប្រជាជនដែលរស់នៅជុំវិញតំបន់បឹងទន្លេសាប ។

## ២.២.២. ការបំពុល និងគុណភាពទឹក

តាមរបាយការណ៍របកគំហើញ នៃការតាមដានពីផលប៉ះពាល់គុណភាពទឹកជាប្រចាំនៅក្នុងប្រទេសកម្ពុជា ក្រោមកម្មវិធីបរិស្ថានរបស់គណៈកម្មការទន្លេមេគង្គ សហការជាមួយក្រសួងធនធានទឹក និងឧតុនិយម ចាប់តាំងពីឆ្នាំ ១៩៩៣ ។ ជាពិសេសរបាយការណ៍ចុងក្រោយ ស្តីពីលទ្ធផលរបកគំហើញគុណភាពទឹកលើដីនៅឆ្នាំ ២០១២ គឺតម្លៃសន្ទស្សន៍មានកម្រិតទាបនៅតំបន់អាងទន្លេសាប ដែលត្រូវបានទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំងពីសកម្មភាពរបស់មនុស្ស លើផ្នែកកសិកម្ម ។ ការធ្វើប្រពលវប្បកម្មដំណាំស្រូវ និងការពង្រីកកសិកម្មស្ថិតក្នុងប្រព័ន្ធអេកូឡូស៊ីតំបន់វាលទំនាបលិចទឹកជុំវិញបឹងទន្លេសាប បាននឹងកំពុងតែបង្កើននូវការប្រើប្រាស់សារធាតុគីមីកសិកម្ម ដូចជាការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីគីមី ។ ការប្រើប្រាស់នូវថ្នាំសម្លាប់សត្វល្អិត និងជីគីមី ដើម្បីបង្កើនទិន្នផលតាមតម្រូវការ បានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធអេកូ

ឡូស៊ី និងមួយផ្នែកបង្កឲ្យប៉ះពាល់ទៅដល់ផលិតផលធនធានជលផល ដែលនាំឲ្យគ្រោះថ្នាក់ដល់សុខភាពសាធារណៈតាមរយៈការកើនឡើងនៃជាតិពុលក្នុងសាច់ត្រី ។

ទោះបីការហាមមិនឲ្យប្រើប្រាស់នូវថ្នាំ និងសារធាតុគីមីទៅលើដំណាំកសិកម្ម ដូចមានចែងក្នុងអនុក្រឹត្យស្តីពីស្តង់ដារ និងការគ្រប់គ្រងវត្ថុធាតុដើមនៃកសិកម្ម (១៩៩៨) ក៏ដោយ ក៏ការប្រើប្រាស់វត្ថុធាតុដើមទាំងអស់នោះ នៅតែជាកត្តាចាំបាច់សម្រាប់ការបង្កើនទិន្នផល ។ ករណីការសិក្សាបានបង្ហាញឲ្យឃើញថា នៅតាមតំបន់វាលទំនាបលិចទឹកក្នុងខេត្តទាំង ៦ នៅជុំវិញបឹងទន្លេសាប បានប្រើប្រាស់សារធាតុគីមីសម្រាប់បង្កើនទិន្នផល ស្ថិតក្នុងកម្រិតខ្ពស់ ។

ការបំពុលទឹក អាចបណ្តាលមកពីកត្តាធំៗចំនួនពីរ គឺកាកសំណល់ឧស្សាហកម្ម ដែលរួមមានកាកសំណល់ ដែលចេញមកពីឧស្សាហកម្មធនតូច វិស័យកសិកម្ម និងកាកសំណល់ប្រើប្រាស់តាមគ្រួសារ ។ បច្ចុប្បន្នការអភិវឌ្ឍឧស្សាហកម្មធនតូច និងមធ្យម បាននឹងកំពុងតែនាំចូលនូវកាកសំណល់ជាតិពុលខុសច្បាប់ ដែលបង្កឲ្យគ្រោះថ្នាក់ដល់សុខភាពសាធារណៈ និងប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប ។ កាកសំណល់រាវតាមតំបន់ជនបទ និងតាមគ្រួសារ មិនបានចម្រោះទេ តែបានបញ្ចេញចោលដោយផ្ទាល់ចូលទៅក្នុងទឹកបឹង ។ ទាំងនេះបានធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹក ជាពិសេសនៅក្នុងរដូវប្រាំង ពេលដែលកម្រិតទឹកបឹងទន្លេសាបមានសភាពរាក់មិនហូរ និងមានសីតុណ្ហភាពខ្ពស់ ។

## ២.២.៣. ការរានដីព្រៃលិចទឹក និងវាលទំនាបលិចទឹក

ព្រៃលិចទឹកនៅតំបន់ទន្លេសាបរបស់ប្រទេសកម្ពុជា គឺជាសម្បត្តិធម្មជាតិមួយដ៏មានសារៈសំខាន់ ដែលពោរពេញទៅដោយរុក្ខជាតិព្រៃឈើក្រាស់ ព្រៃគុម្ពោធ ព្រៃរបោះ វល្លិ៍ ស្មៅ និងពពួកវារីរុក្ខជាតិ ដែលអាចធន់នឹង កម្រិតកម្ពស់ទឹកពី ៥ ទៅ ៧ ម៉ែត្រ ទាំងរដូវប្រាំង និងរដូវវស្សា ។ ព្រៃលិចទឹកទាំងនេះ ក៏បង្ហាញនូវចំណុច សំខាន់ៗជាច្រើន គួរជាទីមោទនភាពរបស់ខ្មែរយើង ដែលមានបឹងធម្មជាតិមួយហ៊ុំព័ទ្ធទៅដោយព្រៃលិចទឹក ហើយដែលបានផ្តល់នូវទំនាក់ទំនងជាមួយនឹង (១) ដី គឺជួយរក្សានុវគុណភាពដីឲ្យបានល្អប្រសើរ (២) ជីវៈចម្រុះ គឺចិញ្ចឹមនូវជីវៈចម្រុះជាច្រើនប្រភេទ ដោយរក្សាការពារនូវតំបន់ដីសើម ក្នុងការរក្សាទឹក និងបញ្ចេញទឹកមកនារដូវប្រាំង ផ្តល់ដល់ទន្លេសាប ដែលធ្វើឲ្យជីវៈចម្រុះអាចមានជីវិត និងមានស្ថិរភាពបានល្អប្រសើរ (៣) ទឹក គឺធ្វើឲ្យទឹករក្សាបាននូវនិយ័តភាពបានល្អ ព្រោះថាបើមានព្រៃលិចទឹក នោះគុណភាពទឹកត្រូវបានជួយ សំអាតមួយចំណែកធំ ដែលហៅថា វិធីចម្រោះទឹកបែបធម្មជាតិ ។ កាត់បន្ថយនូវរំហួតកុំឲ្យខ្លាំងពេក និងកាត់បន្ថយនូវល្បឿនខ្យល់ដែលជានិច្ចកាលតែងធ្វើការយាយីដល់លំនៅដ្ឋានប្រជាពលរដ្ឋដែលរស់នៅតាមបឹងទន្លេសាប (៤) បាតុភូតធម្មជាតិ គឺទប់ទល់នឹងការហូរច្រោះ នៃលំហូរទឹកភាគខាងលើ ដែលនាំឲ្យខ្សោះដីជាតិ និងការពារភាពគោករាក់របស់បឹងទន្លេសាប (៥) ត្រី និងវារីសត្វ គឺជម្រកដ៏សំខាន់សម្រាប់ត្រី និងវារីសត្វ ក្នុងការពងកូន ជាកន្លែងបង្កើតនូវចំណី និងសម្រាប់ជ្រកពួន ក្នុងការគេចផុតពីការយាយី ដែលជាច្បាប់ជីវសាស្ត្រ (៦) ទេសចរណ៍ គឺផ្តល់នូវតម្លៃខ្ពស់ សម្រាប់ទេសចរណ៍ភាវូបនីយកម្ម ដែលផ្តោតសំខាន់ទៅលើ ទេសចរណ៍ធម្មជាតិ ។

ដោយសារតែការគ្រប់គ្រង និងការប្រើប្រាស់ធនធានព្រៃលិចទឹក ពុំមានលក្ខណៈសមស្រប និងប្រកបដោយនិរន្តភាព បានធ្វើឲ្យព្រៃលិចទឹកតំបន់ជុំវិញបឹងទន្លេសាប និងតំបន់វាលទំនាបលិចទឹក ត្រូវបានទទួលរងនូវវិនាសកម្មខ្ទេចខ្ទីពីមួយឆ្នាំ ទៅមួយឆ្នាំ បណ្តាលមកពីកត្តាមនុស្ស ដែលបង្កនូវសកម្មភាពគ្រោះមហន្តរាយ យ៉ាងធ្ងន់ធ្ងរ ដូចជា ការកាប់ព្រៃធ្វើអុសធ្យូង ការដុតព្រៃចាប់សត្វនានា ការកាប់សម្រះ ជាពិសេសការកាប់រានយកដីធ្វើកសិកម្ម និងការទន្ទ្រានយកដីធ្វើជាកម្មសិទ្ធិតាមគ្រប់រូបភាព ដែលជាបច្ច័យដ៏អាក្រក់បំផុតក្នុងការ បំផ្លិចបំផ្លាញព្រៃលិចទឹក និងតំបន់វាលទំនាបលិចទឹកជុំវិញបឹងទន្លេសាប ។

តាមការសិក្សាស្រាវជ្រាវស្ថិតិបានឲ្យដឹងថានិន្នាការនៃការកើនឡើង និងថយចុះរបស់ព្រៃលិចទឹកតាមរយៈផ្កាយរណបរបស់ MRC UNDP និង FAO នៅឆ្នាំ១៩៧៣ ដល់ឆ្នាំ ១៩៧៦ បានបង្ហាញឲ្យឃើញថាព្រៃលិចទឹកនៅតំបន់ទឹកសាបនៅប្រទេសកម្ពុជាមានចំនួនប្រមាណ ១លានហិកតា ។ ដោយឡែក តាមនិន្នាការ នៃការបាត់បង់ព្រៃលិចទឹកទឹកសាបនៅទូទាំងប្រទេស ក៏បានបង្ហាញឲ្យឃើញពីភាពធ្ងន់ធ្ងរទៅៗចាប់ពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ២០០២ តាមរយៈនៃការសិក្សាឡើងវិញរបស់នាយកដ្ឋានជលផល បានឲ្យដឹងថានៅឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៦ ព្រៃលិចទឹកមានទំហំប្រមាណ ៩៣៨.៣០០ ហិកតា នៅឆ្នាំ ១៩៨៥ ដល់ឆ្នាំ ១៩៨៧ ព្រៃលិចទឹកមានទំហំប្រមាណ ៨៣២.៦០០ ហិកតា និងនៅឆ្នាំ ១៩៩២ ដល់ឆ្នាំ ១៩៩៣ ព្រៃលិចទឹកមានទំហំប្រមាណ ៦២៩.៥០០ ហិកតា ។

ដោយមើលឃើញពីផលប៉ះពាល់កាន់តែធ្ងន់ធ្ងរឡើងមកលើតំបន់ទន្លេសាប និងតំបន់វាលទំនាបលិចទឹក រាជរដ្ឋាភិបាលកម្ពុជា បានបន្តការយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការជម្រុញកិច្ចការការពារធនធានធម្មជាតិ និងជីវៈចម្រុះ ជាពិសេសការគ្រប់គ្រង អភិរក្ស អភិវឌ្ឍន៍ធនធានដ៏កម្រនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធឲ្យប្រកបដោយនិរន្តរភាព ផ្តល់ប្រយោជន៍ជាអតិបរមាដល់ប្រជាពលរដ្ឋទូទាំងប្រទេស ។ ជាលទ្ធផលតាមរយៈនៃកិច្ចខិតខំប្រឹងប្រែងដោយយកចិត្តទុកដាក់របស់ អាជ្ញាធរទន្លេសាប ក្នុងកិច្ចសហការជាមួយក្រសួងស្ថាប័ន និងខេត្តពាក់ព័ន្ធនៅតំបន់ជុំវិញបឹងទន្លេសាប នៅឆ្នាំ ២០១១ រាជរដ្ឋាភិបាលបានកំណត់ និងដាក់ឲ្យអនុវត្តន៍ជាផ្លូវការនូវអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១ ស្តីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧.៤០៦ ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ។

ជាការពិតសមត្ថកិច្ចគ្រប់គ្រង និងយោងលើច្បាប់ជលផលត្រង់ជំពូកទី ៦ ស្តីពីការគ្រប់គ្រងនាទីព្រៃ លិចទឹក និងព្រៃកោងកាង ដែលមានមាត្រា ២៦, ២៧, ២៨ និង២៩ ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃលិចទឹក គឺជាភារកិច្ចរបស់រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ក៏ប៉ុន្តែជាក់ស្តែងការកំណត់ដែនព្រៃលិចទឹកមិនបានកំណត់ឲ្យបានច្បាស់លាស់ និងមានវិធានការណ៍ការពារឲ្យបានដាច់ខាតទន្ទឹមនឹងមហន្តរាយនៅតែកើតមានជារៀងរាល់ថ្ងៃ ។ ជាក់ស្តែង តាមការចុះអធិការកិច្ចរបស់ក្រុមការងារមន្ត្រីអាជ្ញាធរទន្លេសាប កាលពីឆ្នាំ ២០១៤ បានបង្ហាញឲ្យឃើញថា ត្រឹមរយៈពេល ៣ឆ្នាំ បន្ទាប់ពីអនុក្រឹត្យកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៦.៤០៦ ហិកតា នាឆ្នាំ ២០១១ គឺព្រៃលិចទឹកតំបន់ជុំវិញបឹងទន្លេសាបស្ថិតក្នុងតំបន់ ៣ ត្រូវបានបន្តទទួលរងនូវការបំផ្លិចបំផ្លាញ និងបាត់បង់អស់ចំនួន ៣៨.២១៨ ហិកតា ។ ទំហំនៃការបាត់បង់នេះ គឺបង្ហាញពីភាពមិនយកចិត្តទុកដាក់ក្នុងការគោរពតួនាទី និងការទទួលខុសត្រូវការងាររបស់អាជ្ញាធរដែនដី និងក្រសួងស្ថាប័នពាក់ព័ន្ធ ហើយការបាត់បង់នេះនឹងអាចក្លាយទៅជាវិនាសកម្ម

ក្នុងលក្ខណៈទ្រង់ទ្រាយកាន់តែធំទៅៗនាពេលអនាគត ដែលជះឥទ្ធិពលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី និងធនធានជលផល ជីវៈចម្រុះរបស់បឹងទន្លេសាប ។

## ២.២.៤. ផលិតភាពធនធានជលផល និងជីវៈចម្រុះ

បឹងទន្លេសាប ប្រកបដោយប្រព័ន្ធអេកូឡូស៊ីស្មុគ្រស្មាញ ខណៈដែលបរិស្ថានវិទ្យា ត្រូវគាំពារដោយរបបជលសាស្ត្រពីប្រព័ន្ធទន្លេមេគង្គ និងប្រភពទឹកជម្រាលជុំវិញតំបន់ទន្លេសាប ។ បឹងទន្លេសាប នៅតែត្រូវបានចាត់ទុកជាបឹងដែលពោរពេញទៅដោយផលិតភាពគ្រប់បែបយ៉ាងនៅក្នុងពិភពលោក ជាពិសេសធនធានត្រីទឹកសាប ។ បឹងទន្លេសាប ក៏ជាជម្រកនៃការបង្កបង្កើតជីវៈចម្រុះ រួមទាំងប្រភេទសំខាន់ៗដែលត្រូវអភិរក្ស ។ ប្រភពធនធានរបស់បឹង បង្ហាញឲ្យឃើញពីភាពខ្លាំងនៃសេដ្ឋកិច្ច និងអត្ថប្រយោជន៍នៃវប្បធម៌សម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនទូទាំងប្រទេស ។ បឹងទន្លេសាប បានផ្តល់នូវទាយជ្ជទានដ៏គាប់ប្រសើរនូវទេសភាពវប្បធម៌ ជាមួយនឹងទីក្រុងប្រវត្តិសាស្ត្រអង្គរ សហគមន៍ភូមិបណ្តែតទឹក បូករួមជាមួយនឹងទីក្រុងស៊ីវិល័យ និងទេសភាពនៃរបរកសិកម្ម ។ ដំណាំស្រូវ និងការនេសាទត្រី ត្រូវបានចាត់ទុកជាប្រភពចម្បងនៃចំណូលសម្រាប់ប្រជាជនតំបន់ជនបទ ។ ទន្ទឹមនឹងភាពសម្បូរបែបនេះ បច្ចុប្បន្នបឹងទន្លេសាប បាននឹងកំពុងស្ថិតក្រោមការកើនឡើងនូវសម្ពាធដ៏ធ្ងន់ធ្ងរ ចំពោះកំណើនប្រជាជនដ៏ឆាប់រហ័ស ការទន្ទ្រានព្រៃលិចទឹក ការពង្រីកផ្ទៃដីកសិកម្ម ការធ្វើអាជីវកម្មនេសាទហួសកម្រិត ការប្រមាញ់សត្វព្រៃ សកម្មភាពមនុស្ស និងការអភិវឌ្ឍតំបន់ជនបទ និងសមាហរណកម្មតំបន់ ។

ដោយសារតែចលនាចរន្តទឹកជំនន់ បានធ្វើឲ្យផលិតភាពត្រី បានដើរតួនាទីសំខាន់ និងបង្កើតជាមូលដ្ឋានគ្រឹះ សម្រាប់ទ្រទ្រង់ជីវភាពរស់នៅក្នុងមូលដ្ឋាន សន្តិសុខស្បៀង និងជីវភាពប្រចាំថ្ងៃ ។ ខណៈដែលចលនាចរន្តទឹកជំនន់ មានទំនាក់ទំនងជិតស្និតជាមួយនឹងផលិតភាពវារីសត្វក្នុងទឹក សម្រាប់ធនធានជលផល និងជីវៈចម្រុះតំបន់ទន្លេសាប ដែលនឹងទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារការអភិវឌ្ឍនៅផ្នែកខាងលើតាមដងទន្លេមេគង្គ និងតាមដៃទន្លេនានា ។ ជាក់ស្តែង យោងតាម MRC/IKMP (2010) ការកសាងទំនប់វារីអគ្គិសនីនៅតំបន់ផ្នែកខាងលើទន្លេមេគង្គ បានធ្វើឲ្យថយចុះនូវផលិតភាពចម្បងរបស់បឹងផ្ទាល់ និងនៅតំបន់វាលទំនាបលិចទឹកជុំវិញបឹងទន្លេសាប "ប្រព័ន្ធអេកូឡូស៊ី និងផលិតភាពចម្បងនៃប្រព័ន្ធទន្លេសាប អាចប្រែប្រួលយ៉ាងខ្លាំង តាមរយៈអន្តរកម្មដែលកើតមានដំណាលគ្នានៃការគំរាមកំហែងទាំងនេះ ដូចជា ៖ ការថយចុះទឹកជំនន់ លំហូរទឹកបញ្ច្រាសបានថយចុះ និងការថយចុះនៃលំហូរចូលនៃជីវជាតិ ដែលនាំមកនូវល្បាប់កក់ និងការធ្លាក់ចុះយ៉ាងខ្លាំងនូវធនធានជលផល និងជីវៈចម្រុះ ដោយសារបម្រែបម្រួលរបបជលសាស្ត្រ ។

ការកសាងនូវហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ផ្សេងៗនៅតាមតំបន់វាលទំនាបលិចទឹកជុំវិញតំបន់ទន្លេសាប ក៏បាននឹងកំពុងតែគម្រាមកំហែង ទៅលើចលនាចរន្តទឹកជំនន់ បានធ្វើឲ្យប៉ះពាល់ដល់ការលិចលង់នូវជម្រក (លំនៅដ្ឋាន) ទៅតាមរដូវកាល និងធ្វើឲ្យមានការប្រែប្រួលដល់ផ្លូវចរាចរត្រី ។ ការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងនេះ និងសំណង់ផ្សេងៗ បានបង្កឲ្យមានការផ្លាស់ប្តូរនូវរបបជលសាស្ត្រ តាមលក្ខណៈធម្មជាតិ រួមមាន ៖ ការស្ទាក់លំហូរទឹកចេញក្រៅ Outflow (ទំនប់ ប្រព័ន្ធស្រោចស្រព របាំង) ការពារលំហូរទឹក

ចូលក្នុង Inflow (ទំនប់ការពារទឹក ទំនប់ទឹក Polder) និងការផ្លាស់ប្តូរលំហូរទឹកចូលក្នុង និងចេញក្រៅ Inflow and Outflow (ផ្លូវគោក ផ្លូវរទេះភ្លើង ជីកព្រែក) ។

ជាមួយនេះដែរ តំបន់ទន្លេសាប ក៏ត្រូវបានប្រឈមគ្រប់រូបភាពក្នុងការគ្រប់គ្រងធនធានក្នុងកម្រិតគោលនយោបាយ និងការអនុវត្ត ។ ប្រព័ន្ធគ្រប់គ្រងសម្រាប់វិស័យជលផល ត្រូវបានកំណត់ក្រោមច្បាប់ជលផល និងត្រូវបានធ្វើកំណែទម្រង់ជាបន្តបន្ទាប់ ។ ច្បាប់នេះ ក៏បានកំណត់ពីសិទ្ធិ អាជ្ញាប័ណ្ណដែលអាចទទួលបាន និងប្រភេទនៃការប្រើប្រាស់ឧបករណ៍ ដែលត្រូវបានច្បាប់អនុញ្ញាតឲ្យ ដោយផ្អែកលើថាតើការនេសាទមានលក្ខណៈជាគ្រួសារ ឬក្នុងទ្រង់ទ្រាយតូច ឬថាតើមានលក្ខណៈជាអាជីវកម្ម (ក្នុងទ្រង់ទ្រាយមធ្យមឬធំ) ។ បើទោះបីជាច្បាប់បានកំណត់ និងបានចែងច្បាស់លាស់ ក៏ប៉ុន្តែធនធានជលផលបឹងទន្លេសាប នៅតែបាន នឹងកំពុងតែទទួលរងនូវការគំរាមកំហែងផងដែរ ដោយសារតែ បទល្មើសគ្រប់រូបភាព និងសកម្មភាពបំផ្លិចបំផ្លាញ រួមទាំងការប្រើប្រាស់ចរន្តអគ្គិសនីឆក់ និងការប្រើប្រាស់អួនស្បៃមុងក្រឡាញឹក ហើយនឹងការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាស់ក្នុងការធ្វើអាជីវកម្មលក្ខណៈធនមធ្យម និងធនធំ នៅរដូវហាមឃាត់ការនេសាទ ។

## ២.២.៥. បម្រែបម្រួលអាកាសធាតុ

បច្ចុប្បន្នលទ្ធផលបម្រែបម្រួលអាកាសធាតុ បានបង្ហាញឲ្យឃើញពីផលប៉ះពាល់ជាក់ស្តែងទៅលើរបបជលសាស្ត្រនៃទន្លេមេគង្គ និងបឹងទន្លេសាបដែលមានរយៈពេលវែង ។ ជាមួយនឹងបម្រែបម្រួលដែលពាក់ព័ន្ធនឹងអាកាសធាតុ ក៏ត្រូវបានរំពឹងនឹងកើតមាននៅតាមតំបន់ទន្លេសាប ហើយផលប៉ះពាល់នៅក្នុងតំបន់នេះភាគច្រើន គឺដោយសារតែការប្រែប្រួលរបបជលសាស្ត្រក្នុងតំបន់អាងទន្លេមេគង្គទាំងមូល ។

តាមការសិក្សាអំពីសេណារីយ៉ូនៃបម្រែបម្រួលអាកាសធាតុ ក៏បានបង្ហាញឲ្យឃើញថា កម្រិតកម្ពស់នៃទឹកបឹងទន្លេសាបនៅរដូវវស្សា មានសភាពខ្ពស់ ជាលទ្ធផលតំបន់លិចទឹក និងកំពស់ទឹកជំនន់កើនឡើងខ្ពស់ជាប្រចាំ និងធ្វើឲ្យផ្លាស់ប្តូរនូវពេលវេលា និងរយៈពេលនៃចរន្តទឹកជំនន់ ។ បម្រែបម្រួលទាំងអស់នេះអាចនាំឲ្យមានចលនាចរន្តទឹកជំនន់កាន់តែខ្លាំងឡើង និងបង្កឲ្យខូចខាតដល់ដំណាំកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងរុក្ខជាតិវាលទំនាបលិចទឹក ព្រមជាមួយនឹងកាត់បន្ថយនូវជីមានជីជាតិនៅក្នុងតំបន់ ។ ទោះបីជាបម្រែបម្រួលនេះ ក៏ជាផលប៉ះពាល់មានលក្ខណៈវិជ្ជមានផងដែរ ដូចជា ៖ បង្កើននូវផលិតភាពប្រព័ន្ធអេកូឡូស៊ី និងបង្កលទ្ធភាពទឹកគ្រប់គ្រាន់នៅរដូវប្រាំង ។

ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ មកលើការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនតាមមូលដ្ឋាន ត្រូវបានទទួលរងនូវផលប៉ះពាល់ដោយផ្ទាល់ពីបម្រែបម្រួលផ្សេងៗទៀតនៅក្នុងបរិស្ថាន ដោយសារតែភាពទំនាក់ទំនងគ្នាយ៉ាងជិតស្និតនៃមូលហេតុ និងប្រសិទ្ធផល ។ តាមរយៈនៃការសិក្សាស្រាវជ្រាវ លទ្ធភាពនៃផលប៉ះពាល់បម្រែបម្រួលអាកាសធាតុមកលើការទ្រទ្រង់ជីវភាពរស់នៅនាពេលអនាគត និងបម្រែបម្រួលបរិស្ថានផ្សេងទៀត ត្រូវបានស្រាវជ្រាវតាមរយៈភាពមិនទៀងទាត់នៃចលនាចរន្តទឹកជំនន់ទន្លេសាប និងភាពទូទៅដទៃទៀតក្នុងបរិស្ថាន ។

របកគំហើញចេញពីការសង្កេតបានស្តែងឲ្យឃើញថា ភាគច្រើននៃភាពប្រឈមនៅក្នុងអតីតកាល ត្រូវបានពាក់ព័ន្ធទៅនឹងទឹកជំនន់ ភាពរាំងស្ងួតដែលខុសពីប្រក្រតី និងផលប៉ះពាល់ទៅលើហេដ្ឋារចនាសម្ព័ន្ធ ការទ្រទ្រង់ជីវភាពរស់នៅ និងសន្តិសុខស្បៀង ។ ផលប៉ះពាល់ជាសំខាន់ភាគច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធ ដែលពាក់ព័ន្ធនឹងទឹកជំនន់ក្នុងកម្រិតខ្ពស់ ដែលបណ្តាលឲ្យខូចខាតផ្លូវថ្នល់ និងរចនាសម្ព័ន្ធជារូបវន្ត ព្រមជាមួយនឹងការលិចលង់ផ្ទះសម្បែងប្រជាជន ។ ការជន់លិចក្នុងកម្រិតខ្ពស់ ក៏បានបណ្តាលឲ្យប៉ះពាល់ដល់ការទ្រ ទ្រង់ជីវភាពរស់នៅរបស់ប្រជាជន ដូចជា ៖ ការផ្លាស់ប្តូរពេលវេលា សម្រាប់ការប្រមូលផលច្រូតកាត់ស្រូវ និងការនេសាទបង្កនូវការលំបាកដោយសារផ្ទៃទឹកជំនន់ធំធេង ។

គ្រោះរាំងស្ងួត ក៏ជាកត្តាប្រឈមមួយផ្សេងទៀត សម្រាប់ការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ទន្លេសាប ។ រាល់បញ្ហាជាទូទៅពាក់ព័ន្ធនឹងភាពខ្វះខាតដែលអាចទទួលបាននូវទឹកស្អាតផឹក និងការធ្វើឲ្យខូចនូវគុណភាពទឹកក្នុងទន្លេ ស្រះ និងត្រពាំង ដែលជះឥទ្ធិពលប៉ះពាល់ដល់សុខមាលភាពរបស់ប្រជាពលរដ្ឋ ។ ភាពរាំងស្ងួត បានប៉ះពាល់ដោយផ្ទាល់តែម្តងទៅនឹងការទ្រទ្រង់ជីវភាពរស់នៅរបស់គ្រួសារកសិករ ដែលអាស្រ័យនឹងប្រព័ន្ធស្រោចស្រពក្នុងរដូវប្រាំង ។

តាមរយៈនៃការសិក្សាស្រាវជ្រាវ បម្រែបម្រួលបិរស្ថាន និងផលប៉ះពាល់ផ្សេងទៀត បានបណ្តាលឲ្យកាត់បន្ថយគុណភាពដី និងគុណភាពទឹក ព្រមជាមួយនឹងការធ្លាក់ចុះនូវធនធានធម្មជាតិ ។ ជាពិសេសភាពប្រឈមនឹងការធ្លាក់ចុះនូវផលចាប់ត្រី បូករួមជាមួយនឹងការប្រើប្រាស់នូវឧបករណ៍ខុសច្បាប់ ការបំផ្លាញជម្រក និងការធ្វើអាជីវកម្មហួសកម្រិត ។ ភាពប្រឈមនឹងបម្រែបម្រួលបរិស្ថានក្នុងរយៈពេលខ្លី បានបង្កឲ្យមានព្យុះខ្លាំង ជាមួយនឹងខ្យល់កន្ត្រាក់ ដែលបណ្តាលឲ្យបំផ្លាញដល់ផ្ទះសម្បែង ទូក ដំណាំ និងបង្កឲ្យមានគ្រោះថ្នាក់ដល់ជីវិត និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជននៅតាមតំបន់ទន្លេសាប ។

## ២.៣. ភាពប្រឈមសេដ្ឋកិច្ច សង្គមកិច្ច

### ២.៣.១. ការទ្រទ្រង់ជីវភាពរស់នៅ

វិស័យកសិកម្មនៅតំបន់ទន្លេសាប និងតំបន់វាលទំនាបលិចទឹកជុំវិញបឹងទន្លេសាប នៅតែជាប្រភពដ៏សំខាន់នៃការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន ។ ក៏ប៉ុន្តែដោយសារ កំណើនប្រជាជនបានកើនឡើងយ៉ាងរហ័សនៅតំបន់ទន្លេសាបជៀបឆ្នាំ ១៩៩៨ បានធ្វើឲ្យតម្រូវការប្រើប្រាស់ធនធានធម្មជាតិ ក្នុងការទាញយកអត្ថប្រយោជន៍ច្រើនយ៉ាងពីបឹងទន្លេសាប និងវាលទំនាបលិចទឹក ដែលបង្កឲ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីកាន់តែធ្ងន់ធ្ងរ និងបានបណ្តាលឲ្យផលិតកម្មកសិកម្ម មានការថយចុះមួយកម្រិត ។

បើទោះបីរាជរដ្ឋាភិបាល បានជម្រុញឲ្យអនុវត្តន៍នូវគោលនយោបាយកសិកម្មយ៉ាងខ្លាំងក្លាក៏ដោយ ក៏ការអនុវត្តគោលនយោបាយនេះ នៅមានកម្រិតដោយសារប្រជាជនរស់នៅតំបន់នោះ ដែលពឹងអាស្រ័យនឹងរបរកសិកម្មមានការខ្វះខាតដើមទុន មិនយល់អំពីការច្នៃប្រឌិតថ្មី និងកង្វះនូវហេដ្ឋារចនាសម្ព័ន្ធជារូបវន្តក្នុងវិស័យកសិកម្ម ហើយដែលតម្រូវឲ្យកសិករមានទ្រង់ទ្រាយតូចមួយចំនួន បានធ្លាក់ខ្លួនជំពាក់បំណុល និងត្រូវបង្ខំចិត្តលក់ដី ផ្ទះសម្បែង ។ ហេតុនេះ សង្វាក់ផលិតកម្មកសិកម្មជាទូទៅ ពុំបានលើកស្ទួយឲ្យបាន

ខ្លាំងក្លាចំពោះការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន តែបានបង្កឱកាសឲ្យមនុស្សមួយក្តាប់តូច ដែលមានជីវភាពធូរជា និងមានលទ្ធភាពវិនិយោគគ្រប់បែបយ៉ាង ថែមទាំងកៀបសង្កត់ទៅលើប្រជាជន ។

របរនេសាទ គឺជាសកម្មភាពយ៉ាងសំខាន់សម្រាប់គ្រួសារប្រជាជនជាច្រើន ដែលរស់នៅតំបន់បឹងទន្លេសាប ។ បច្ចុប្បន្ន ការពឹងផ្អែកទៅលើធនធានជលផលនៅជុំវិញបឹងទន្លេសាប បាននឹងកំពុងតែជួបប្រឈមក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រកបដោយចិរភាព សម្រាប់ប្រជាជនដែលរស់នៅក្នុងបឹងទន្លេសាប និងនៅជុំវិញតំបន់ទន្លេសាប ។ ចេញពីទស្សនទាននៃប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន ដែលងាយទទួលរងគ្រោះក្នុងរយៈពេលខ្លី និងវែង ដោយសារតែផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ។ ជាក់ស្តែង បម្រែបម្រួលកម្រិតទឹកភ្លៀង កម្រិតកំពស់ទឹក រយៈពេល និងបម្រែបម្រួលទំហំនៃតំបន់ព្រៃលិចទឹក ។ បម្រែបម្រួលទាំងនេះ ក៏អាចបណ្តាលមកពីសកម្មភាពរបស់មនុស្ស ដូចជាការសាងសង់ទំនប់ ការកាប់បំផ្លាញព្រៃលិចទឹក ការប្រើប្រាស់ជីគីមីក្នុងរបរកសិកម្ម និងការអភិវឌ្ឍផ្សេងៗ ។ ផលលំបាក ដែលជះឥទ្ធិពលផ្ទាល់ចំពោះធនធានធម្មជាតិ និងការចិញ្ចឹមជីវិតរស់នៅរបស់មនុស្ស គឺបម្រែបម្រួលទៅលើធនធានជលផល និងធនធានវារីរុក្ខជាតិ ដែលបណ្តាលមកពីការបាត់បង់នូវកន្លែងពងកូន និងទីជម្រក (លំនៅដ្ឋាន) ដែលផ្តល់ឲ្យនូវការធ្លាក់ចុះនូវផលចាប់ ។ ប្រភេទសកម្មភាពផ្សេងទៀត ជាមួយនឹងផលប៉ះពាល់អាក្រក់មកលើធនធានជលផល (ផលចាប់) និងចំណូលរបស់ប្រជាជន (សហគមន៍) គឺការប្រើប្រាស់នូវឧបករណ៍នេសាទខុសច្បាប់ និងបំផ្លិចបំផ្លាញ និងការធ្វើអាជីវកម្មហួសកម្រិត ។ ការអភិវឌ្ឍផ្សេងទៀត រួមមាន ការចិញ្ចឹម កសិកម្ម ទេសចរណ៍ និងសំណង់ផ្សេងៗ ក៏អាចបណ្តាលឲ្យបាត់បង់នូវព្រៃលិចទឹក និងប៉ះពាល់ដល់សុខមាលភាពប្រព័ន្ធអេកូឡូស៊ីនៃបឹងទន្លេសាប ។

ភាពប្រឈមសំខាន់មួយផ្សេងទៀត ដែលជះឥទ្ធិពលដល់ការទ្រទ្រង់ជីវភាពរបរនេសាទ គឺអភិបាលកិច្ច និងការគ្រប់គ្រងស្ថាប័ន ដែលតម្រូវឲ្យអនុវត្តន៍នូវគោលនយោបាយកំណែទម្រង់វិស័យជលផល ។ កំណែទម្រង់លើវិស័យនេះ គឺជាកត្តាមួយធ្វើឲ្យមានបម្រែបម្រួលដ៏ធំក្នុងការគ្រប់គ្រងធនធានជលផលនៅក្នុងតំបន់ទន្លេសាប ហើយវាអាចកើនឡើងគួរឲ្យយកចិត្តទុកដាក់អំពីតួនាទីនៃធនធានជលផលនៅក្នុងតំបន់ទាំងក្នុងការទ្រទ្រង់ជីវភាពរស់នៅ និងការបង្កើតប្រាក់ចំណូល ។

ជាទូទៅការប្រឈមនៅក្នុងការទ្រទ្រង់ជីវភាពរស់នៅអាស្រ័យនឹងរបរនេសាទ គឺពាក់ព័ន្ធទៅនឹងទិដ្ឋភាពប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន (ជំលោះអ្នកពាក់ព័ន្ធ ជម្រើសការទ្រទ្រង់ជីវភាពរស់នៅមានកម្រិត) និងទិដ្ឋភាពគោលនយោបាយ និងការគ្រប់គ្រង (ការចូលរួមរបស់អ្នកពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព) ។

## ២.៣.២. ស្ថានភាពសេដ្ឋកិច្ចសង្គម

កត្តាបម្រែបម្រួលសេដ្ឋកិច្ច សង្គមកិច្ចសំខាន់បំផុតនៅតំបន់ទន្លេសាប គឺកត្តាកំណើនប្រជាជន ដែលបាននឹងកំពុងតែកើនឡើងយ៉ាងលឿន ។ ប្រជាជនរស់នៅតំបន់ទន្លេសាប បានកើនឡើងពី ១.៥ លាននាក់ ក្នុងឆ្នាំ ១៩៩៨ ទៅ ១.៧ លាននាក់នៅឆ្នាំ ២០០៨ គឺកើនឡើងចំនួន ១៤% (វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ) ។ ទន្ទឹមនឹងអត្រានៃភាពក្រីក្រនៅទូទាំងប្រទេសកម្ពុជានៅក្នុងឆ្នាំ ២០១១ (ផែនការយុទ្ធសាស្ត្រ

អភិវឌ្ឍន៍ជាតិ ២០១៤-២០១៨) បានធ្លាក់មកនៅកម្រិត ១១% ។ ក៏ប៉ុន្តែ អត្រានៃភាពក្រីក្រនៅតំបន់ជនបទតាមខេត្តជុំវិញតំបន់បឹងទន្លេសាប នៅតែស្ថិតក្នុងកម្រិតមួយគួរឲ្យបារម្ភ (២០%-២៣%) ។

ការពិតកំណើនប្រជាជននៅតំបន់ទន្លេសាបនាពេលបច្ចុប្បន្ន គឺស្ថិតក្នុងសន្ទុះគួរឲ្យព្រួយបារម្ភបំផុតក្នុងសកម្មភាពសេដ្ឋកិច្ចចន្លោះពីឆ្នាំ ១៩៩៨ ដល់ ២០០៨ ចំពោះការកើនឡើងនូវយុវជនដែលពោរពេញដោយកម្លាំងការងារ ។ ការកើនឡើងនូវសមាមាត្រនៃប្រជាជន ដែលមានអាយុចូលបម្រើការងារ បានឆ្លុះបញ្ចាំងពីបរិបទមួយយ៉ាងរឹងមាំក្នុងកិច្ចអភិវឌ្ឍន៍មួយ ដែលផ្តល់នូវលទ្ធភាពគ្រប់បែបយ៉ាងសម្រាប់ភាពមានការងារធ្វើ ។ បើមិនដូចនោះទេ កំណើននៃកម្លាំងពលកម្មការងារ អាចនឹងបណ្តាលឲ្យមានបញ្ហាដល់សង្គមជាតិនៅពេលដែលប្រជាជនកាន់តែច្រើន មានការប្រកួតប្រជែងគ្នា ដើម្បីទាញយកនូវធនធានធម្មជាតិ មានកម្រិតនៅតំបន់ទន្លេសាប មកប្រើប្រាស់។

ជាទូទៅ ប្រជាជនដែលរស់នៅជិតផ្លូវជាតិភាគច្រើនមានស្ថានភាពគ្រួសារប្រសើរជាង ប្រជាជនដែលរស់នៅជិតបឹងទន្លេសាប ។ ប្រជាជនដែលរស់នៅជិតបឹងទន្លេសាបភាគច្រើន មានស្ថានភាពគ្រួសារក្រីក្របំផុត ដែលបានទទួលនូវការអប់រំតិចតួច មានជម្រើសក្នុងការទ្រទ្រង់ជីវភាពរស់នៅតិចតួច គ្មានដីកសិកម្មរស់នៅពឹងអាស្រ័យផ្ទាល់នឹងធនធានធម្មជាតិ ដែលជាកម្មសិទ្ធិរួម ដូចជា ធនធានទឹក ធនធានជលផល និងព្រៃលិចទឹក សម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។ បញ្ហាមួយទៀតដែលជាកត្តាប្រឈមខ្លាំងបំផុតដែរ គឺប្រជាជនរស់នៅផ្ទាល់នឹងបឹងទន្លេសាប ដែលការតាំងទីលំនៅជាភូមិបណ្តែតទឹក ហើយដែលមានស្ថាន ភាពរស់នៅងាយនឹងទទួលរងគ្រោះ ។

ជាមួយនឹងបញ្ហាខាងលើ តំបន់បឹងទន្លេសាប បាននឹងកំពុងតែប្រឈមជាមួយនឹងបញ្ហាសេដ្ឋកិច្ចសង្គមកិច្ចក៏ដូចនឹងតំបន់ទាំងមូលដែរ ខណៈដែលប្រជាជនជិត ២ លាននាក់ បាននឹងកំពុងតែរស់នៅក្នុងតំបន់បឹង និងទំនាបលិចទឹក ទទួលបានប្រយោជន៍ដោយផ្ទាល់ ឬដោយប្រយោលពីធនធានបឹង ក្នុងលក្ខខណ្ឌជីវភាពរស់នៅ និងសន្តិសុខស្បៀងអាហារ ។ ការកើតឡើងនូវជម្លោះបញ្ហាសេដ្ឋកិច្ច សង្គមកិច្ចដោយសារតែការប្រើប្រាស់ធនធានធម្មជាតិ ការកើនឡើងនូវសម្ពាធអាជីវកម្មរបរនេសាទ ការផ្លាស់ប្តូរក្នុងភាពជាម្ចាស់ និងលទ្ធភាពទទួលបាន (ប្រភពធនធាន និងទីផ្សារ) និងអតុល្យភាពនៃយេនឌ័រ និងក្រមសីលធម៌ គឺជាបញ្ហាប្រឈមក្នុងការរក្សាបាននូវនិរន្តភាពការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុង និងជុំវិញតំបន់ទន្លេសាប។ ជម្លោះរវាងក្រុមអ្នកប្រើប្រាស់កាន់តែធ្ងន់ធ្ងរ ដោយសារតែការកាន់កាប់គ្រប់គ្រងមួយផ្នែកធំក្នុងបឹងនៃការធ្វើអាជីវកម្មនេសាទ ក្នុងអំឡុងរដូវនេសាទ ដែលជានិច្ចកាលប្រើប្រាស់នូវបច្ចេកទេសនេសាទខុសច្បាប់ ។ ស្របជាមួយនឹងបញ្ហាប្រឈមនៃក្រុមប្រជាជនវ័យក្មេង កំពុងចូលរួមក្នុងកម្លាំងពលកម្មដែលធ្វើឲ្យសម្ពាធដ៏ធ្ងន់ធ្ងរមកលើធនធានធម្មជាតិក្នុងតំបន់នេះ អនាគតតំបន់ទន្លេសាបពឹងផ្អែកសំខាន់យ៉ាងខ្លាំងទៅលើ ថាតើប្រភពនៃការទ្រទ្រង់ជីវភាពរស់នៅបែបណា ដែលយុវជនទាំងនេះចង់បាន ក៏ដូចជាមានលទ្ធភាពនឹងឆ្ពោះទៅរក ។

# ៣. អាជ្ញាធរទន្លេសាប

## ៣.១. បទបញ្ញត្តិបង្កើតអាជ្ញាធរទន្លេសាប

### ៣.១.១. អាណត្តិ និងភារកិច្ចរបស់អាជ្ញាធរទន្លេសាប

បឹងទន្លេសាប និងវាលទំនាបលិចទឹក គឺជាតំបន់ជីវៈចម្រុះសកលដ៏សំខាន់មួយ ដែលជួយទ្រទ្រង់ដល់ផលិតផល ត្រី ស្រូវ ផលិតផលកសិកម្ម និងធនធានដីសើមដ៏ច្រើន ព្រមទាំងបានបង្កើតជាមូលដ្ឋានធនធានសន្តិសុខស្បៀង និងការទ្រទ្រង់ជីវភាពរស់របស់ប្រជាជនរាប់លាននាក់សម្រាប់ប្រទេសកម្ពុជាទាំងមូល ។

បច្ចុប្បន្នសម្ពាធនៃការអភិវឌ្ឍ និងកំណើនប្រជាជន បានធ្វើឲ្យហានិភ័យនៃបឹងទន្លេសាប បាននឹងកំពុងតែទទួលរងនូវការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ ទៅដល់សុខមាលភាពបឹង បរិស្ថាន ជីវៈចម្រុះ និងធនធាន ធម្មជាតិនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ដូចជា ការកើនឡើងនូវការប្រើប្រាស់បច្ចេកវិជ្ជាខុសបទដ្ឋាន បច្ចេកទេស ការកាប់បំផ្លាញ រុករានទន្ទ្រានយកដីព្រៃលិចទឹក ការធ្វើអាជីវកម្មហួសកម្រិតលើធនធានជលផល បម្រែបម្រួលអាកាសធាតុ និងការសាងសង់ទំនប់វារីអគ្គីសនីជាដើម ។

ដើម្បីជានាដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព សម្រាប់រក្សាទុកជាកេរ្តិ៍មរតក ដ៏ប្រពៃរបស់មនុស្សជាតិបានយូរអង្វែង ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបង្កើតស្ថាប័នថ្មីមួយ ដែលជាសេនាធិការបន្ថែមជួយដល់រាជរដ្ឋាភិបាល គឺ **អាជ្ញាធរទន្លេសាប** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ និងបានធ្វើការកែសម្រួលទៅលើមាត្រាមួយចំនួន តាមព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ។

ជាទូទៅអាណត្តិការងាររបស់**អាជ្ញាធរទន្លេសាប** ត្រូវបានកំណត់នៅក្នុងព្រះរាជក្រឹត្យ សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប មានន័យថា អាជ្ញាធរទន្លេសាប មានអាណត្តិការងារជាអាទិភាព ផ្តោតលើ ៖

- ការសម្របសម្រួលរាល់សកម្មភាពមកលើធនធានធម្មជាតិ ការពារ និងថែរក្សាបរិស្ថាន និងជីវ រូបសាស្ត្រនៃបឹងទន្លេសាប
- ការសម្របសម្រួលរាល់កម្មវិធី សកម្មភាពសង្គមកិច្ច និងសេដ្ឋកិច្ច រួមជាមួយនឹងទិសដៅកាត់បន្ថយភាពក្រីក្រនៅតំបន់ទន្លេសាប និងលើកកម្ពស់ការទ្រទ្រង់ជីវភាពរស់នៅប្រជាជន ។

យោងលើមាត្រាទី ៤ ជំពូកទី ៣ នៃព្រះរាជក្រឹត្យ ដែលបានចែងពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរទន្លេសាប ។ មាត្រាខាងលើនេះ បានបញ្ជាក់យ៉ាងច្បាស់ថា អាជ្ញាធរទន្លេសាប នឹងទទួលអនុវត្តន៍ទៅតាមមុខងារស្ថិតក្នុងដែនសមត្ថកិច្ចរបស់អង្គភាព រួមមាន ៖

- សេនាធិការផ្ទាល់ឲ្យរាជរដ្ឋាភិបាលលើរាល់គម្រោង ដោយធ្វើការសិក្សាស្រាវជ្រាវ ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល

- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងផ្សេងៗ
- សម្របសម្រួលរាល់សកម្មភាព ដែលកំពុងអនុវត្តន៍ គ្រោងនឹងអនុវត្តន៍ របស់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា ដែលមាននៅក្នុងតំបន់ទន្លេសាប ដើម្បីឲ្យការងារមានភាពរលូនជាមួយគ្នាប្រកបដោយប្រសិទ្ធភាព
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនានា ដើម្បីជំរុញឲ្យប្រតិបត្តិករពាក់ ព័ន្ធអនុវត្តន៍ស្របតាមយុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាល
- ធ្វើជាតំណាងរាជរដ្ឋាភិបាលក្នុងសកម្មភាពការងាររួមមាន កិច្ចប្រជុំ ការចរចា និងការដោះស្រាយរាល់បញ្ហា ដែលអាចកើតមានជាយថាហេតុ
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ កិច្ចសន្យាទាំងឡាយ ក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាល
- ជាសមភាគីជាមួយគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ក្នុងការរួមគ្នាពិចារណា ដើម្បីកំណត់សកម្មភាពដែលត្រូវអនុវត្តន៍
- ប្រមូល វិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យ ដើម្បីផ្សព្វផ្សាយ និងចែករំលែកដល់អ្នកពាក់ព័ន្ធ
- អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធ
- រាយការណ៍ជូនរាជរដ្ឋាភិបាល អំពីសកម្មភាពការងារសំខាន់ៗ
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

នៅក្នុងមាត្រាទី ៨ អាជ្ញាធរទន្លេសាប ក៏បានតម្រូវឲ្យមានការកោះប្រជុំសាមញ្ញជារៀងរាល់ ៣ ខែម្តងនៃគណៈកម្មាធិការប្រតិបត្តិរបស់អាជ្ញាធរទន្លេសាប ។

ជាមួយនឹងខ្លឹមសាររបស់ព្រះរាជក្រឹត្យ បង្កើតអាជ្ញាធរទន្លេសាប បានកំណត់ច្បាស់ពីតួនាទីចម្បងរបស់ អាជ្ញាធរទន្លេសាប គឺពង្រឹងនូវការសម្របសម្រួលនៅតំបន់ទន្លេសាប ដោយតាមដានត្រួតពិនិត្យ និងវាយតម្លៃ រាល់គម្រោង និងសកម្មភាពនានា ។ ដោយយោងមាត្រាទី ៤ ក៏ដូចជាមានចែងនៅក្នុងលេខាធិការដ្ឋានផងដែរ អាជ្ញាធរទន្លេសាប នឹងមានតួនាទីដោយផ្តោតទៅនឹងគម្រោង ដូចខាងក្រោម ៖

1. ជាអង្គភាពសិក្សាស្រាវជ្រាវ តាមដាន និងវាយតម្លៃ អំពីសក្តានុពលសេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ដើម្បីរៀបចំឡើងនូវផែនទីបង្ហាញផ្លូវ (ផែនការមេ) ទស្សនវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ សម្រាប់ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។
2. ជាដៃគូ ដើម្បីជួយសម្របសម្រួលក្នុងដំណើរការគម្រោង ដែលគួរបន្តអនុវត្តន៍ក្នុងតំបន់ទន្លេសាប

3. តាមដានត្រួតពិនិត្យការអនុវត្តគម្រោងកំពុងអនុវត្តន៍ ដើម្បីធានាថាការអនុវត្តបានបំពេញរាល់ទិសដៅ និងកម្មវិធីនៃការអនុវត្ត
4. វាយតម្លៃការអនុវត្តគម្រោង ដែលត្រូវបានបញ្ចប់ ដើម្បីពិនិត្យពីភាពជោគជ័យរបស់គម្រោងជាមួយនឹងគោលដៅដែលចង់បាន

ផ្អែកលើឯកសារបទបញ្ញត្តិ អាជ្ញាធរទន្លេសាប មិនមែនជាអង្គភាពដែលដើរតួនាទីជា អង្គការអាងទន្លេ River Basin Organization (RBO) ដែលពាក់ព័ន្ធនឹងវិស័យទឹកផ្ទាល់នោះទេ គឺជាអង្គភាព ប្រមូលផ្តុំនូវ ព័ត៌មាន ទិន្នន័យតាមរយៈការសិក្សាស្រាវជ្រាវ រៀបចំកសាងផែនការ និងតាមដានត្រួតពិនិត្យរាល់ការទទួលខុសត្រូវ ដែលកំពុងប្រតិបត្តិក្នុងតំបន់ទន្លេសាប ។

## ៣.១.២. រចនាសម្ព័ន្ធ និងអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាប ត្រូវបានដឹកនាំដោយប្រធានមួយរូប ដែលបច្ចុប្បន្នជា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងមានអនុប្រធានចំនួន ២ រូប និងសមាជិកចំនួន ៣១ រូប ដែលមានឋានៈជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ តំណាងមកពីក្រសួងស្ថាប័ន ព្រមជាមួយនឹងអភិបាល នៃគណៈអភិបាលខេត្តទាំង ៨ ស្ថិតក្នុងដែនសមត្ថកិច្ចប្រតិបត្តិតំបន់ទន្លេសាប ។

យោងមាត្រាទី ៧ នៃព្រះរាជក្រឹត្យ បានចែងច្បាស់ថា អាជ្ញាធរទន្លេសាប មានអគ្គលេខាធិការដ្ឋានមួយ សម្រាប់ដំណើរការការងារប្រចាំថ្ងៃ និងចាត់ការទូទៅលើការងារ សម្របសម្រួល ទំនាក់ទំនង និងសហការរវាងក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយនិរន្តរភាព ។ បច្ចុប្បន្នលេខាធិការដ្ឋានរបស់អាជ្ញាធរទន្លេសាប ត្រូវបានដឹកនាំដោយ អគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងចំនួន ៣ រូប និងមាននាយកដ្ឋានចំនួន ៤ ព្រមជាមួយនឹងការិយាល័យចំនួន ១៤ ដូចមានក្នុងរចនាសម្ព័ន្ធខាងក្រោម ៖

រចនាសម្ព័ន្ធអាជ្ញាធរទន្លេសាប




## ៣.១.៣. វិសាលភាពអនុវត្តន៍ការងាររបស់អាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាប នឹងប្រតិបត្តិសកម្មភាពការងារអាស្រ័យនឹងវិសាលភាពដែនសមត្ថកិច្ចការងារ ដែលបានកំណត់ច្បាស់លាស់នៅក្នុងព្រះរាជក្រឹត្យបង្កើត **អាជ្ញាធរទន្លេសាប** បើទោះជាការកំណត់វិសាលភាពព្រំប្រទល់នៃតំបន់ទន្លេសាប នៅមិនទាន់បានរៀបចំ និងអនុម័តជាផ្លូវការនៅឡើយ ដូចមានចែងក្នុងមាត្រា ២ ។ សកម្មភាពប្រតិបត្តិការងារ ត្រូវបានអនុវត្តន៍គ្របដណ្ដប់ទៅលើដែនដីនៃខេត្តទាំង ៨ ជុំវិញតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធនៃខេត្តមួយចំនួនទៀត ដែលស្ថិតក្នុងដែនផ្ទៃរងទឹកភ្លៀង (Watershed Boundaries) ដែលភ្ជាប់តាមរយៈធនធានទឹក និងធនធានធម្មជាតិ ពឹងផ្អែកទៅនឹងប្រភពទឹក ។

ដូចបានកំណត់យ៉ាងច្បាស់នៅក្នុងអាណត្តិការងាររបស់អាជ្ញាធរទន្លេសាប គឺជាអង្គភាពសម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ហើយត្រូវបានចែងពីតួនាទី និងភារកិច្ចនៅក្នុងមាត្រាទី ៤ នៃព្រះរាជក្រឹត្យ ។ អាជ្ញាធរទន្លេសាប ត្រូវកំណត់អំពីសកម្មភាពមួយចំនួន ក្នុងការគាំទ្រដល់ភារកិច្ចចម្បងៗ ដូចជា ៖

- រៀបចំបង្កើត និងសម្របសម្រួលទិន្នន័យ ព័ត៌មាន ស្ដីពីតំបន់ទន្លេសាប
- សិក្សាស្រាវជ្រាវ តាមដាន និងវាយតម្លៃ អំពីសក្ដានុពលសេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រៀបចំបង្កើតឡើងនូវជំនាញបច្ចេកទេស ដែលពាក់ព័ន្ធ ។

ស្របតាមព្រះរាជក្រឹត្យ ដែលបានកំណត់ពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរទន្លេសាប និងក្នុងស្មារតីយកចិត្តទុកដាក់ជម្រុញនូវកិច្ចការការពារធនធានធម្មជាតិ និងជីវៈចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា នៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយនិរន្តរភាព ។ អាជ្ញាធរទន្លេសាប បានខិតខំយកចិត្តទុកដាក់អនុវត្តន៍ការងារតាមរយៈនៃការចុះសិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យនូវរាល់សកម្មភាពបទល្មើស និងភាពអនាធិបតេយ្យមកលើធនធានជលផល ព្រៃលិចទឹក ជីវៈចម្រុះ នៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ក្រោមកិច្ចសហការនិងសម្របសម្រួលជាមួយនឹងបណ្តាក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ការចុះអនុវត្តន៍ការងារប្រកបដោយភាពជោគជ័យជាប្រវត្តិសាស្ត្ររបស់អាជ្ញាធរទន្លេសាប ស្របតាមបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ បប ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ២០១០ ក្នុងការចាត់វិធានការ និងការការពារធនធានធម្មជាតិតំបន់បឹងទន្លេសាប រហូតដល់កំណត់បែងចែកជាតំបន់ការពារ ៣ តំបន់ រួមមាន ៖

- តំបន់ការពារទី ០១ ៖ ជាតំបន់លំនៅដ្ឋាន និងស្រែចំការរបស់ប្រជាកសិករ និងជាតំបន់លិចទឹកតិចតួចនៅរដូវវស្សា នៅតាមបណ្តោយផ្លូវជាតិលេខ ៥ និងផ្លូវជាតិលេខ ៦
- តំបន់ការពារទី ០២ ៖ ជាតំបន់ទ្រនាប់ចន្លោះតំបន់ការពារទី ០១ និងតំបន់ការពារទី ០៣ ជាតំបន់វាលស្មៅ ព្រៃគុម្ពោធ និងដីស្រែដែលកសិករធ្វើស្រែប្រាំងប្រជេញទឹក ។ តំបន់នេះនៅរដូវ វស្សាមានការលិចទឹកជាទូទៅរហូតដល់កម្ពស់ពី ៣ ម ទៅ ៤ ម ។
- តំបន់ការពារទី ០៣ ៖ ជាតំបន់ការពារដាច់ខាត ប្រកបទៅដោយព្រៃលិចទឹក និងតំបន់វាលស្មៅលិចទឹក និងតំបន់ដីសើម ដែលគ្របដណ្តប់លើផ្ទៃដីចំនួន ៦៤៧.៤០៦ ហិកតា រួមជាមួយនឹងនិយាមការប្បាស់លាស់ចំនួន ៨០២ ចំនុច ស្ថិតក្នុងខេត្តទាំង ០៦ ជុំវិញបឹងទន្លេសាប ដូចមានចែងក្នុងអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១ ស្តីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧.៤០៦ ហិកតា ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេ សាប (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ) ។

ជាមួយនឹងស្មារតីចូលរួមអនុវត្តន៍គោលនយោបាយកំណែទម្រង់វិស័យជលផល របស់រាជរដ្ឋាភិបាល ដើម្បីជំរុញការគ្រប់គ្រង និងការអភិវឌ្ឍវិស័យជលផល ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើស្ទួយសេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមច្ឆាជាតិនៅក្នុងតំបន់បឹងទន្លេសាប និងជីវៈចម្រុះផ្សេងៗទៀតឲ្យបានសម្បូរឡើងវិញ ។ អាជ្ញាធរទន្លេសាប បានដើរតួនាទីយ៉ាងសំខាន់ក្នុងការខិតខំអនុវត្តន៍ការងាររបស់ខ្លួនប្រកបដោយការយកចិត្តទុកដាក់ តាមរយៈការសិក្សាស្រាវជ្រាវអំពីបទល្មើស និងភាពអនាធិបតេយ្យនៅតំបន់ទន្លេសាប និងបានស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល ក្នុងគំនិតផ្តួចផ្តើមថែរក្សាការពារ និងការប្រើប្រាស់ធនធានមច្ឆាជាតិប្រកបដោយនិរន្តរភាព ដែលឈានទៅដល់ការលុបបំបាត់នូវបទល្មើស និងភាពអនាធិបតេយ្យក្នុងការធ្វើអាជីវកម្មហួសកម្រិតមកលើធនធានជលផលនៅតំបន់បឹងទន្លេសាប ។

តាមរយៈបទបញ្ជាលេខ ០១ បប របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ស្ដីពីការចាត់វិធានការលុបបំបាត់ភាពអនាធិបតេយ្យ នៃការដាក់សម្រះ ធ្នស់ ព្រួល និងសំណង់កាត់ទទឹងទន្លេស្ទឹង ព្រែក អូរ និងបឹងបួរ នៅតាមបណ្ដាខេត្តពាក់ព័ន្ធនឹងបឹងទន្លេសាប ។ អាជ្ញាធរទន្លេសាប បានខិតខំប្រឹងប្រែងចូលរួមអនុវត្តន៍ការងារជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងកម្រិតជាតិ និងថ្នាក់ក្រោមជាតិ រហូតដល់សម្រេចបានជោគជ័យនូវកម្មវិធីកំណែទម្រង់វិស័យជលផល នៅក្នុងតំបន់ពាក់ព័ន្ធនឹងបឹងទន្លេសាប ដូចមានចែងក្នុងអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០១២ ស្ដីពីការលុបឡូត៍នេសាទជុំវិញបឹងទន្លេសាប ក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ធំ ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងជាកន្លែងអភិរក្សជលផល ។

ដើម្បីបន្តពង្រឹងការអនុវត្តបេសកកម្មស្នូលរបស់អាជ្ញាធរទន្លេសាប ក្នុងតួនាទីសិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ និងវាយតម្លៃ អំពីសក្ដានុពលសេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិ ព្រមជាមួយនឹងការចុះអធិការកិច្ច តាមដាននូវរាល់សកម្មភាពបទល្មើស និងភាពអនាធិបតេយ្យនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ។ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំឡើងនូវផែនការសកម្មភាពការងារលើកទី ០១ (២០១៤-២០១៦) និងផែនការសកម្មភាពលើកទី ០២ (២០១៥-២០១៧) ដើម្បីអនុវត្តន៍សកម្មភាពការងារប្រចាំឆ្នាំ ។ ផែនការសកម្មភាពការងារនេះ ឆ្លុះបញ្ចាំងអំពីសកម្មភាពសំខាន់ៗក្នុងការចុះអនុវត្តការងារ ប្រមូលចងក្រងព័ត៌មាន-ទិន្នន័យ ដើម្បីចូលរួមចំណែកជួយលើកកម្ពស់ដល់ការគ្រប់គ្រង អភិរក្ស អភិវឌ្ឍន៍តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយចិរភាព ហើយដែលត្រូវបានរៀបចំឡើងដោយបានកំណត់នូវសកម្មភាពការងារអាទិភាពរបស់នាយកដ្ឋានក្រោមឱវាទ ក្នុងការអនុវត្តសម្រេចឲ្យបាននូវគោលបំណងលទ្ធផល (Outcome) និងជាតុចេញ (Output) រួមរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។ សកម្មភាពចុះអនុវត្តការងារសំខាន់ៗ រួមមាន ៖

- ✓ ការចុះអធិការកិច្ច អំពីវិនាសកម្មព្រៃលិចទឹកតំបន់ជុំវិញបឹងទន្លេសាប
- ✓ ការចុះតាមដានត្រួតពិនិត្យភាពអនាធិបតេយ្យ និងបទល្មើសក្នុងការធ្វើអាជីវកម្មភាពហួសហេតុ និងខុសច្បាស់មកលើធនធានធម្មជាតិ និងធនធានជលផល
- ✓ ការតាមដាន និងវាយតម្លៃពីផលចាប់ប្រចាំថ្ងៃជុំវិញបឹងទន្លេសាប
- ✓ ការតាមដាន និងវាយតម្លៃពីការធ្វើអាជីវកម្មកែច្នៃប្រហុក និងសិប្បកម្មនានា
- ✓ ការតាមដាន អំពីការគ្រប់គ្រងតំបន់សហគមន៍នេសាទ នៃតំបន់អភិរក្សជលផល
- ✓ ការតាមដាន អំពីការគ្រប់កាកសំណល់រឹងរាវ នៅតំបន់ទន្លេសាប
- ✓ ការចុះសិក្សាស្រាវជ្រាវ ប្រមូលព័ត៌មានទិន្នន័យ ដែលពាក់ព័ន្ធនឹងសក្ដានុពលសេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិ និងជីវៈចម្រុះនៅតំបន់បឹងទន្លេសាប
- ✓ ការប្រមូលចងក្រងព័ត៌មាន ទិន្នន័យរាល់គម្រោង ដែលបាននឹងកំពុងអនុវត្តន៍ដោយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនៅតំបន់ទន្លេសាប
- ✓ ការចូលរួមលើកកម្ពស់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ✓ ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធនានា

## ៣.២. ចក្ខុវិស័យ (Vision)

ការកំណត់នូវចក្ខុវិស័យនៅក្នុងផែនការយុទ្ធសាស្ត្រ របស់អាជ្ញាធរទន្លេសាប តម្រូវឲ្យអត្ថន័យ ខ្លឹមសារស្របជាមួយនឹងអាណត្តិ និងតួនាទីភារកិច្ច ដែលកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើត **អាជ្ញាធរទន្លេសាប** ។

**" ស្ថាប័ន/អង្គភាពគំរូមួយ ដែលអាចសម្រេចបានដោយជោគជ័យក្នុងការសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចិរភាពក្នុងតំបន់ទន្លេសាប"**

តម្រូវការចាំបាច់បង្កើនប្រសិទ្ធភាពការសម្របសម្រួល នៅតំបន់ទន្លេសាប ដែលកើតឡើងគ្រប់ទិដ្ឋភាព សកម្មភាព ដែលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះរបស់បឹង ។ ជាក់ស្តែងបច្ចុប្បន្ន បឹងទន្លេសាប ត្រូវបានទទួលរងនូវការគម្រាមកំហែងតាមរយៈកត្តាខាងក្រៅប្រទេស (ការអភិវឌ្ឍផ្នែកខាងលើទន្លេមេគង្គ) និងកត្តាខាងក្នុងអាងទន្លេ (ការអភិវឌ្ឍទាញយកទឹកប្រើប្រាស់នៅតាមដៃទន្លេ ហូរចាក់មកក្នុងបឹង) ។

ការសម្របសម្រួល ត្រូវបានពិនិត្យដោយយកចិត្តទុកដាក់ដោយអាជ្ញាធរទន្លេសាប និងការរៀបចំនូវរាល់កិច្ចប្រជុំពិភាក្សា និងមុខងាររបស់លេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ។ ការជំរុញឲ្យមានការពិភាក្សាផ្លាស់ប្តូរយោបល់គ្នា ក្នុងចំណោមដៃគូដែលមានក្នុងរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលពាក់ព័ន្ធនឹងតំបន់ទន្លេសាប ។ ការសម្របសម្រួល ក៏បានបញ្ជាក់ពីការគាំទ្របច្ចេកទេស សម្រាប់ការរៀបចំកសាងគម្រោង និងការរៀបចំឯកសារកម្មវិធីសម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ។ ការទំនាក់ទំនង និងការរស់នៅរបស់ប្រជាជននៅក្នុងតំបន់បឹងទន្លេសាប រួមជាមួយនឹងដៃគូពាក់ព័ន្ធនានា ត្រូវរៀបចំគ្រប់គ្រងឲ្យបានច្បាស់លាស់ ដែលជាសកម្មភាពមិនអាចជៀសវាងបានក្នុងបរិបទសម្របសម្រួល ។ វាជាកត្តាចាំបាច់បំផុត ក្នុងប្រមូលផ្តុំចងក្រងជាបណ្តាញការងារសម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ដើម្បីជំរុញប្រសិទ្ធភាពដំណើរការការងារ តាមរយៈការចែករំលែកនូវបទពិសោធន៍ ។ ដើម្បីជានាឲ្យការសម្របសម្រួលប្រកបដោយ ប្រសិទ្ធភាព គឺតម្រូវឲ្យមានការកសាងសមត្ថភាពក្នុងការផ្តល់ជាផ្នែករដ្ឋបាល បទបញ្ញាតិ និងជំនួយបច្ចេកទេស ទៅលើគ្រប់វិស័យក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ។

ប្រសិទ្ធភាព នៃការសម្របសម្រួល របស់អាជ្ញាធរទន្លេសាប ត្រូវយកមកអនុវត្តន៍មានដូចខាងក្រោម ៖

1. លើកម្មវិធីសេដ្ឋកិច្ច និងសង្គមកិច្ច ក្នុងទិសដៅលើកកម្ពស់ប្រសិទ្ធភាពដល់ការទ្រទ្រង់ជីវភាពរស់នៅ និងស្ថានភាពហិរញ្ញវត្ថុរបស់ប្រជាជននៅតំបន់ទន្លេសាប
2. លើកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន ក្នុងទិសដៅជានាឲ្យបានដល់ប្រយោជន៍ធនធាន និង បរិស្ថាន ត្រូវបានការពារថែរក្សា និងមិនឲ្យវិនាសហិនហោច ។

## ៣.៣. បេសកកម្ម

ដូចបានកំណត់ច្បាស់ពីអាណត្តិការងាររបស់អាជ្ញាធរទន្លេសាប **សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប** និងត្រូវបានចែងក្នុងមាត្រាទី ៤ អំពីតួនាទីភារកិច្ច ក្នុងព្រះរាជក្រឹត្យ ។ ហេតុនេះបេសកកម្ម សម្រាប់កំណត់ពីអាណត្តិការងាររបស់អាជ្ញាធរទន្លេសាប និងចូលរួមគាំទ្រដល់ចក្ខុវិស័យ គឺ ៖

**" គាំទ្រដល់ការអភិវឌ្ឍ និងកិច្ចដំណើរការដ៏សមស្រប ក្នុងការសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប "**

ជាមួយនឹងបេសកកម្ម សម្រាប់ដំណើរការផែនការយុទ្ធសាស្ត្រ ត្រូវបានពិចារណាដោយយកចិត្តទុកដាក់ទៅលើទិសដៅសំខាន់ៗក្នុងស្ថានភាពការងាររបស់អាជ្ញាធរទន្លេសាប ។ ជាក់ស្តែង រាល់ការអនុវត្តរួមគ្នា នៃគម្រោងអភិវឌ្ឍន៍ និងសកម្មភាពការងារផ្សេងៗទៀត ត្រូវកំណត់ឲ្យបានច្បាស់នៅក្នុងកិច្ចព្រមព្រៀង និងលក្ខន្តិកៈ ដែលកំណត់សេចក្តី "ការចែករំលែកអត្ថប្រយោជន៍ប្រកបដោយសមធម៌" ។ ក្នុងទិសដៅការងារយូរអង្វែង តាមរយៈនៃការចែករំលែកអត្ថប្រយោជន៍ប្រកបដោយសមធម៌នេះ អាជ្ញាធរទន្លេសាប នឹងកំណត់បាននូវកាលានុវត្តភាព ឆ្ពោះទៅសម្រេចឲ្យបាននូវតុល្យភាពសង្គម សេដ្ឋកិច្ច និងបរិស្ថាន ក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រ ។ ការជំរុញប្រសិទ្ធភាពបេសកកម្ម ក្នុងការគាំទ្រដល់ដំណើរការផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរ ទន្លេសាប រួមមាន ៖

1. ពង្រឹងប្រសិទ្ធភាព និងសម្របសម្រួលរាល់ព័ត៌មាន ដែលកើតឡើងនូវតំបន់ទន្លេសាប
2. ចុះសិក្សាស្រាវជ្រាវ ប្រមូលព័ត៌មាន ទិន្នន័យនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
3. រៀបចំបង្កើត និងផ្សព្វផ្សាយនូវជំនាញបច្ចេកទេស ដែលពាក់ព័ន្ធ

### ៣.៤. គុណប្រយោជន៍គន្លឹះ

គុណប្រយោជន៍ សម្រាប់ភាពជោគជ័យនៃដំណើរការកសាង និងអនុវត្តន៍នូវផែនការយុទ្ធសាស្ត្រ ក្នុង ការសម្រេចឲ្យបាននូវចក្ខុវិស័យ និងបេសកកម្មខាងលើ តម្រូវឲ្យអ្នកពាក់ព័ន្ធ ត្រូវ ៖

- តម្លាភាព
- ការងារជាក្រុម (សហការ និងផ្លាស់ប្តូរគំនិតយោបល់)
- គោរពគ្នាទៅវិញទៅមក
- អភិបាលកិច្ចល្អ
- សមធម៌យេនឌ័រ និងសង្គមកិច្ច
- ប្រសិទ្ធភាពការងារ

## ៤. ការវិភាគចំនុចខ្លាំង ខ្សោយ កាលនុវត្តភាព និងភាពប្រឈម (SWOT)

ដើម្បីសម្រេចឲ្យបានជោគជ័យនូវអាណត្តិការងារ និងបេសកកម្មរបស់អាជ្ញាធរទន្លេសាប ជាសំខាន់ត្រូវវិភាគទៅលើចំនុចខ្លាំង ចំនុចខ្សោយ កាលានុវត្តភាព និងភាពប្រឈម (SWOT) របស់អាជ្ញាធរទន្លេសាប ។ វាជាការចាំបាច់បំផុត ដើម្បីកំណត់ឲ្យឃើញពីកាលានុវត្តភាព ដែលបញ្ជាក់ពីចំនុចខ្លាំងរបស់អាជ្ញាធរទន្លេសាប ត្រូវបានយកមកអនុវត្តន៍ សម្រាប់ជាអត្ថប្រយោជន៍ក្នុងកម្រិតអតិបរិមា ដើម្បីគ្រប់គ្រងឲ្យបាននូវឧបសគ្គ និងបញ្ហាប្រឈមនានា ។ ជាងនេះទៅទៀត ភាពខ្សោយ គឺបង្ហាញពីចន្លោះប្រហោង ដែលតម្រូវឲ្យបំពេញ ប្រសិន បើអាជ្ញាធរទន្លេសាប យកចិត្តទុកដាក់ចាប់យកនូវកាលានុវត្តភាពនានា ។ ការប្រកួតប្រជែងទាញយកនូវធន ធានប្រើប្រាស់ តម្រូវឲ្យអាជ្ញាធរទន្លេសាប យកចិត្តទុកដាក់កំណត់វិសាលភាពអនុវត្តន៍សកម្មភាពការងារ ដើម្បីពង្រឹងប្រសិទ្ធភាពការប្រតិបត្តិ ។ ដើម្បីសម្រេចបានដោយជោគជ័យ តម្រូវឲ្យផែនការយុទ្ធសាស្ត្រ ដែលផ្តល់ជា ផែនទីបង្ហាញផ្លូវ សម្រាប់អាជ្ញាធរទន្លេសាប ផ្អែកលើការវិភាគ

ចំនុចខ្លាំង ចំនុចខ្សោយ កាលានុវត្តភាព និងភាពប្រឈម (SWOT) ព្រមជាមួយនឹងបញ្ហា ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី និងការប្រើប្រាស់ទឹកនៅក្នុងតំបន់ទន្លេសាបសម្រាប់ជាមូលដ្ឋានគ្រឹះ ក្នុងការកំណត់តំបន់អាទិភាពសម្រាប់អនុវត្តន៍សកម្មភាព ។ លទ្ធផលជាតុចេញ (Output) នៃការវិភាគចំនុចខ្លាំង ចំនុចខ្សោយ កាលានុវត្តភាព និងភាពប្រឈម (SWOT) ត្រូវបានរៀបចំដូចមានក្នុងតារាង ទី ០១ ខាងក្រោម ៖

# តារាងសង្ខេបចំនុចខ្លាំង ចំនុចខ្សោយ កាលានុវត្តភាព និងភាពប្រឈមរបស់អាជ្ញាធរទន្លេសាប

| ចំនុចខ្លាំង | ចំនុចខ្សោយ | កាលានុវត្តភាព | ភាពប្រឈម |
|---|---|---|---|
| អាជ្ញាធរទន្លេសាប បង្កើតឡើងដោយព្រះរាជក្រឹត្យ មានបេសកកម្មការងារ សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប | ក្រសួង ស្ថាប័នទាំង ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងដៃគូបច្ចេកទេសអន្តរជាតិ នៅមិនទាន់ការយល់ច្បាស់ពី តួនាទី ភារកិច្ច របស់អាជ្ញាធរទន្លេសាប | បន្តយកចិត្តទុកដាក់បញ្ជ្រាបការយល់ដឹងជាសកល និងបង្កើនទំនាក់ទំនងជាមួយនឹងក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីឲ្យយល់ច្បាស់ពីតួនាទី និងបេសកកម្មការងាររបស់អាជ្ញាធរទន្លេសាប<br>បន្តជម្រុញការអនុវត្តសកម្មភាពការងារឲ្យមានប្រសិទ្ធភាព តាមការកំណត់ពីតួនាទី និងភារកិច្ច ក្នុងព្រះរាជក្រឹត្យ និងអនុក្រឹត្យ | តួនាទី និងភារកិច្ចរបស់អាជ្ញាធរទន្លេសាប គឺជាការបន្ថែម ទៅនឹងការងារទទួលខុសត្រូវដែលមានស្រាប់របស់ ក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| ការទទួលស្គាល់ និងគាំទ្រក្នុងការបង្កើតឲ្យមានអាជ្ញាធរទន្លេសាប ក្នុងការសម្របសម្រួល រាល់សកម្មភាព/គម្រោងអនុវត្តនៅតំបន់ទន្លេសាប ពីថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូហិរញ្ញវត្ថុជាតិ និងអន្តរជាតិ | ភាគច្រើននៃសកម្មភាព និងកម្មវិធីគម្រោងបាននឹងកំពុងអនុវត្តក្នុងតំបន់ទន្លេសាប មិនបានជូនព័ត៌មាន/ផ្តល់របាយការណ៍ និងមិនមានការប្រឹក្សាយោបល់ជាមួយនឹងអាជ្ញាធរទន្លេសាប ក្នុងកិច្ចសហប្រតិបត្តិការ | រៀបចំកសាងផែនការ និងក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់តំបន់ទន្លេសាប ក្នុងក្របខ័ណ្ឌសម្របសម្រួល និងគ្រប់គ្រងនូវរាល់សកម្មភាពសំខាន់ៗដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចសង្គម ធនធានធម្មជាតិ និងបរិស្ថាន | ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនីមួយៗ មិនទាន់មានសុខដុមនីយកម្មនឹងគ្នា ទៅលើការអនុវត្តគម្រោង/កម្មវិធីរួមគ្នា ហើយការដោះស្រាយបញ្ហា ត្រូវធ្វើការសម្រេចពីកម្រិតថ្នាក់ដឹកនាំកំពូល |
| សញ្ញាណនិមិត្តរូប និងវិសាលភាពការងារទទួលខុសត្រូវ ត្រូវបានទទួលស្គាល់ជាទូទៅក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ និងកម្រិតអន្តរជាតិ | ដែនវិសាលភាពតំបន់ទន្លេសាប មិនទាន់ត្រូវបានកំណត់ច្បាស់លាស់<br>សមាសភាពសមាជិកនៃក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ មិនទាន់ត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញ<br>គណៈកម្មាធិការប្រតិបត្តិ មិនទាន់ដំណើរការបានល្អនៅឡើយទៅតាមការងារដែលបានចែងក្នុងព្រះរាជក្រឹត្យ។ | ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងធនធានទឹក និងឧតុនិយម (គណៈកម្មាធិការថ្នាក់ជាតិអាងទន្លេ) ដើម្បីកំណត់ដែនវិសាលភាពតំបន់ទន្លេសាប<br>រៀបចំបច្ចុប្បន្នភាពសមាភាពសមាជិកឡើងវិញ និងបន្តពង្រឹងដំណើរការការងារក្នុងកិច្ចប្រតិបត្តិជាប្រចាំរបស់គណៈកម្មាធិការប្រតិបត្តិ | កង្វះខាតមូលដ្ឋានទិន្នន័យ និងការផ្តល់កិច្ចសហប្រតិបត្តិការពីក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធនៅមានកម្រិត |
| ជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាល ធ្វើការសិក្សាស្រាវជ្រាវ ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ ដើម្បីសម្របសម្រួល ក្នុងការគ្រប់គ្រង អភិរក្ស | ការចូលរួមសហការពីក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ រួមជាមួយនឹងថ្នាក់តំបន់ នៅមានកម្រិត ក្នុងការចែករំលែកព័ត៌មាន | បន្តពង្រឹងការសិក្សាស្រាវជ្រាវ និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រសួង ស្ថាប័ន ដៃគូភាគីពាក់ព័ន្ធ ក្នុងការប្រមូលចងក្រង ចែករំលែកនិងផ្សព្វផ្សាយរាល់ព័ត៌មាន ទិន្នន័យ ដែលពាក់ព័ន្ធ សក្តានុពល និងផលប៉ះពាល់ដល់ | ការប្រមូលទិន្នន័យ ការវិភាគ និងធ្វើបច្ចុប្បន្នភាពនៅមានកម្រិត។ |

| | | | |
|---|---|---|---|
| និងអភិវឌ្ឍន៍តំបន់ទន្លេសាប | ទិន្នន័យ | តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | |
| កិច្ចសហការ ជាមួយអន្តរក្រសួងស្ថាប័ន ដែលជាសមាជិកទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈគម្រោង និងកម្មវិធីថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ | ធនធានមនុស្ស ទាំងជំនាញសម្របសម្រួល និងបច្ចេកទេស នៅមានកម្រិតនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ | បញ្ជ្រាបសកម្មភាពបណ្តុះបណ្តាល ការផ្ទេរចំណេះដឹង ចូលក្នុងកម្មវិធីកសាងសមត្ថភាពថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដើម្បីផ្តល់កាលានុវត្តភាពបន្ថែមដល់មន្ត្រី ក្នុងការធ្វើសមាហរណកម្មសកម្មភាព/គម្រោង រួមជាមួយនឹងការពង្រឹងភាពជាដៃគូ តាមរយៈការអនុវត្តគម្រោង/កម្មវិធីកិច្ចសហប្រតិបត្តិការ ។ | ការផ្តល់កិច្ចសហការមិនទាន់បានរលូន ដោយធ្វើឲ្យបាត់បង់នូវកាលានុវត្តភាពរបស់ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធដែលធ្លាប់អនុវត្តកន្លងមក ។ |
| លទ្ធភាពដើម្បីទាក់ទាញ/ប្រមូលផ្តុំកៀរគរមូលនិធិដើម្បីបំពេញបេសកកម្មការងារ | ការកំណត់ទិសដៅក្នុងផែនការយុទ្ធសាស្ត្រកន្លងមក មិនទាន់ច្បាស់លាស់ ។<br>ការយល់ដឹងរបស់មន្ត្រីនៅមានកម្រិត | បញ្ជ្រាបបកម្មវិធី/គម្រោងអាទិភាព ក្នុងផែនការយុទ្ធសាស្ត្រថវិកាតាមកម្មវិធី និងកម្មវិធីវិនិយោគសាធារណៈ និងផែនការថ្នាក់តំបន់ (NIP-CNMC/MRC, GMS, ASEAN ) ក្នុងការស្វែងរកដៃគូអភិវឌ្ឍន៍ និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្ត | គម្រោង/កម្មវិធី ស្នើឡើង មិនចំចំណុចដៅនៃផែនការ និងខុសតំបន់គោលដៅ ដែលដៃគូអភិវឌ្ឍន៍ចង់បាន |
| សម្របសម្រួលរាល់សកម្មភាព និងកម្មវិធី/គម្រោងកំពុងអនុវត្ត និងគ្រោងអនុវត្តក្នុងតំបន់ទន្លេសាប | ចំណេះដឹង និងការយល់ដឹងជាមូលដ្ឋាននៃជំនាញតាមដានត្រួតពិនិត្យ និងវាយតម្លៃនៅមានកម្រិត ។ ម្យ៉ាងទៀត មិនមានគោលការណ៍/វិធីសាស្ត្រច្បាស់លាស់ពីរបៀប ដែលនឹងត្រូវដំណើរការអនុវត្ត | ពង្រឹងការយល់ដឹង និងសមត្ថភាពជំនាញបច្ចេកទេស ដើម្បីសម្របសម្រួលជាមួយនឹងក្រសួងស្ថាប័នជំនាញ និងភាគីពាក់ព័ន្ធផ្សេងៗ ក្នុងការត្រួតពិនិត្យ និងវាយតម្លៃហេតុប៉ះពាល់នៃការអភិវឌ្ឍដែលបានស្នើឡើងទាំងប្រយោជន៍ធនធានធម្មជាតិ បរិស្ថាន និងសេដ្ឋកិច្ចសង្គម | គម្រោងធំៗជាច្រើនរបស់ក្រសួង ស្ថាប័ន និងភាគីនីមួយៗ អនុវត្តនៅតំបន់ទន្លេសាប នៅរាយប៉ាយ និងមាននីតិវិធីរៀងៗខ្លួនក្នុងការគ្រប់គ្រងគម្រោងតាមរយៈនៃតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួងស្ថាប័ន |
| អាជ្ញាធរទន្លេសាបគឺជាអង្គភាពសិក្សា ស្រាវជ្រាវ ប្រមូលទិន្នន័យ ដើម្បីធ្វើការវិភាគ និងធ្វើបច្ចុប្បន្នភាព ដែលការការសិក្សាមាន លក្ខណៈវិទ្យាសាស្ត្រស្របតាមបទដ្ឋានបច្ចេកទេស ដែលដៃគូអភិឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធទទួល ស្គាល់។ | កង្វះខាតអ្នកជំនាញ លើវិស័យធនធានជលផល ជីវៈចម្រុះ និង អ្នកឯកទេស Modeling។ | ពង្រឹងសមត្ថភាពមន្ត្រី អំពីជំនាញបច្ចេកទេសពាក់ព័ន្ធ ដោយប្រើប្រាស់ស្ថាប័ន/គ្រឹះស្ថានថ្នាក់តំបន់ និងថ្នាក់ជាតិ ដែលមានស្រាប់ ក្នុងការផ្តល់ចំណេះដឹងដល់មន្ត្រី ។<br>ជ្រើសរើសមន្ត្រីប្រកបដោយសមត្ថភាពតាមការចាំបាច់ | ការផ្តល់សហការពីក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការផ្តល់ព័ត៌មាន ទិន្នន័យ ដែលពាក់ព័ន្ធ នៅមានកម្រិត មិនបានរលូន ដោយខ្លាចបាត់បង់នូវអត្ថប្រយោជន៍ |
| ដំណើរការការងារជាប្រចាំ ស្របតាមផែនសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប | សកម្មភាពការងារតាមនាយកដ្ឋានជំនាញលើកស្នើឡើងមានចំនួនច្រើន តម្រូវថវិកាច្រើន និងអនុវត្តន៍មិនបាន | បច្ចុប្បន្នភាពផែនការសកម្មភាពការងារជាអាទិភាព ដើម្បីដាក់ចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាតាមកម្មវិធីរបស់ក្រសួងធនធានទឹក និងឧតុនិយម ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិចារណាការគាំទ្របន្តអនុវត្តន៍សកម្មភាពការងាររបស់អាជ្ញាធរទន្លេសាប | ធនធានហិរញ្ញវត្ថុ សមត្ថភាព និងចំនួនមន្ត្រីមានកម្រិត |

# ៥. ទិសដៅជាយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប

## ៥.១. សេចក្តីផ្តើម

ឆ្លងតាមលទ្ធផល នៃការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធក្នុងអង្គសិក្ខាសាលា អាជ្ញាធរទន្លេសាប បានកំណត់នូវទិសដៅការងារក្នុងរយៈពេលមធ្យមជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗ ។ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់រយៈពេល ៥ ឆ្នាំ រួមមាន ៖

- ពង្រឹងគោលនយោបាយ បទបញ្ញាតិ និងក្របខ័ណ្ឌស្ថាប័ន
- ពង្រឹងការយល់ដឹងជាមូលដ្ឋាន អំពីអាងទន្លេ
- សម្របសម្រួល ការកសាងផែនការ និងការគ្រប់គ្រង
- ទំនាក់ទំនងសហប្រតិបត្តិការ និងការកសាងសមត្ថភាពដល់អ្នកពាក់ព័ន្ធ
- កិច្ចប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព

តារាងទី ២ ខាងក្រោម បង្ហាញឲ្យឃើញពីទិសដៅជាយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ក្នុងរយៈពេល ៥ ឆ្នាំ (២០១៥-២០២០) ខាងមុខ ។ ទិសដៅជាយុទ្ធសាស្ត្រទាំងអស់នេះ គឺជាមូលដ្ឋានគ្រឹះនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រក្នុងរយៈពេលមធ្យម សម្រាប់ការធ្វើអន្តរាគមន៍ដោយអាជ្ញាធរទន្លេសាប ដែលមានទម្រង់បែបបទប្រទាក់ក្រឡាគ្នាទៅវិញទៅមក ។ ជាមួយនេះដែរ ក្របខ័ណ្ឌជាយុទ្ធសាស្ត្រសម្រាប់រយៈពេល ៥ ឆ្នាំ របស់អាជ្ញាធរទន្លេសាប មិនត្រូវបានចាត់ទុកដូចជាផែនការសកម្មភាពសម្រាប់ការគ្រប់គ្រងអាងទន្លេនោះទេ ។ ជាក់ស្តែង ឯកសារផែនការយុទ្ធសាស្ត្រនេះ បានកំណត់ច្បាស់ពីសកម្មភាពអាទិភាព ដែលអាចជួយដល់មន្ត្រីរបស់អាជ្ញាធរទន្លេសាប និងត្រូវបានចាត់ទុកជាចំណាត់អាទិភាពសម្រាប់ផែនការនាពេលអនាគត ។

ក្របខ័ណ្ឌជាយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ របស់អាជ្ញាធរទន្លេសាប គួរតែត្រូវបានចាត់ទុក ជាសេចក្តីណែនាំ សម្រាប់ប្រតិបត្តិនៅក្នុងឆ្នាំខាងមុខ ស្ថិតក្នុងកម្រិតរៀបចំចាត់ចែង បច្ចេកទេស គោលនយោបាយ និងហិរញ្ញវត្ថុ ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ក៏ជាឯកសារយុទ្ធសាស្ត្រ ដែលជាអំណះអំណាងឬជាមូលដ្ឋានដ៏សំខាន់សម្រាប់រាល់ដៃគូឬភាគីពាក់ព័ន្ធ របស់អាជ្ញាធរទន្លេសាប ដើម្បីជានា ៖

- ការយល់ដឹងជាសាធារណៈ អំពីបញ្ហាពាក់ព័ន្ធនឹងការបង្កើត **អាជ្ញាធរទន្លេសាប**
- ការទាក់ទាញការគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់អាជ្ញាធរទន្លេសាប
- ការកំណត់នូវអាទិភាពសំខាន់ៗ និងការបញ្ជៀសនូវសកម្មភាព និងកម្មវិធី/គម្រោងជាន់គ្នា តាមរយៈនៃការសម្របសម្រួល ពីអាជ្ញាធរទន្លេសាប ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រ ក៏បង្ហាញនូវចំនុចសំខាន់ៗ ដូចខាងក្រោមផងដែរ ៖

- ដៃគូ ក្នុងផ្នែកនយោបាយ ត្រូវស្ថិតក្នុងជំហរមួយ ក្នុងការតាមដានពិនិត្យ អំពីដំណើរការនៃការបង្កើត **អាជ្ញាធរទន្លេសាប** ក្នុងដែនសមត្ថកិច្ចអន្តរាគមន៍
- ដៃគូ ក្នុងផ្នែកបច្ចេកទេស ត្រូវស្ថិតក្នុងជំហរមួយ ក្នុងការបញ្ជ្រាបសកម្មភាពអន្តរាគមន៍ជាលក្ខណៈបច្ចេកទេសចូលក្នុង ផែនការអភិវឌ្ឍន៍អាងទន្លេ ស្របជាមួយនឹងសកម្មភាពផ្សេងទៀត នៅតំបន់ទន្លេសាប

- ដៃគូ ផ្នែកហិរញ្ញវត្ថុ ត្រូវស្ថិតក្នុងជំហរមួយ ក្នុងការទទួលបាននូវការយល់ដឹងច្បាស់ អំពីកម្មវិធីពេលវេលានៃការអនុវត្តសកម្មភាព និងកម្មវិធី/គម្រោងនីមួយៗរបស់អាជ្ញាធរទន្លេសាប ដែលអាចឲ្យពិចារណា ក្នុងការគាំទ្រថវិកា ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រ ត្រូវតែជាឯកសារសំខាន់ និងអាទិភាពបំផុត ដែលត្រូវចូលរួមចែករំលែកទៅដល់ក្រសួង ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ ថ្នាក់អន្តរជាតិ និងដៃគូសំខាន់ៗរបស់អាជ្ញាធរទន្លេសាប ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ក៏សំខាន់ផងដែរ សម្រាប់ជូនព័ត៌មានដល់ប្រទេសស្ថិតនៅផ្នែកខាងលើតាមដងទន្លេមេគង្គ និងតាមដៃទន្លេ ដែលមិនស្ថិតក្នុងដែនដីរដ្ឋបាល ក៏ប៉ុន្តែពាក់ព័ន្ធនឹងរបបជលវិទ្យា ដែលទទួលរបបទឹកពីទន្លេមេគង្គ ។

បេសកកម្មរបស់អាជ្ញាធរទន្លេសាប ប្រកបដោយខ្លឹមសារ អត្ថន័យពេញលេញ ប្រសិនបើទិសដៅជាយុទ្ធសាស្ត្រទាំង ៥ ខាងលើ ត្រូវបានថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធជាសមាជិក អ្នកនយោបាយ ដៃគូបច្ចេកទេស និងហិរញ្ញវត្ថុទាំងថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ទទួលនូវការយកចិត្តទុកដាក់ និងពិចារណា ដើម្បីជាប្រយោជន៍ក្នុងការចូលរួមសហប្រតិបត្តិការទៅលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ។

# តារាងទី ២ ៖ សេចក្តីសង្ខេបតារាងម៉ាទ្រីស នៃផែនការយុទ្ធសាស្ត្រ អ.ទ.ស ២០១៦-២០២០

| លទ្ធផលរំពឹងទុក | សកម្មភាព/គម្រោង | រយៈពេលកំណត់នៃការអនុវត្ត | កម្រិតអាទិភាព |
|---|---|---|---|
| **ទិសដៅទី ១. ពង្រឹងគោលនយោបាយ បទបញ្ញត្តិ និងស្ថាប័ន** | | | |
| ១. គោលនយោបាយ សម្រាប់ការណែនាំ អភិបាលកិច្ចទឹក និងសកម្មភាពការងារ អាជ្ញាធរទន្លេសាប | ១.១.លើកកម្ពស់គោលនយោបាយគ្រប់គ្រងធនធានទឹកឲ្យបានទូលំទូលាយនៅប្រទេសកម្ពុជារួមទាំងនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងនៅតំបន់ទន្លេសាប | ៥ ឆ្នាំ (២០១៦-២០២០) | មធ្យម |
| | ១.២.សម្របសម្រួលបញ្ជ្រាបផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប ក្នុងគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | ចាប់ផ្តើមនៅឆ្នាំទី ៣ (២០១៨) | មធ្យម |
| | ១.៣.សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលគោលការណ៍ការគ្រប់គ្រងធនធានទឹកចម្រុះក្នុងបទបញ្ញត្ត/ផែនការតាមវិស័យ និងជំរុញឲ្យមានសុខដុមនីយកម្មតាមការចាំបាច់ | ៥ ឆ្នាំ (២០១៦-២០២០) | មធ្យម |
| ២. បទបញ្ញត្តិអភិបាលកិច្ចទឹកត្រូវបានបង្កើតឡើងនៅតំបន់ទន្លេសាប | ២.១.សម្របសម្រួល និងប្រតិបត្តិតាម រាល់បទបញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ធនធានទឹក និងក្របខ័ណ្ឌក្នុងការគ្រប់គ្រងអាងទន្លេរបស់ព្រះរាជាណាចក្រកម្ពុជា | ៥ ឆ្នាំ (២០១៦-២០២០) | មធ្យម |
| | ២.២.កំណត់ដែនវិសាលភាពនៃតំបន់ទន្លេសាប (ព្រះរាជក្រឹត្យ មាត្រា ២) | ចាប់ផ្តើមឆ្នាំទី ១ (២០១៦) | ខ្ពស់ |
| ៣. រាល់ធាតុសំខាន់ៗផ្នែកច្បាប់បទដ្ឋានគតិយុត្ត និងតួនាទីភារកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរទន្លេសាប ត្រូវបានប្រតិបត្តិ និងបង្កើនប្រសិទ្ធភាពការងារ | ៣.១.ចាត់ចែងរៀបចំដំណើរការការងារឲ្យបានទៀងទាត់ (ប្រជុំ សិក្ខាសាលា...) ស្របតាមលក្ខន្តិកៈការងារពាក់ព័ន្ធភារកិច្ចរបស់អាជ្ញាធរទន្លេសាប | ៥ ឆ្នាំ (២០១៦-២០២០) | មធ្យម |
| | ៣.២.សម្របសម្រួល និងសហការជិតស្និតជាមួយក្រសួងស្ថាប័នជំនាញ ក្នុងការបង្កើនប្រសិទ្ធភាពការអនុវត្តច្បាប់ បទដ្ឋានគតិយុត្តពាក់ព័ន្ធការលើកកម្ពស់ការគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីតំបន់បឹងទន្លេសាប | ៥ ឆ្នាំ (២០១៦-២០២០) | មធ្យម |
| | ៣.៣.បន្តស្មារតីចូលរួមអនុវត្តន៍បទដ្ឋានគតិយុត្ត ក្នុងកិច្ចការការពារដែនព្រៃលិចទឹកជុំវិញតំបន់ទន្លេសាប (តំបន់ ៣) | ៥ ឆ្នាំ (២០១៦-២០២០) | ខ្ពស់ |
| **ទិសដៅទី ២. ពង្រឹងការយល់ដឹងជាមូលដ្ឋានអំពីការគ្រប់គ្រងទន្លេសាប** | | | |
| ៤.មូលដ្ឋានទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងធនធានធម្មជាតិតំបន់ទន្លេសាបនិងតំបន់ពាក់ព័ន្ធ ត្រូវបានពង្រឹងក្នុងការប្រមូលចងក្រង និងផ្សព្វផ្សាយ | ៤.១.សិក្សាស្រាវជ្រាវពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងធនធានធម្មជាតិតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | ៥ ឆ្នាំ (២០១៦-២០២០) | ខ្ពស់ |
| | ៤.២.រៀបចំបញ្ជីសារពើភ័ណ្ឌប្រភពធនធានទឹក ស្ថិតក្នុងក្របខ័ណ្ឌផែនការគ្រប់គ្រងអាងទន្លេនៅក្នុងតំបន់ទន្លេសាប | ចាប់ផ្តើមឆ្នាំទី ១ (២០១៦) បញ្ចប់នៅឆ្នាំទី ៣ (២០១៨) | ខ្ពស់ |
| | ៤.៣.រៀបចំបញ្ជីសារពើភ័ណ្ឌតំបន់ដីសើមជុំវិញតំបន់ទន្លេសាប | ចាប់ផ្តើមឆ្នាំទី ១ (២០១៦) បញ្ចប់នៅឆ្នាំទី ៣ (២០១៨) | ខ្ពស់ |

| | | | |
|---|---|---|---|
| ៥. ការគ្រប់គ្រង និងយន្តការចែករំលែកព័ត៌មាន និងទិន្នន័យ | ៥.១.គាំទ្រ និងសហការជាមួយក្រសួងស្ថាប័នជាតិក្នុងការពង្រឹង/បង្កើតឲ្យមានបណ្តាញទំនាក់ទំនងការងារតាមដានត្រួតពិនិត្យ អំពីផលប៉ះពាល់ទៅលើធនធានធម្មជាតិ បរិស្ថាន និងល័ក្ខខ័ណ្ឌសេដ្ឋកិចសង្គមកិច្ច | ៥ ឆ្នាំ (២០១៦-២០២០) | មធ្យម |
| | ៥.២.គាំទ្រ និងសហការជាមួយក្រសួងស្ថាប័នជាតិ ក្នុងការពង្រឹងនីតិវិធី/វិធីសាស្ត្រតាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីផលប៉ះពាល់មកលើធនធានធម្មជាតិ បរិស្ថាន និងល័ក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមកិច្ច | ៥ ឆ្នាំ (២០១៦-២០២០) | មធ្យម |
| | ៥.៣.បង្កើតវេទិកា (Platform) ចែករំលែក និងផ្សព្វផ្សាយការសិក្សាស្រាវជ្រាវពាក់ព័ន្ធសក្តានុពល និងផលប៉ះពាល់តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | ចាប់ផ្តើមឆ្នាំទី ១ និងអនុវត្តន៍ជាប្រចាំឆ្នាំ | ខ្ពស់ |
| **ទិសដៅទី ៣. សម្របសម្រួល កសាងផែនការ និងគ្រប់គ្រង** | | | |
| ៦. ការគ្រប់គ្រងប្រកបដោយចិរភាព ស្របតាមបទបញ្ញតិពាក់ព័ន្ធនឹងក្របខ័ណ្ឌការងារគ្រប់គ្រងអាងទន្លេ | ៦.១.សម្របសម្រួល និងគាំទ្រវាល់កិច្ចដំណើរការអភិវឌ្ឍប្រកបដោយចិរភាពក្នុងកិច្ចការការពារធនធានធម្មជាតិ និងបរិស្ថានតំបន់ជុំវិញបឹងទន្លេសាប | ៥ ឆ្នាំ (២០១៦-២០២០) | មធ្យម |
| | ៦.២.សម្របសម្រួលបណ្តាញការងារជាមួយថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិលើបទបញ្ញតិនៃការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងអាងទន្លេ | ចាប់ផ្តើមឆ្នាំទី ១ និងអនុវត្តន៍ជាប្រចាំ | មធ្យម |
| ៧. ការយល់ដឹង និងសម្របសម្រួលបណ្តាគម្រោងក្នុងតំបន់ទន្លេសាប | ៧.១.រៀបចំយន្តការបច្ចេកទេស អំពីនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ អំពីនីតិវិធីអនុវត្តន៍គម្រោងនីមួយៗ នៅតំបន់ទន្លេសាប | ៥ ឆ្នាំ (២០១៦-២០២០) | ខ្ពស់ |
| | ៧.២.ពង្រឹងការយល់ដឹង អំពីវិធីសាស្ត្រ និងនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់កម្មវិធី/គម្រោង | ៥ ឆ្នាំ (២០១៦-២០២០) | មធ្យម |
| ៨. ក្របខ័ណ្ឌនៃផែនការគ្រប់គ្រងតំបន់ទន្លេសាប ត្រូវបានរៀបចំ និងផ្សព្វផ្សាយ | ៨.១.របាយការណ៍/សេចក្តីអត្ថាធិប្បាយបច្ចេកទេសពីស្ថានភាពតំបន់ទន្លេសាប (State of Tonle Sap Lake) រួមមាន សេដ្ឋកិច្ចសង្គម ធនធានធម្មជាតិ និងបរិស្ថាន | ចាប់ផ្តើមឆ្នាំទី ១ និងអនុវត្តន៍ជាប្រចាំឆ្នាំ | ខ្ពស់ |
| | ៨.២.រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍/គ្រប់គ្រងតំបន់ទន្លេសាប | ចាប់ផ្តើមឆ្នាំទី ៣ (២០១៨) បញ្ចប់ឆ្នាំទី ៥ | ខ្ពស់ |
| **ទិសដៅទី ៤. ការទំនាក់ទំនង និងការកសាងសមត្ថភាពភាគីពាក់ព័ន្ធ** | | | |
| ៩. មុខងារសំខាន់របស់បឹងទន្លេសាប ត្រូវបានយល់ដឹងជាសាធារណៈ តាមរយៈការទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន | ៩.១.រៀបចំកសាង និងអនុវត្តន៍ផែនការទំនាក់ទំនង/សម្របសម្រួល ដែលយកចិត្តទុកដាក់ទាំងលក្ខណៈបច្ចេកទេស និងឧបករណ៍ក្នុងការបង្កើនការយល់ដឹងឲ្យបានទូលំទូលាយ ដូចជា ៖ ឯកសារផ្អែករឹង និងទុន ការកំណត់ដៃគូ និងបណ្តាញការងារ សម្រាប់ពង្រីកការផ្សព្វផ្សាយ | ចាប់ផ្តើមឆ្នាំទី ១ (២០១៦) បញ្ចប់ឆ្នាំទី ៣ (២០១៨) | ខ្ពស់ |

| | | | |
|---|---|---|---|
| ១០. សមត្ថភាពភាគីពាក់ព័ន្ធក្នុងការចែករំលែក និងសហាការក្នុងការអភិវឌ្ឍការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងល័ក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមកិច្ចនៃតំបន់បឹងទន្លេសាប | ១០.១.ពង្រឹងការអនុវត្តផែនការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ និងលើកកម្ពស់កសាងសមត្ថភាព | ៥ ឆ្នាំ (២០១៦-២០២០) | មធ្យម |
| | ១០.២.កំណត់ បង្កើតភាពជាដៃគូ និងបណ្តាញការងារជាមួយក្រុមអ្នកពាក់ព័ន្ធតំបន់ទន្លេសាប (ក្រុមអ្នកប្រើប្រាស់, អង្គការមិនមែនរដ្ឋាភិបាល, កសិករ, សហគមន៍...) | ត្រូវបានបញ្ចប់ក្នុងរយៈពេល ៥ឆ្នាំ | ខ្ពស់ |
| **ទិសដៅទី ៥. ការប្រតិបត្តិរបស់អាជ្ញាធរទន្លេសាប ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព** | | | |
| ១១. ប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ | ១១.១.តាមដានត្រួតពិនិត្យ និងវាយតម្លៃរាល់ក្របខ័ណ្ឌ និងរាល់សកម្មភាពការងារ ដែលអនុវត្តន៍ជាប្រចាំរួមជាមួយនឹងត្រួតពិនិត្យឡើងវិញ ពាក់កណ្តាលអាណត្តិឆ្នាំ២០១៩ | ៥ ឆ្នាំ (២០១៦-២០២០) | ខ្ពស់ |
| | ១១.២.ដឹកនាំ និងពង្រឹងនូវការអនុវត្តផែនការយុទ្ធសាស្ត្រ | ៥ ឆ្នាំ (២០១៦-២០២០) | ខ្ពស់ |
| ១២. ធនធានហិរញ្ញវត្ថុ និងដៃគូគាំទ្រដល់បេសកកម្មការងាររបស់អាជ្ញាធរទន្លេសាប | ១២.១.ពង្រឹង និងពង្រីកបណ្តាញទំនាក់ទំនងការងារជាមួយក្រុមប្រឹក្សាយោបល់នៃម្ចាស់ជំនួយ (Donor Consultative Group) ក្នុងការគាំទ្រ ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ | ចាប់ផ្តើមឆ្នាំទី ១ និងអនុវត្តន៍ជាប្រចាំ | ខ្ពស់ |
| | ១២.២.សម្របសម្រួលក្នុងតួនាទីបណ្តាញការងារអង្គការអាងទន្លេ | ចាប់ផ្តើមឆ្នាំទី១ និងអនុវត្តន៍ជាប្រចាំ | ខ្ពស់ |
| | ១២.៣.សមាហរណកម្មប្រភពថវិកា/មូលនិធិខាងក្នុងរបស់អាជ្ញាធរទន្លេសាប (ថវិការដ្ឋ, ម្ចាស់ជំនួយ, គម្រោងនានា...) | ត្រូវបានបញ្ចប់នៅឆ្នាំទី ៥ (២០២០) និងបន្តដំណើរការ | ខ្ពស់ |
| ១៣. ធនធានមនុស្ស និងនីតិវិធី រដ្ឋបាលដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពរបស់អាជ្ញាធរទន្លេសាប | ១៣.១.ជួសជុលថែទាំ គ្រឿងសង្ហារឹម និងប្រេងឥន្ធនៈ | ត្រូវបានបញ្ចប់ក្នុងរយៈពេល ៣ ឆ្នាំ | មធ្យម |
| | ១៣.២.នីតិវិធី បទបញ្ជាផ្ទៃក្នុង សម្រាប់ដំណើរការងារប្រចាំ | | មធ្យម |
| | ១៣.៣.ជ្រើសរើសមន្ត្រីប្រកបដោយសមត្ថភាព តាមការចាំបាច់ | ពិនិត្យតាមតម្រូវការចាំបាច់ក្នុងឆ្នាំ | ខ្ពស់ |
| | ១៣.៤.កសាងសមត្ថភាពមន្ត្រីអាជ្ញាធរទន្លេសាប និងមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធ | ៥ ឆ្នាំ (២០១៦-២០២០) | មធ្យម |

## ៥.២. ទិសដៅជាយុទ្ធសាស្ត្រ

ទិសដៅជាយុទ្ធសាស្ត្រទាំង ៥ ដែលបានលើកឡើង ត្រូវបានពន្យល់បន្ថែមនៅផ្នែកខាងក្រោម ដើម្បីបង្កើនការយល់ដឹងដល់ភាគីពាក់ព័ន្ធ (អ្នករៀបចំគោលនយោបាយ អ្នកបច្ចេកទេស និងអ្នកគាំទ្រថវិកា) ចំពោះការដឹកនាំគ្រប់គ្រងរបស់អាជ្ញាធរទន្លេសាប ។ ដើម្បីបង្កើនប្រសិទ្ធភាពនូវការយល់ដឹងកាន់តែច្បាស់ទៅលើបេសកកម្មការងាររបស់អាជ្ញាធរទន្លេសាប ត្រូវតែមានការពាក់ព័ន្ធនឹងការផ្សព្វផ្សាយឲ្យបានទូលំទូលាយ រួមជាមួយនឹងការប្រើប្រាស់ភាសានៅក្នុងផែនការយុទ្ធសាស្ត្រ ។

ទិសដៅជាយុទ្ធសាស្ត្រ ត្រូវកំណត់ឲ្យបានច្បាស់លាស់ដែលមានលក្ខណៈឯករាជ្យ និងស៊ីគ្នាជាមួយនឹងបេសកកម្មការងាររបស់អាជ្ញាធរទន្លេសាប ហើយដែលត្រូវធានាថា ភាពទំនាក់ទំនងគ្នាទៅវិញទៅមក គឺជាកត្តាសំខាន់នៅក្នុងគ្រោងការណ៍នៃការសម្របសម្រួល ។

### ៥.២.១. ការពង្រឹងគោលនយោបាយ, បទបញ្ញត្តិ, និងស្ថាប័ន

ការបង្កើតឡើងនូវអាជ្ញាធរទន្លេសាប ត្រូវបានបញ្ជាក់ឲ្យឃើញអំពីការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល ចំពោះកិច្ចការការពារធនធានធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ។ ផ្អែកលើបទបញ្ញត្តិនានារបស់អាជ្ញាធរទន្លេសាប រាជរដ្ឋាភិបាល បានបញ្ចូលនូវអភិក្រមច្បាស់លាស់ " **សម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍** " ក្នុងទស្សនវិស័យលើកកម្ពស់ដល់បឿនសេដ្ឋកិច្ចសង្គម ធនធានធម្មជាតិ បរិស្ថាន និងវប្បធម៌របស់ប្រទេសជាតិ ដូចជា ៖

- ទាមទាការពារនូវប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ ដែលជាធនធានដ៏កម្រនៃបឹងទន្លេសាប និងជាប្រភពសន្តិសុខស្បៀង ជាពិសេសធនធនជលផល
- ចូលរួមលើកកម្ពស់ដល់ការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ សំដៅឆ្ពោះទៅការកាត់បន្ថយភាពក្រីក្រនៅតំបន់ជុំវិញបឹងទន្លេសាប
- សម្របសម្រួលរាល់សកម្មភាព កម្មវិធី/គម្រោង ដែលកំពុងអនុវត្តន៍ គ្រោងនឹងអនុវត្តន៍នៅតំបន់ទន្លេសាប ដើម្បីឲ្យការងារមានភាពរលូនជាមួយគ្នាប្រកបដោយប្រសិទ្ធភាព

តួនាទីរបស់អាជ្ញាធរទន្លេសាប មិនគ្រាន់តែតម្រូវឲ្យរៀបចំនូវកិច្ចដំណើរការការងារក្នុងកិច្ចប្រតិបត្តិរបស់អង្គភាពដូចមានក្នុងតារាងទី ២ (លទ្ធផលរំពឹងទុក ៣) និងមាត្រាទី ៨ នៃព្រះរាជក្រឹត្យ ។ ទោះបីយ៉ាងណាក៏ដោយក៏បានលើកឡើងពីយន្តការការងារក្នុងការសម្របសម្រួល បង្កើនការទំនាក់ទំនងក្នុងកិច្ចសហប្រតិបត្តិការដើម្បីរៀបចំគោលនយោបាយ ទស្សនវិស័យ បេសកកម្មការងាររបស់អាជ្ញាធរទន្លេសាបជាមួយវិស័យពាក់ព័ន្ធ។ ការកំណត់អំពីគោលនយោបាយ **គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍វិស័យធនធានទឹក** ស្ថិតក្នុងក្របខ័ណ្ឌការគ្រប់គ្រងអាងទន្លេ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹក (ឆ្នាំ ២០០៧) ដែលជាការទទួលខុសត្រូវសំខាន់បំផុតរបស់ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការរៀបចំបញ្ជីសារពើភ័ណ្ឌធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា និងការប្រមូលចងក្រងទិន្នន័យអំពីបរិមាណ និងគុណភាពធនធានទឹក និងរៀបចំនូវផែនការធនធានទឹកថ្នាក់ជាតិ ។ ពាក់ព័ន្ធនឹងក្របខ័ណ្ឌច្បាប់ បទបញ្ញត្តិ នៃគោលនយោបាយធនធានទឹកនេះ គឺតម្រូវឲ្យអាជ្ញាធរទន្លេសាប ត្រូវធ្វើការសហការយ៉ាងជិតស្និតជាមួយនឹងវិស័យពាក់ព័ន្ធឲ្យបានទូលំទូលាយ ជាពិសេសក្រសួងធនធានទឹក និងឧតុនិយម ទៅលើការកសាងផែនការ និងរៀប

ចំនួនសារពើភ័ណ្ឌនៃធនធានទឹកក្នុងកម្រិតថ្នាក់ជាតិ និងតំបន់ទន្លេសាប (លទ្ធផលរំពឹងទុក ១ និងលទ្ធផលរំពឹងទុក ២) ។

ការរៀបចំកំណត់ដែនវិសាលភាពតំបន់ទន្លេសាប (សកម្មភាព ២.២) ជាមុខងារស្នូលដែលតម្រូវឲ្យកំណត់ ដើម្បីឲ្យឃើញពីដែនសមត្ថភាពការងាររបស់អាជ្ញាធរទន្លេសាប ។ តំបន់ប្រតិបត្តិការងារ ត្រូវរួមបញ្ចូលជាមួយនឹងបូរណភាពដែនដីរដ្ឋបាលខេត្តទាំង ៨ ជុំវិញតំបន់ទន្លេសាប ។ តំបន់ទន្លេសាបជាទិដ្ឋភាពភូមិសាស្ត្រមួយដ៏សំខាន់របស់ប្រទេសកម្ពុជា ដែលភ្ជាប់ទំនាក់ទំនងតាមរយៈប្រភពធនធានទឹក (Water Resources) ។ ទាំងអស់នេះ គឺជាហេតុផលសំខាន់បំផុត ត្រូវចាត់វិធានការការពារថែរក្សានូវធនធានធម្មជាតិ និងជីវៈចម្រុះនៃបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ដែលត្រូវបានកំណត់ថាជាដែនវិសាលភាពទីជម្រាល (Watershed Boundary) ។ ជាមួយគ្នានេះដែរ កម្មវិធីពាក់ព័ន្ធនឹងកិច្ចដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ត្រូវស្ថិតក្នុងដែនដីរដ្ឋបាលនៃខេត្ត/រាជធានី ស្រុក/ខណ្ឌ/ក្រុង ឃុំ/សង្កាត់ និងភូមិនីមួយៗ ។ ហេតុនេះការកំណត់ដែនវិសាលភាពតំបន់ទន្លេសាបជាមធ្យោបាយយ៉ាងសំខាន់បំផុត ក្នុងការកំណត់នូវកិច្ចប្រតិបត្តិការងាររបស់អាជ្ញាធរទន្លេសាប ដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃពីប្រសិទ្ធភាពនៃសកម្មភាព កម្មវិធី/គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ធនធានធម្មជាតិ និងបរិស្ថាន ដែលបង្កឲ្យប៉ះពាល់ដល់សក្តានុពលនៅតំបន់ទន្លេសាប ។

### ៥.២.២. ការពង្រឹងការយល់ដឹងជាមូលដ្ឋាន អំពីតំបន់ទន្លេសាប

ការយល់ដឹង និងការផ្សព្វផ្សាយឲ្យបានដឹង តាមលក្ខណៈវិទ្យាសាស្ត្រពីតំបន់ទន្លេសាប គឺមានសារៈសំខាន់បំផុត សម្រាប់អាជ្ញាធរទន្លេសាប ក្នុងការលើកកម្ពស់ដល់ការអនុវត្តគោលនយោបាយអាងទន្លេ និងបង្កលទ្ធភាពប្រកបដោយសង្គតភាព និងសម្របសម្រួលរាល់គម្រោងអភិវឌ្ឍន៍នានា ។ បែបបទសម្រាប់ពង្រឹងមូលដ្ឋានចំណេះដឹង និងការគាំទ្រដល់ក្រសួង ស្ថាប័នជាតិ នឹងត្រូវធ្វើតាមដំណាក់កាល ដែលមានក្នុង (លទ្ធផលរំពឹងទុក ៤ និងលទ្ធផលរំពឹងទុក ៥)។ បញ្ហាទាំងអស់នេះ តម្រូវឲ្យមានការសិក្សាស្រាវជ្រាវ និងប្រមូលចងក្រងព័ត៌មាន ទិន្នន័យធនធានធម្មជាតិ និងជីវៈចម្រុះ ជាពិសេសពាក់ព័ន្ធនឹងទីជម្រក ធនធានទឹក និងប្រព័ន្ធអេកូឡូស៊ី រួមជាមួយព័ត៌មាន ទិន្នន័យជាក់ស្តែងពាក់ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច នៅតំបន់បឹងទន្លេសាប និងធានាថាព័ត៌មាន ទិន្នន័យ ត្រូវបានរៀបចំគ្រប់គ្រង និងមានបច្ចុប្បន្នភាពច្បាស់លាស់ ។ ក្នុងអំឡុងរយៈពេល ៥ ឆ្នាំ អាជ្ញាធរទន្លេសាប ត្រូវតែដើរតួនាទីយ៉ាងសំខាន់ ក្នុងការបំពេញទិសដៅជាក់លាក់ក្នុងការជម្រុញការយល់ដឹងអំពីសក្តានុពលតំបន់ទន្លេសាប និងបង្កើនប្រសិទ្ធភាពប្រភពព័ត៌មាន ទិន្នន័យ ។

បញ្ហាគន្លឹះខ្លះៗ ដែលអាជ្ញាធរទន្លេសាប នឹងត្រូវយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់ ដើម្បីធានានូវភាពជោគជ័យក្នុងការពង្រឹងការយល់ដឹងមានដូចខាងក្រោម ៖

- ប្រមូលចងក្រងរាល់ប្រភេទព័ត៌មាន ទិន្នន័យពីគ្រប់ប្រភព (សកម្មភាព ៤.១) និងសហការឲ្យបានជិតស្និតជាមួយនឹងក្រសួងធនធានទឹក និងឧតុនិយម ក្នុងការប្រមូលរៀបចំចងក្រងធ្វើបញ្ជីសារពើភ័ណ្ឌធនធានទឹក និងក្របខ័ណ្ឌផែនការគ្រប់គ្រងអាងទន្លេ ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ (សកម្មភាព ៤.២ និងសកម្មភាព ៤.៣) ដើម្បីកសាងនូវ meta-database ពាក់ព័ន្ធនឹងព័ត៌មាន ទិន្នន័យសេដ្ឋកិច្ចសង្គម និងធនធានធម្មជាតិ/បរិស្ថានតំបន់ទន្លេសាប

- ចំណាត់ថ្នាក់ប្រភេទទិន្នន័យសំខាន់ៗ ការញែកចេញនូវប្រភេទទិន្នន័យ ដែលទិន្នន័យទាំងអស់នេះ តម្រូវឲ្យមានការពង្រឹងឡើងវិញ ក្នុងការរៀបចំកសាងផែនការ និងធ្វើការវាយតម្លៃ
- ផ្តួចផ្តើម ឬជម្រុញឲ្យមានប្រព័ន្ធ សម្រាប់ការចែករំលែកព័ត៌មាន ទិន្នន័យ និងលទ្ធភាពដែលអាចទទួលបានរវាងមូលដ្ឋានទិន្នន័យ
- ជម្រុញការសិក្សាស្រាវជ្រាវក្នុងតំបន់ពាក់ព័ន្ធ

អាជ្ញាធរទន្លេសាប គួរតែជាភ្នាក់ងារផ្សព្វផ្សាយនូវព័ត៌មាន ទិន្នន័យដែលពាក់ព័ន្ធ (សកម្មភាព ៥.១ និងសកម្មភាព ៥.២) និងគួររៀបចំនូវបណ្តាញព័ត៌មាន ទិន្នន័យឲ្យបានទូលំទូលាយ ដែលអាចស្វែងរកបានសម្រាប់ក្នុងការសិក្សាស្រាវជ្រាវ និងធ្វើអង្កេតនានា ។ ជាមួយនេះដែរ អាជ្ញាធរទន្លេសាប ក៏ត្រូវគិតគូពិចារណា និងសិក្សាលទ្ធភាព នៃការរៀបចំបង្កើតឲ្យវេទិកាចែករំលែក និងផ្សព្វផ្សាយពីលទ្ធផលនៃការសិក្សាស្រាវជ្រាវ (សកម្មភាព ៥.៣) ពាក់ព័ន្ធនឹងសក្តានុពល និងផលប៉ះពាល់តំបន់អាងទន្លេសាប ។

### ៥.២.៣. សម្របសម្រួល កសាងផែនការ និងការគ្រប់គ្រង

ទាក់ទងជាមួយដំណើរការប្រតិបត្តិ នៃផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ដែលមានអាណត្តិការងារជាក់លាក់ " **សម្របសម្រួល ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប** " បញ្ជាក់ឲ្យឃើញនូវសកម្មភាពសំខាន់ចំនួន ២ គឺ ៖

- ការជំរុញឲ្យមានគោលនយោបាយ យុទ្ធសាស្ត្រ និងក្របខ័ណ្ឌផែនការសម្រាប់តំបន់ទន្លេសាប
- តាមដានត្រួតពិនិត្យ និងវាយតម្លៃរាល់គម្រោង កំពុងអនុវត្តន៍ និងគ្រោងអនុវត្តន៍តំបន់ទន្លេសាប

ផ្អែកលើខ្លឹមសារព្រះរាជក្រឹត្យបង្កើត **អាជ្ញាធរទន្លេសាប** ដែលជាសេនាធិការផ្ទាល់ឲ្យរាជរដ្ឋាភិបាល តម្រូវឲ្យអង្គភាពជម្រុញប្រសិទ្ធភាពយន្តការសម្របសម្រួល ក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃរាល់គម្រោង និងសកម្មភាពនៅតំបន់ទន្លេសាប ដើម្បីពិនិត្យទៅលើគុណប្រយោជន៍នៃធនធានធម្មជាតិ បរិស្ថានព្រមជាមួយនឹងផលប៉ះពាល់មកលើតម្លៃសេដ្ឋកិច្ចសង្គម (លទ្ធផលរំពឹងទុក ៧) ។

ដើម្បីជានាភាពជោគជ័យការងារ អាជ្ញាធរទន្លេសាប នឹងមិនគ្រាន់តែរៀបចំបង្កើតនូវយន្តការសម្របសម្រួលប៉ុណ្ណោះទេ ថែមទាំងពិនិត្យអនុម័តឲ្យបានច្បាស់អំពីយន្តការ នៃក្របខ័ណ្ឌកសាងផែនការតំបន់ទន្លេសាប (លទ្ធផលរំពឹងទុក ៨) ដោយគិតគូពីការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចិរភាពនូវតម្លៃធនធានធម្មជាតិនិងបរិស្ថាននៅតំបន់ទន្លេសាប និងសេដ្ឋកិច្ចសង្គមកិច្ចតំបន់ទន្លេសាប ។ ការជម្រុញយន្តការសម្របសម្រួលឲ្យមានប្រសិទ្ធភាព ក៏តម្រូវឲ្យអាជ្ញាធរទន្លេសាប មានការយល់ដឹងពីហេតុផលរបស់គម្រោង គោលបំណងលក្ខន្តិកៈ និងវិសាលភាពនៃសកម្មភាព ដើម្បីកំណត់ពីរបៀបនៃការទំនាក់ទំនងរបស់គម្រោង រួមជាមួយការផ្សាភ្ជាប់ទៅនឹងទិសដៅជាយុទ្ធសាស្ត្រទី ១ ក្នុងការពង្រឹងគោលនយោបាយ បទបញ្ញត្តិ និងស្ថាប័ន ដោយសារតែការសម្របសម្រួលគម្រោង ត្រូវតែមានការចូលរួមសហការពីដៃគូពាក់ព័ន្ធ ។

ក្របខ័ណ្ឌកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់តំបន់ទន្លេសាប (សកម្មភាព ៨.១ សកម្មភាព ៨.២ និងសកម្មភាព ៨.៣) គឺជាភារកិច្ចគន្លឹះរបស់អាជ្ញាធរទន្លេសាប ដែលត្រូវរៀបចំបង្កើតឡើង ។ អាជ្ញាធរ

ទន្លេសាប អាចរៀបចំកសាងនូវយុទ្ធសាស្ត្រ គោលនយោបាយ និងរបាយការណ៍/សេចក្តីអត្ថាធិប្បាយបច្ចេកទេសលម្អិត អំពីស្ថានភាពតំបន់ទន្លេសាប (State of Tonle Sap) សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងសេដ្ឋកិច្ច សង្គមកិច្ចប្រកបដោយនិរន្តភាព ក្នុងការធ្វើឲ្យកាន់តែប្រសើរឡើងនូវតំបន់ទន្លេសាប (សកម្មភាព ៨.១) ។

ជាទូទៅអត្ថន័យខ្លឹមសារនៃចេនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប ឆ្លុះបញ្ចាំងពីការទទួលខុសត្រូវ ក្នុងការកសាងផែនការក្នុងរយៈពេលខ្លី មធ្យម និងវែង សម្រាប់តំបន់ទន្លេសាប ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់តំបន់ទន្លេសាប គួរតែមានរយៈពេល ១០ឆ្នាំ (ជារយៈពេលអប្បបរិមា) ដែលកំណត់ពីទិសដៅជាក់លាក់មុនដំបូងបំផុត សម្រាប់វឌ្ឍនភាពការងារ បន្ទាប់មកចំណុចជាយុទ្ធសាស្ត្រ មធ្យោបាយ និងកម្មវិធី តម្រូវឲ្យសម្រេចបានជោគជ័យទៅតាមគោលដៅចង់បាន ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់តំបន់ទន្លេសាប មិនមែនជា **ផែនការមេ ឬ ផែនទីបង្ហាញផ្លូវ** ទៅតាមផ្នែកនៃវិស័យនីមួយៗឡើយ ។ ផែនការយុទ្ធសាស្ត្រនេះ អាចត្រូវបានរៀបចំឡើង ដោយប្រមូលផ្តុំចេញពីផែនការដែលមានស្រាប់តាមវិស័យនីមួយៗ ដែលតម្រូវឲ្យមានការសម្របសម្រួលក្នុងកម្រិតខ្ពស់ ។ អាជ្ញាធរទន្លេសាប ត្រូវធ្វើការយ៉ាងជិតស្និតជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធនៅគ្រប់វិស័យ ដែលភាគច្រើនផ្សាភ្ជាប់ទៅនឹងភាពប្រឈមដល់ការគ្រប់គ្រងតំបន់ទន្លេសាប រួមមានកត្តាសំខាន់ចំនួន ២ ដែលពាក់ព័ន្ធនឹងកិច្ចការពារធនធានធម្មជាតិ បរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ។

## ៥.២.៤. ការទំនាក់ទំនង និងការកសាងសមត្ថភាពគ្រប់អ្នកពាក់ព័ន្ធ

ការលើកកម្ពស់សមត្ថភាពនៃការយល់ដឹង អំពីអភិបាលកិច្ចក្នុងគោលការណ៍នៃការគ្រប់គ្រងធនធានធម្មជាតិ ការគ្រប់គ្រងអាងទន្លេ និងជាពិសេសការយល់ច្បាស់ការងារស្នូលរបស់អាជ្ញាធរទន្លេសាប តម្រូវឲ្យរៀបចំនូវផែនការទំនាក់ទំនងជាក់លាក់មួយ (លទ្ធផលរំពឹងទុក ៩) ដើម្បីកំណត់ពីចំណុចដៅ និងព័ត៌មាននៃការទំនាក់ទំនង ។ ភាពសំខាន់ គឺការកំណត់សំគាល់ឲ្យបានច្បាស់រវាងការប្រាស្រ័យទំនាក់ទំនងជាលក្ខណៈទូទៅ ស្តីពីស្ថានភាពបរិយាកាសរបស់អាងទន្លេ និងទិដ្ឋភាពលក្ខណៈបច្ចេកទេសពាក់ព័ន្ធទៅនឹងដំណើរការប្រតិបត្តិនៃអាងទន្លេ ។ នៅចំណុចនេះ ភាពផ្សាភ្ជាប់នៃការទំនាក់ទំនង ត្រូវរៀបចំបង្កើតឡើងជាមួយនឹងការងារអង្កេត ។

ការប្រាស្រ័យទំនាក់ទំនង ត្រូវបានទទួលស្គាល់ និងលើកទឹកចិត្តដោយដៃគូភាគច្រើនរបស់អាជ្ញាធរទន្លេសាប នឹងត្រូវបានផ្តល់ជាចំនុចសំខាន់ៗក្នុងកម្មវិធីបណ្តុះបណ្តាល សម្រាប់ដៃគូនាពេលបច្ចុប្បន្ន និងពេលអនាគត (សកម្មភាព ១០.១ និងសកម្មភាព ១០.២)។ ទាំងនេះមានន័យថា អាជ្ញាធរទន្លេសាប អាចនឹងអាស្រ័យលើបណ្តាញទំនាក់ទំនងប្រកបដោយសមត្ថភាពដែលមានស្រាប់នៅតំបន់ទន្លេសាប ឬមានលទ្ធភាពគ្រប់គ្រាន់រៀបចំបណ្តុះបណ្តាលគ្រូបង្គោលនៅតាមបណ្តាក្រសួង ស្ថាប័នស្នូលថ្នាក់ជាតិ ដើម្បីរៀបចំដំណើរការឲ្យមាននិរន្តភាពបន្ថែមទៀត ។ ការកំណត់ឲ្យដឹងពីអ្នកប្រើប្រាស់ ដែលទាញយកផលប្រយោជន៍ពីបឹងទន្លេសាប ដែលជាយុទ្ធសាស្ត្រស្នូលសំខាន់មួយក្នុងរយៈពេលមធ្យម ពីព្រោះមួយផ្នែក បានមកពីកាលានុវត្តភាពនៃការផ្តល់តាមរយៈគម្រោងនិងការផ្សព្វផ្សាយព័ត៌មានជូនដល់ប្រជាជន ដែលត្រូវបានធ្វើឡើងតាមរយៈសមាជិក

សហគមន៍/សមាគមន៍ និងក្រុមការងារស្ថិតក្នុងរចនាសម្ព័ន្ធចាត់តាំង ក្នុងការជួយដល់អាជ្ញាធរទន្លេសាបក្នុងការបង្កើតសេចក្ដីសម្រេចចិត្ត ។

អាជ្ញាធរទន្លេសាប នឹងធានាថាការកំណត់ពីផែនការប្រាស្រ័យទំនាក់ទំនង និងផែនការបណ្ដុះបណ្ដាលឲ្យបានច្បាស់លាស់ ដោយជៀសវាងការលោភលន់ហួសប្រមាណ និងការមិនស៊ីគ្នាដោយរលូននៅក្នុងដំណាក់កាលនីមួយៗ ។ សមត្ថភាពជំនាញបច្ចេកទេសនៅផ្ទៃក្នុង អាចនឹងជ្រើសរើស ដើម្បីដើរតួនាទីយ៉ាងសំខាន់ជាអ្នកសម្របសម្រួល ។

## ៥.២.៥. ការកសាងសមត្ថភាពខាងក្នុង

ទិសដៅជាយុទ្ធសាស្ត្រក្នុងរយៈពេល ៥ ឆ្នាំ គឺមានសារៈសំខាន់សម្រាប់អាជ្ញាធរទន្លេសាប ។ ប្រសិនបើគុណភាពនៃសមត្ថភាពមន្ត្រីរបស់អាជ្ញាធរទន្លេសាប នៅមានកម្រិតទាប ក៏មិនអាចសម្រេចទិសដៅប្រកបដោយជោគជ័យបានឡើយ ។ ដើម្បីធានាឲ្យមានភាពជោគជ័យ នូវការយល់ដឹងអភិបាលកិច្ចក្នុងគោលការណ៍នៃការគ្រប់គ្រងធនធានទឹកចម្រុះ ធនធានធម្មជាតិ ការគ្រប់គ្រងអាងទន្លេ និងជាពិសេសការយល់ច្បាស់ពីការងារស្នូលអាជ្ញាធរទន្លេសាប ដាច់ខាតត្រូវមានមូលដ្ឋានគ្រឹះសមត្ថភាពនៃការយល់ដឹងឲ្យបានទូលំទូលាយ ។

ភាពចាំបាច់សម្រាប់អាជ្ញាធរទន្លេសាប ត្រូវធានាឲ្យបានជោគជ័យនូវបេសកកម្មការងារ រួមមាន ៖

- តម្រូវឲ្យមានសមត្ថភាពខ្ពស់ ដើម្បីសិក្សាស្រាវជ្រាវព័ត៌មាន ទិន្នន័យដែលមានលក្ខណៈវិទ្យាសាស្ត្រ និងការគ្រប់គ្រងទិន្នន័យ និងធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃរាល់គម្រោងកំពុងអនុវត្តន៍ និងគ្រោងអនុវត្តន៍នៅតំបន់ទន្លេសាប ។ កាលានុវត្តភាពនៃទិសដៅជាយុទ្ធសាស្ត្រ ក្នុងតួនាទីប្រកបទៅដោយជំនាញ គឺជាមូលដ្ឋានគ្រឹះ ដើម្បីបង្កើនជំនឿទុកចិត្តសម្រាប់អាជ្ញាធរទន្លេសាប និងលើកកម្ពស់ប្រសិទ្ធភាពការងារដល់អង្គភាពក្នុងការទទួលខុសត្រូវជាមូលដ្ឋានទៅលើសកម្មភាពសម្របសម្រួល សិក្សាស្រាវជ្រាវ និងតាមដានត្រួតពិនិត្យវាយតម្លៃ ដល់ការអនុវត្តគម្រោងនៅតំបន់ទន្លេសាប ។ ជាទូទៅអាជ្ញាធរទន្លេសាប តាមរយៈអគ្គលេខាធិការដ្ឋាន នឹងធានានូវការអភិវឌ្ឍធនធានមនុស្ស ក្នុងការឆ្លើយតបទៅនឹងបេសកកម្ម និងសកម្មភាពនៅតំបន់ទន្លេសាប និងមិនត្រូវធ្វើការជ្រើសរើសដោយមិនមានអំណះអំណាង ច្បាស់លាស់ណាមួយឡើយ ។ ទិសដៅជ្រើសរើសមុនដំបូង ដែលត្រូវជ្រើសរើសមន្ត្រីដែលមានបច្ចេកទេសប្រកបដោយសមត្ថភាព ដើម្បីអនុវត្តន៍ការងារទទួលខុសត្រូវ (ការគ្រប់គ្រងគម្រោង)សកម្មភាពគន្លឹះនៅក្នុងរយៈពេល ៥ ឆ្នាំ ។ ជាក់ស្ដែង ជំនាញប្រកបដោយសមត្ថភាព ដែលអាជ្ញាធរទន្លេសាប នឹងធានាដល់ការអនុវត្តនូវផែនការយុទ្ធសាស្ត្រនេះ ។
- ស្វយ័តហិរញ្ញវត្ថុ ដើម្បីអនុវត្តន៍សកម្មភាពជាមូលដ្ឋាន ។ ក្នុងដំណើរការបង្កើតនូវភាពស្មុគស្មាញ សម្រាប់ការសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប និងលក្ខណៈឆ្លងដែន (ប្រសិនបើ) អាជ្ញាធរទន្លេសាប នឹងស្វះស្វែងកៀងគរធនធានហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់ ដើម្បីធានាឲ្យកិច្ចប្រតិបត្តិឲ្យបានរលូនក្នុងអង្គភាព និងធានាឲ្យការសម្របសម្រួលលើរាល់សកម្មភាព កម្មវិធី/គម្រោងកំពុងអនុវត្តន៍ និងគ្រោងអនុវត្តន៍ក្នុងតំបន់

ទន្លេសាបប្រកបដោយប្រសិទ្ធភាព ។ ជាការសំខាន់បំផុត អាជ្ញាធរទន្លេសាប ត្រូវប្រកបដោយភាពបទបែន និងមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាពក្នុងសមត្ថភាពជាអង្គភាពសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ។

# ៦. មធ្យោបាយប្រតិបត្តិ

## ៦.១. សេចក្តីផ្តើម

ទិសដៅជាយុទ្ធសាស្ត្រទាំង ៥ ខាងលើ បានបង្ហាញនៅក្នុងផ្នែកមុន គឺកំណត់ឲ្យឃើញពីក្របខ័ណ្ឌការអភិវឌ្ឍជាយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាបនៅក្នុងឆ្នាំខាងមុខ ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ គឺជាអំណះអំណាងសម្រាប់ភាគីពាក់ព័ន្ធ ដែលជាដៃគូ ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រ ក៏ឆ្លុះបញ្ចាំងពីកិច្ចដំណើរការអភិវឌ្ឍរបស់អាជ្ញាធរទន្លេសាប ក្នុងការបង្កើតនូវការយល់ដឹង ការធ្វើសេចក្តីសម្រេចចិត្ត និងរៀបចំនូវសកម្មភាពការងារក្នុងរយៈពេលមធ្យម ។

ភាពប្រឈមរបស់អាជ្ញាធរទន្លេសាប គឺការបង្កើតឡើងនូវកិច្ចប្រតិបត្តិការឲ្យបានគ្រប់ទិសដៅជាយុទ្ធសាស្ត្រ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ ការមិនបានដាក់ចូលទៅក្នុងផែនការសកម្មភាពការងារ និងផែនការកម្មវិធីថវិកា ក្នុងជំពូកខាងក្រោម គឺបង្ហាញពីចំនុចអាទិភាពសម្រាប់ការអន្តរាគមន៍ ។ ទិសដៅ គឺដើម្បីរក្សានូវជាតុស្នូលនៃបេសកកម្ម និងអាណត្តិការងាររបស់អាជ្ញាធរទន្លេសាប ដើម្បីទទួលបាននូវការយល់ដឹងច្បាស់អំពីគោលនយោបាយ និងការទទួលស្គាល់ក្នុងកម្រិតបច្ចេកទេស ។

អាទិភាពខាងក្រោម ត្រូវបានកំណត់ឡើងក្នុងរយៈពេល ៥ឆ្នាំ អាជ្ញាធរទន្លេសាប នឹងយកចិត្តទុកដាក់បានយ៉ាងត្រឹមត្រូវរាល់ដំណើរការការងារបច្ចេកទេស និងការគ្រប់គ្រងស្ថាប័ន/អង្គភាព ដើម្បីធានាប្រសិទ្ធភាពការសម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ។

## ៦.២. អាទិភាពអន្តរាគមន៍របស់អាជ្ញាធរទន្លេសាប

### ៦.២.១. អាទិភាពគន្លឹះរបស់អាជ្ញាធរទន្លេសាប

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប នឹងដើរតួនាទីសំខាន់ ក្នុងការយកចិត្តទុកដាក់បំផុតនៅក្នុងរយៈពេលអនុវត្តន៍ ៥ឆ្នាំ ទៅលើបញ្ហាអាទិភាព ដូចខាងក្រោម ៖

- បង្កើនធនធានហិរញ្ញវត្ថុ ដើម្បីបង្កលទ្ធភាពអនុវត្តន៍ឲ្យបានពេញលេញនូវការសិក្សាជាមូលដ្ឋាន និងបំពេញមុខងារស្ថាប័ន/អង្គភាពប្រចាំថ្ងៃ
- បន្តផ្សព្វផ្សាយ និងអនុវត្តន៍នូវសកម្មភាពបច្ចេកទេសជាមូលដ្ឋានគ្រឹះ បង្កើតឲ្យមានវេទិកាចែករំលែក និងផ្សព្វផ្សាយពីលទ្ធផលនៃការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងសក្តានុពល និងផលប៉ះពាល់តំបន់អាងទន្លេសាប រៀបចំគ្រប់គ្រងប្រភពព័ត៌មាន ទិន្នន័យពាក់ព័ន្ធតំបន់ទន្លេសាប, ផ្សព្វផ្សាយ និងបញ្ចប់ការកំណត់ដែនវិសាលភាពតំបន់ទន្លេសាប (មាត្រា ២), របាយការណ៍/សេចក្តីអត្ថាធិប្បាយបច្ចេកទេស អំពីស្ថានភាពតំបន់ទន្លេសាប (State of Tonle Sap), និង

ជាពិសេសផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ទន្លេសាប និងផែនការប្រាស្រ័យទំនាក់ទំនង (សម្របសម្រួល) ដែលបំពេញឲ្យគ្នាទៅវិញទៅមក

- បង្កើតឡើង និងសម្របសម្រួលក្រសួង ស្ថាប័នស្នូលរបស់ជាតិ
- ជ្រើសរើសក្រុមការងារបច្ចេកទេស និងរដ្ឋបាល ជំនាញការ អ្នកគ្រប់គ្រងគម្រោង និងមន្ត្រីលេខាធិការដ្ឋាន ទាមទារឲ្យសម្រេចបាននូវទិសដៅជាក់លាក់ទី ១, ទី ២ និងទី ៣
- លើកកម្ពស់ភាពជាដៃគូ ជាមួយនឹងដៃគូបច្ចេកទេស និងហិរញ្ញវត្ថុសំខាន់ៗ

## ធនធានហិរញ្ញវត្ថុ

បើពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់នោះទេ អាជ្ញាធរទន្លេសាប នឹងមិនមានភាពឯករាជ្យ ឬលទ្ធភាពដើម្បីអនុវត្តន៍មុខងារស្នូលប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលឡើយ ។ អាជ្ញាធរទន្លេសាប ត្រូវតែឯករាជ្យនៅក្នុងការងារ ដើម្បីលើកកម្ពស់ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ។

ក្នុងនោះផងដែរ ត្រូវសម្របសម្រួល ឲ្យមានការចូលរួមបដិភាគពីបណ្ដាក្រសួង ស្ថាប័ន ដែលសមាជិករបស់អាជ្ញាធរទន្លេសាប ដែលជាប្រភពមូលដ្ឋានគ្រឹះក្នុងការកៀងគរធនធានហិរញ្ញវត្ថុ និងជាការចាំបាច់ត្រូវបង្កើតឡើងនូវមូលនិធិបន្ថែម ដែលហៅថា រចនាសម្ព័ន្ធនៃការអន្តរាគមន៍ Structural Intervention ដើម្បីប្រតិបត្តិសកម្មភាពអាទិភាពផ្សេងៗទៀត ដែលបានបង្ហាញខាងលើ ។ រចនាសម្ព័ន្ធនៃការអន្តរាគមន៍ មានន័យថា ប្រមូលផ្តុំនូវថវិកាសម្រាប់ការសិក្សាបច្ចេកទេស និងការប្រតិបត្តិស្នូល ។

## ការសិក្សាបច្ចេកទេស

ជាលក្ខណៈបច្ចេកទេសប្រកបដោយជំនាញពិតប្រាកដរបស់អាជ្ញាធរទន្លេសាប អាចត្រឹមតែសម្រេចបាននូវភាពជោគជ័យ ដោយការបង្ហាញនូវធាតុសំខាន់ៗទៅដល់ដៃគូ ។ វា គឺជាការបង្កើតបាននូវជំនឿទុក ចិត្តមួយ ដែលធ្វើឲ្យអាជ្ញាធរទន្លេសាប ត្រូវបានទទួលស្គាល់ ដូចនឹង អង្គការអាងទន្លេ (River Basin Organization) ហើយវាក៏ជាការបង្កឲ្យមានជំនឿទុកចិត្តផងដែរ ដែលនឹងនាំឲ្យអាជ្ញាធរទន្លេសាប អាចដើរតួនាទីជាស្ថាប័នគោលនយោបាយ ក្នុងចំណោមក្រសួង ស្ថាប័នជាសមាជិកនៅក្នុងតំបន់ទន្លេសាប ដែលធ្វើឲ្យមានការគាំទ្រនូវកិច្ចប្រឹងប្រែងក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ជាតិ ។ ***សកម្មភាពចាំបាច់ ដែលត្រូវបានស្នើឡើងជាអាទិភាពសម្រាប់រយៈពេល ៥ ឆ្នាំ រួមមាន ៖ ការកំណត់ដែនសីមាភាពតំបន់ទន្លេសាប (មាត្រា ២), របាយការណ៍/សេចក្តីអត្ថាធិប្បាយបច្ចេកទេស អំពីស្ថានភាពតំបន់ទន្លេសាប (State of Tonle Sap), ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ទន្លេសាប និងផែនការប្រាស្រ័យទំនាក់ទំនង (សម្របសម្រួល) ដែលបំពេញឲ្យគ្នាទៅវិញទៅមក ។***

មណ្ឌលប្រភពព័ត៌មាន ទិន្នន័យសម្រាប់តំបន់ទន្លេសាប នឹងធានាឲ្យការតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយភាពត្រឹមត្រូវសម្រាប់គោលនយោបាយសាធារណៈបច្ចុប្បន្ន និងពេលអនាគត ស្តីពីតំបន់ទន្លេសាប ។ ទាំងនេះ នឹងជួយរៀបចំនូវប្រព័ន្ធគ្រប់គ្រងការប្រមូល និងដំណើការព័ត៌មានទិន្នន័យក្នុងតំបន់ទន្លេសាប ។ នៅក្នុងរយៈពេលវែង ប្រភេទផ្សេងៗទៀត អាចផ្តល់នូវការគាំទ្រដល់ការបង្កើតសេចក្តីសម្រេចចិត្ត

នឹងដឹកនាំទៅរកការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងការចែករំលែកផលប្រយោជន៍ សម្រាប់ភាពជោគជ័យរបស់អាជ្ញាធរទន្លេសាប ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ទន្លេសាប គឺជាឯកសារបង្ហាញផ្លូវជាយុទ្ធសាស្ត្រ មានខ្លឹមសារទូលំទូលាយ ផ្សាភ្ជាប់ទៅគ្រប់ផ្នែក និងសកម្មភាពតាមវិស័យដែលពាក់ព័ន្ធទៅនឹងកិច្ចការការពារគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ហើយគួរតែជាផែនការរយៈពេល ១០ឆ្នាំ ដែលកំណត់ពីទិសដៅនៃវឌ្ឍនភាពច្បាស់លាស់ បន្ទាប់មកមានយុទ្ធសាស្ត្រ មធ្យោបាយ និងកម្មវិធី ដែលអាចសម្រេចបាននូវគោលដៅ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍នេះ តម្រូវឲ្យមានយន្តការសម្របសម្រួលកម្រិតខ្ពស់ ដែលជាប្រយោជន៍សំខាន់ ។ ដូចនេះ អាជ្ញាធរទន្លេសាប តម្រូវពង្រឹងនូវយន្តការសម្របសម្រួល ក្នុងកិច្ចសហការជាមួយនឹងក្រសួងស្ថាប័នដែលពាក់ព័ន្ធ ដើម្បីក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ទន្លេសាប។ ការកសាងយុទ្ធសាស្ត្រ និងផែនការកម្រិតអាងទន្លេ តម្រូវឲ្យមានកិច្ចសហការជាមួយនឹងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ។ ជាមួយនេះដែរ អាជ្ញាធរទន្លេសាប ក៏ត្រូវរៀបចំបង្កើតឡើងនូវយុទ្ធសាស្ត្រ គោលនយោបាល និងសេចក្តីណែនាំដែលមានលក្ខណៈលម្អិត សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍នូវធនធានធម្មជាតិ បរិស្ថាន និងសេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌តំបន់អាងទន្លេសាប ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់តំបន់បឹងទន្លេសាប គួរតែ ៖

- ជាផែនការកំណត់ច្បាស់លាស់ ក្នុងការវាស់វែងនូវវឌ្ឍនភាពនិងទិសដៅ ដែលចង់បាន
- ជាផែនការដែលមានការសម្របសម្រួលនូវគ្រប់វិស័យ និងយុទ្ធសាស្ត្រពាក់ព័ន្ធ
- ជាផែនការដែលផ្តល់នូវដំណោះស្រាយដោយរលូននឹងគ្នារវាងយុទ្ធសាស្ត្រតាមវិស័យ

## ការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងស្ថាប័នស្នូល សម្រាប់អាជ្ញាធរទន្លេសាប

ក្នុងមាត្រា ៣ ថ្មី នៃព្រះរាជក្រឹត្យបង្កើត **អាជ្ញាធរទន្លេសាប** បានកំណត់ឲ្យមានសេចក្តីសម្រេចមួយដែលអនុម័តដោយរាជរដ្ឋាភិបាល ក្នុងការតែងតាំងសមាសភាពជាក់ស្តែងរបស់អាជ្ញាធរទន្លេសាប ហើយដែលសមាសភាពទាំងអស់នោះមកពីបណ្តាក្រសួងស្ថាប័នជំនាញពាក់ព័ន្ធចំនួន ២៣ និងខេត្តជុំវិញតំបន់ទន្លេសាបចំនួន ៨ ខេត្ត ។ វា គឺជាកត្តាមួយសំខាន់ ក្នុងការកំណត់បាននូវក្របខ័ណ្ឌច្បាស់លាស់ សម្រាប់ការបង្កើតឡើងនូវក្រុមការងារបច្ចេកទេសអន្តរក្រសួងស្ថាប័នស្នូល សម្រាប់ជួយគាំទ្រពន្លឿនល្បឿនផែនការជាយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ដើម្បីធានាឲ្យមានការទំនាក់ទំនងការងារគ្នាទៅវិញទៅមកក្នុងតំបន់ជាមួយនឹងអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។ ដោយឡែកកញ្ចប់ធនធានហិរញ្ញវត្ថុ ក៏បានឆ្លុះបញ្ចាំងទៅតាមការងារខាងលើដែរ នឹងបម្រើជាមូលដ្ឋានសម្រាប់ការបង្កើតនូវក្រុមការងារស្នូល និងបង្កើនកិច្ចប្រតិបត្តិការការងារ ។

ភ្ជាប់ជាមួយនឹងការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងស្ថាប័នស្នូល សម្រាប់អាជ្ញាធរទន្លេសាប វាក៏អាចជាការងារមិនចាំបាច់ផងដែរនៅដំណាក់កាលដំបូង គឺការបង្កើនចំនួនសមាជិក ។ ក៏ប៉ុន្តែក្រុមការងារបច្ចេកទេសអន្តរក្រសួងស្ថាប័នស្នូល គឺជាអាទិភាព សម្រាប់ប្រសិទ្ធភាពនៃការអនុវត្តន៍ទិសដៅជាយុទ្ធសាស្ត្រ និងពង្រឹងជំនឿទុកចិត្ត សម្រាប់អាជ្ញាធរទន្លេសាប ។

## ការជ្រើសរើសមន្ត្រីបម្រើការងារនៅអាជ្ញាធរទន្លេសាប

ការជ្រើសរើសមន្ត្រី ដូចបានបង្ហាញក្នុងផ្នែក ៥.២.៥ នឹងត្រូវអនុវត្តន៍ដោយយោងតាមតម្រូវការ និងភាពមិនចាំបាច់ ដោយយោងលើរចនាសម្ព័ន្ធដែលមានស្រាប់ ។ កត្តាខាងក្រោម ដែលគួរជាមូលដ្ឋាននៃការជ្រើសរើសមន្ត្រីឲ្យចូលបម្រើការងារ ៖

- មន្ត្រីគួរតែមានសមត្ថភាពអនុវត្តន៍នូវការងារឯករាជ្យ សម្រាប់អគ្គលេខាធិការដ្ឋាន និងជៀសវាងភាពអាច់កំបាំង ដែលមិនមានអារម្មណ៍ទទួលខុសត្រូវការងារនៅក្នុងអាជ្ញាធរទន្លេសាប
- មន្ត្រីត្រូវបំពេញការងារក្រោមនាយកដ្ឋានជំនាញ ត្រូវជ្រើសរើសដោយមានការប្រឹក្សាយោបល់ជាមួយនឹងប្រធាននាយកដ្ឋាន

ផ្តើមចេញពីកត្តាខាងលើ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប នឹងជ្រើសរើសដូចខាងក្រោម ៖

- មន្ត្រីមានជំនាញស្រាវជ្រាវ
- មន្ត្រីប្រាស្រ័យទំនាក់ទំនង (សម្របសម្រួល)
- មន្ត្រីហិរញ្ញវត្ថុ
- មន្ត្រីនាយកដ្ឋានជំនាញផែនការ រួមមានប្រធាន ជំនាញធនធានធម្មជាតិ បរិស្ថាន សេដ្ឋកិច្ចសង្គម ជីវះចម្រុះ ធនធានទឹក....
- មន្ត្រីបច្ចេកទេស និងលេខាធិការផ្សេងៗទៀត

## ការលើកកម្ពស់ក្នុងភាពជាដៃគូជំនាញបច្ចេកទេស និងហិរញ្ញវត្ថុ

បើពុំមានដៃគូគាំទ្រផ្នែកជំនាញបច្ចេកទេស និងហិរញ្ញវត្ថុក្នុងរយៈពេលវែងទេ អាជ្ញាធរទន្លេសាប ក៏មិនអាចមានដំណើរការទៅមុខបានលឿន និងមិនអាចត្រូវបានគេទទួលស្គាល់ផងដែរ ។ អាទិភាពការងារនេះ គឺជាភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ក្នុងការប្រមូលកៀងគរធនធានហិរញ្ញវត្ថុ សម្រាប់ការធ្វើអន្តរាគមន៍ក្នុងពេលអនាគត ។ និមិត្តកម្មនៃក្រុមជំនាញបច្ចេកទេសប្រកបដោយភាពមាំមួន ដូចបានបញ្ជាក់ខាងលើ នឹងជួយរៀបចំបង្កើតនូវពេលវេលាបន្ថែមទៀត សម្រាប់បេសកកម្មជាយុទ្ធសាស្រ្ត ។ អគ្គលេខាធិការ និងអគ្គលេខាធិការរង នឹងទទួលខុសត្រូវនូវគោលនយោបាយ ផ្សាភ្ជាប់រវាងអង្គការចាត់តាំងរបស់អាជ្ញាធរទន្លេសាប និងស្ថាប័នដៃគូខាងក្រៅ និងជានាទូវកិច្ចប្រតិបត្តិសម្រាប់បេសកកម្ម និងអាណត្តិការងាររបស់អាជ្ញាធរទន្លេសាប ។ បេសកកម្មនេះ នឹងពង្រឹងផ្នែកគោលនយោបាយ និងការបង្កើតសេចក្តីសម្រេចចិត្តជាយុទ្ធសាស្រ្តដល់ថ្នាក់ដឹកនាំ និងរាជរដ្ឋាភិបាល ។

ការពន្យល់ច្បាស់លាស់នៅផ្នែកខាងលើ ដែលក្រសួងស្ថាប័នភាគីពាក់ព័ន្ធ ចាត់ទុកជាឆ្អឹងខ្នងនៃភាពជោគជ័យរបស់អាជ្ញាធរទន្លេសាប ក្នុងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្រ្ត ។ ក្រសួងស្ថាប័នទាំងអស់នោះរួមមានក្រសួងស្ថាប័ន និងខេត្តពាក់ព័ន្ធជាសមាជិក ដែលធ្វើការរួមគ្នាលើគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ។ ជាមួយនឹងនេះដែរ ក៏មានរួមបញ្ចូលទាំងដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ វិទ្យាស្ថានសិក្សាស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល ។ល។ ដែលគាំទ្រពល់គម្រោង និងកម្មវិធីស្ថិតក្នុងក្របខ័ណ្ឌសុខដុមនីយកម្ម ។

ភាពជាចាំបាច់ តម្រូវឲ្យរៀបចំបង្កើតឡើងនូវភាពជាដៃគូ និងបណ្តាញការងារ ជាមួយនឹងភាគីពាក់ព័ន្ធក្នុងតំបន់ ដែលជាអត្ថប្រយោជន៍ទូទៅ ដើម្បីសម្រេចឲ្យបាននូវប្រយោជន៍ទៅវិញទៅមកក្នុងការរៀបចំ និងចែករំលែកចំណេះដឹង និងបទពិសោធន៍ និងការផ្សព្វផ្សាយពីព័ត៌មានការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ បរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីទៅដល់អ្នកប្រើប្រាស់ ។ ក្នុងការពង្រឹងពង្រីកទំនាក់ទំនងក្នុងភាពជាដៃគូ អាជ្ញាធរទន្លេសាប ត្រូវពាក់ព័ន្ធទៅនឹងការផ្តល់នូវវេទិការសម្រាប់ការពិគ្រោះយោបល់ និងការផ្លាស់ប្តូរបទពិសោធន៍ក្នុងចំណោម អង្គការអាងទន្លេនៅកម្រិតថ្នាក់តំបន់ និងអន្តរជាតិ ដូចជា ៖ គណៈកម្មការទន្លេមេគង្គ/គណៈកម្មាធិការជាតិទន្លេមេគង្គ (MRC/NMC),Marry Darling Basin Authority (Australia), Laguna Lake Development Authority (Philippines), Red River Basin Organization (Viet Nam) ។ល។

តាមរយៈក្រុមការងារបច្ចេកទេសអន្តរក្រសួងស្ថាប័នស្នូល អាជ្ញាធរទន្លេសាប នឹងប្រឹងប្រែងដោយយកចិត្តទុកដាក់ ដើម្បីជម្រុញនូវភាពជាដៃគូជាយុទ្ធសាស្ត្រ ជាមួយនឹងដៃគូរអភិវឌ្ឍន៍ដូចជា ៖ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលជាមួយនឹងការយកចិត្តទុកដាក់ក្នុងការអនុវត្ត និងអ្នកប្រើប្រាស់ ។ អភិក្រមនេះ គឺដើម្បីជម្រុញលើកកម្ពស់ការអនុវត្តនូវចំណេះដឹង ដែលបង្កឲ្យកើតមាន និងទប់ស្កាត់នូវរាល់ផលប៉ះពាល់ទៅដល់អ្នកប្រើប្រាស់ ។ ដើម្បីរក្សាបាននិរន្តរភាពក្នុងភាពជាដៃគូ ត្រូវរៀបចំនូវភាពទំនាក់ទំនងដោយមានការឯកភាពក្នុងកិច្ចព្រមព្រៀង ដូចជា ៖ ការចុះអនុសារណៈយោគយល់គ្នានៃកិច្ចព្រមព្រៀង ដែលបែងចែកនូវតួនាទី និងការទទួលខុសត្រូវរបស់ដៃគូនីមួយៗ ។

ក្នុងក្របខ័ណ្ឌក្រុមប្រឹក្សាយោបល់កិច្ចសហប្រតិបត្តិការភាពជាដៃគូទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ត្រូវបានរៀបចំបង្កើតឡើងដោយអាជ្ញាធរទន្លេសាប ដែលសកម្មភាពនេះ គួរត្រូវបានបង្កើតឡើង ដើម្បីទាក់ទាញដៃគូបន្ថែមទៀត ដើម្បីគាំទ្រសកម្មភាពរបស់អាជ្ញាធរទន្លេសាប ។ តួនាទីសំខាន់របស់អាជ្ញាធរទន្លេសាប គឺគាំទ្រដល់ក្រសួងស្ថាប័ន និងខេត្តពាក់ព័ន្ធ ដើម្បីបង្កើតឡើងនូវបរិយាកាសដ៏ល្អប្រសើរ សម្រាប់ការចូលរួមរបស់វិស័យឯកជន ក្នុងកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ បរិស្ថាន និងជីវៈចម្រុះតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ។

### ៦.២.២. ការរៀបចំកម្មវិធីភាពជាដៃគូ អាជ្ញាធរទន្លេសាប

កម្មវិធីភាពជាដៃគូ និងបណ្តាញការងារ អាជ្ញាធរទន្លេសាប នឹងគ្របដណ្តប់ទៅដោយធាតុសំខាន់ៗ ដែលរួមមាន ៖

- ការរៀបចំបង្កើតឡើងនូវសេចក្តីត្រូវការ សម្រាប់ភាពជាដៃគូ និងការព្រមព្រៀងអាស្រ័យនឹងទម្រង់ទូទៅនៃគោលដៅនីមួយៗ
- ការកំណត់ឲ្យឃើញ និងភាពផ្សាភ្ជាប់ទៅនឹងក្រុម/បុគ្គល នៃភាគីពាក់ព័ន្ធសំខាន់ៗ
- ការឯកភាព ទៅលើលទ្ធផលរំពឹងទុក សម្រាប់សកម្មភាពក្នុងភាពជាដៃគូ
- ការផ្តល់នូវភាពត្រឹមត្រូវក្នុងវេទិការ នៃការចូលរួមរបស់ដៃគូ
- ការទទួលបាននូវភាពទំនាក់ទំនងដោយផ្ទាល់ និងគាំទ្រដល់ថ្នាក់ដឹកនាំរបស់ដៃគូ

- ការប្រកាន់ខ្ជាប់នូវគំនិតដ៏ត្រឹមត្រូវចំពោះបញ្ហា និងដំណោះស្រាយ
- ការបង្កើតឡើងនូវកិច្ចប្រតិបត្តិដោយសមធម៌សម្រាប់គ្រប់ដៃគូ
- ការកំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់ដៃគូ (ហិរញ្ញវត្ថុ ជាតុចេញ និងជាតុចូល)
- ការបញ្ជាក់ឲ្យបានច្បាស់នូវចំណុចដៅ និងការផ្តល់ធនធាន
- ការលើកទឹកចិត្តកម្រិតអតិបរិមាក្នុងការចូលរួម ក្នុងការកសាងផែនការ និងការអនុវត្ត
- ការវាយតម្លៃពីគម្រោងទូទៅ
- ការផ្សព្វផ្សាយលទ្ធផលសិក្សាស្រាវជ្រាវ ឲ្យចំនឹងចំណុចដៅនៃអ្នកទទួលប្រយោជន៍

## តម្រូវការលើកកម្ពស់យុទ្ធសាស្ត្រក្នុងភាពជាដៃគូ ៖ សកម្មភាពស្នើឡើង និងលទ្ធផលរំពឹងទុក

ការយកចិត្តទុកខ្ពស់បំផុតដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបរបស់រាជរដ្ឋាភិបាល ។ ទោះបីជាបទពិសោធន៍ បានបង្ហាញអោយឃើញថា លទ្ធភាពជំនាញបច្ចេកទេសការគ្រប់គ្រង ហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធនៅមានកម្រិត ដើម្បីគាំទ្រក្នុងការបង្កើនប្រសិទ្ធភាពដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ស្ថិតក្នុងពហុវិស័យក៏ដោយ តែត្រូវបានកត់សំគាល់ថា រាល់សកម្មភាពជានិច្ចកាលត្រូវបានអនុវត្តន៍ក្នុងភាពជាដៃគូជាមួយនឹងភ្នាក់ងារគាំទ្រខាងក្រៅ ។ ដូចនេះ អាជ្ញាធរទន្លេសាប នឹងពង្រឹងពង្រីកភាពជាដៃគូជាមួយនឹងកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ព្រមជាមួយនឹងភ្នាក់ងារខាងក្រៅ ដើម្បីសម្រេចឲ្យបានជោគជ័យនូវរាល់សកម្មភាពដែលបានលើកឡើង ៖

- ជម្រុញលើកកម្ពស់យុទ្ធសាស្ត្រក្នុងភាពជាដៃគូជាមួយនឹងដៃគូអភិវឌ្ឍន៍ ដូចជា ម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល វិទ្យាស្ថានបច្ចេកទេសស្រាវជ្រាវ ។ល។ រួមជាមួយ ការអនុវត្តស្នូល និង ការផ្សព្វផ្សាយ (significant outreach) ទៅដល់អ្នកប្រើប្រាស់ តាមរយៈក្រុមការងារបង្គោលប្រចាំតាមក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ
- រៀបចំទម្រង់បែបបទក្នុងភាពជាដៃគូ ដោយការឯកភាពលើកិច្ចព្រមព្រៀង ដូចជា ៖ ការចុះអនុសារណៈយោគយល់គ្នា
- កំណត់ និងរៀបចំបង្កើតភាពជាដៃគូជាមួយនឹងភ្នាក់ងារខាងក្រៅដែលមានសក្តានុពល
- កំណត់ និងរៀបចំបង្កើតនូវភាពទំនាក់ទំនងក្នុងក្របខ័ណ្ឌតំបន់ និងបណ្តាញការងារ

លទ្ធផលរំពឹងទុកសំខាន់ៗ រួមមាន ៖

- យុទ្ធសាស្ត្រភាពជាដៃគូ បានបង្កើតឡើងជាមួយនឹងភ្នាក់ងារពាក់ព័ន្ធ ជាពិសេសជាមួយ ក្រសួង ស្ថាប័ននិងខេត្តពាក់ព័ន្ធ
- សក្តានុពលកិច្ចអភិវឌ្ឍន៍ខាងក្រៅ និងភ្នាក់ងារជំនួយ បានកំណត់ និងបង្កើតភាពជាដៃគូ
- ក្របខ័ណ្ឌ និងបណ្តាញការងារថ្នាក់តំបន់ដែលពាក់ព័ន្ធ បានកំណត់ និងផ្សាភ្ជាប់ទំនាក់ទំនង
- កិច្ចព្រមព្រៀងស្ថិតក្នុងទម្រង់បែបបទ នៃការចុះអនុសារណៈយោគយល់គ្នារវាងអាជ្ញាធរទន្លេសាប ជាមួយនឹងដៃគូដែលត្រូវបានបង្កើតឡើង

## ៦.២.៣. ក្រសួងស្ថាប័នសំខាន់ៗ ដែលពាក់ព័ន្ធនឹងអាជ្ញាធរទន្លេសាប

តារាង ៣ បង្ហាញពីក្រសួង ស្ថាប័ន ដែលត្រូវបានចង្អុលបង្ហាញឲ្យឃើញតាមរយៈតួនាទី ភារកិច្ច ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងអាជ្ញាធរទន្លេសាប នៅក្នុងតំបន់ទន្លេសាប មានតាមផ្នែកខាងក្រោម ៖

- ការអភិវឌ្ឍ និងការកសាងផែនការ
- សវនកម្ម និងតាមដានត្រួតពិនិត្យ (រាល់គម្រោង)
- ធនធានធម្មជាតិ និងបរិស្ថាន

## តារាង ៣ ក្រសួងស្ថាប័នសំខាន់ៗ ដែលពាក់ព័ន្ធ ជាមួយនឹងអាជ្ញាធរទន្លេសាប

| លេខ | ក្រសួង ស្ថាប័ន និងដៃគូ | ការទទួលខុសត្រូវ | ផ្សារភ្ជាប់ជាមួយ/ប្រយោជន៍សម្រាប់ អទស |
|---|---|---|---|
| **ភ្នាក់ងារអភិវឌ្ឍន៍ និងកសាងផែនការ** | | | |
| ១ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (Council Development of Cambodia) | ស្ថាប័នស្នូល និងច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទំនាក់ទំនងជាមួយប្រទេសម្ចាស់ជំនួយ ភ្នាក់ងារ និងអង្គការមិនមែនរដ្ឋាភិបាល | ផ្តល់នូវមូលដ្ឋានទិន្នន័យរបស់គម្រោង ដែលពាក់ព័ន្ធនឹងតំបន់ទន្លេសាបជួយកៀងគរជំនួយបច្ចេកទេស និងថវិកាក្នុងការគាំទ្រដល់អាជ្ញាធរទន្លេសាប |
| ២ | ក្រសួងផែនការ (Ministry of Planning) | កិច្ចសហប្រតិបត្តិការ ដើម្បីរៀបចំនូវយុទ្ធសាស្ត្រ គោលនយោបាយ និងអាទិភាពវិនិយោគឯកជន និងសាធារណៈ | ជួយគាំទ្រដល់អាជ្ញាធរទន្លេសាប ក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃរាល់គម្រោង បាននឹងកំពុង អនុវត្តន៍នៅតំបន់ទន្លេសាបគាំទ្រយុទ្ធសាស្ត្រអាទិភាពរបស់អាជ្ញាធរទន្លេសាប ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគម្រោងវិនិយោគសាធារណៈគាំទ្រដល់ការកសាងសមត្ថភាពមន្ត្រីអាជ្ញាធរទន្លេសាបក្នុងការពង្រឹងសមត្ថភាពកសាងផែនការ និងជំនាញតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោង |
| ៣ | ក្រសួងមហាផ្ទៃ (Ministry of Interior) គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (NCDD) | ការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជា ។ | ជួយគាំទ្រសកម្មភាពការងារដល់អាជ្ញាធរទន្លេសាប ក្នុងការផ្ទេរចំណេះដឹង និងអំណាចក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប |
| ៤ | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (Supreme National Economic Council) | ស្ថាប័នខួរក្បាលគោលនយោបាយអភិវឌ្ឍន៍ សង្គម សេដ្ឋកិច្ចសម្រាប់ប្រមុខរាជរដ្ឋាភិបាល | ជួយគាំទ្រសកម្មភាពការងារដល់អាជ្ញាធរទន្លេសាប ក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប |
| ៥ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម (Ministry of Industry and Handicraft) | គ្រប់គ្រងវិស័យឧស្សាហកម្ម និងសិប្បកម្ម | ជួយគាំទ្រ ដល់អាជ្ញាធរទន្លេសាបក្នុងការផ្តល់ព័ត៌មាន ទិន្នន័យសម្រាប់រៀបចំ និងជំរុញផែនការអភិវឌ្ឍ ឧស្សាហកម្ម សិប្បកម្មខ្នាតតូច និងមធ្យមនៅតំបន់ទន្លេសាប |
| ៦ | ក្រសួងកិច្ចការនារី (Ministry of Women Affair) | សម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិដើម្បីលើកកម្ពស់ស្ថានភាពស្ត្រី | ជួយគាំទ្រដល់អាជ្ញាធរទន្លេសាបក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងអភិវឌ្ឍន៍សម្រាប់ស្ត្រី |

| | | | |
|---|---|---|---|
| ៧ | ក្រសួងអប់រំ យុវជន និង កីឡា ( Ministry of Education, Youth and Sport ) | លើកកម្ពស់វិស័យអប់រំ យុវជន និងកីឡាទាំងគុណភាព និងបរិមាណ ក្នុងទិសដៅអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ជាតិ និងអន្តរជាតិ | ជួយគាំទ្រសកម្មភាពការងាររបស់អាជ្ញាធរទន្លេសាប ក្នុងការលើកកម្ពស់ចំណេះដឹង ការយល់ដឹង និងវិជ្ជាជីវៈផ្សេងៗ ដល់ប្រជាជន នៅតំបន់ទន្លេសាប |
| **ភ្នាក់ងារតាមដានត្រួតពិនិត្យ និងសវនកម្ម** | | | |
| ១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( Ministry of Economic and Finance ) | ត្រួតពិនិត្យ និងតាមដានការចំណាយថវិការបស់ក្រសួង ស្ថាប័ន និងពិនិត្យឃ្លាំមើលពីថវិកាជាតិ | ផ្តល់នូវកញ្ចប់ថវិកា គាំទ្រដល់ផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប និងកៀងគរជំនួយបច្ចេកទេស និងថវិកាសម្រាប់គាំទ្រដល់សកម្មភាព កម្មវិធី/គម្រោងអាទិភាពរបស់អាជ្ញាធរទន្លេសាប |
| ២ | អាជ្ញាធរសវនកម្មជាតិ ( National Audit Authority ) | ស្ថាប័នឯករាជ្យ ក្នុងការចុះសវកម្មទិដ្ឋភាពហិរញ្ញវត្ថុ តាមបណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ទៅលើដំណើរការប្រសិទ្ធភាព និងប្រសិទ្ធផលនៃកម្មវិធី និងគម្រោង | ផ្តល់នូវរបាយការណ៍ទៅវិញទៅមកក្នុងកិច្ចសហការទៅលើការតាមដានពីប្រសិទ្ធភាព និងប្រសិទ្ធផលរបស់គម្រោងនៅតំបន់ទន្លេសាប |
| **ភ្នាក់ងារធនធានធម្មជាតិ និងបរិស្ថាន** | | | |
| ១ | ក្រសួងធនធានទឹក និងឧតុនិយម ( Ministry of Water Resources and Meteorology ) | ការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខមាលភាពរបស់ប្រជាជនទូទាំងប្រទេស | ផ្តល់កិច្ចសហប្រតិបត្តិការក្នុងការទទួលបាននូវព័ត៌មាន ទិន្នន័យពាក់ព័ន្ធ និងគាំទ្រដល់ការកំណត់ដែនវិសាលភាពតំបន់ទន្លេសាបជួយគាំទ្រ និងជម្រុញឲ្យមានផែនការអភិឌ្ឍន៍អាងទន្លេតំបន់ទន្លេសាបជួយគាំទ្រដល់ការកសាងសមត្ថភាពក្នុងការយល់ដឹងពីការគ្រប់គ្រងធនធានទឹកចម្រុះ និងការគ្រប់គ្រងអាងទន្លេ |
| ២ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( Ministry of Agriculture, forestry and fishery ) | ពាក់ព័ន្ធនឹងផ្នែកសំខាន់ ៣ ធំៗ ( កសិកម្ម រុក្ខាមាញ់ និងនេសាទ ) ផ្សាភ្ជាប់ទៅនឹងធនធានធម្មជាតិ និងការអភិវឌ្ឍ | ផ្តល់កិច្ចសហប្រតិបត្តិការក្នុងការទទួលបាននូវព័ត៌មាន ទិន្នន័យជុំវិញធនធានធម្មជាតិ និងកិច្ចអភិវឌ្ឍន៍ជុំវិញតំបន់ទន្លេសាបគាំទ្រដល់ការកសាងសមត្ថភាព |
| ៣ | ក្រសួងបរិស្ថាន ( Ministry of Environment ) | ការគ្រប់គ្រង ការពារធនធានធម្មជាតិ បរិស្ថានប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព តាមរយៈការបង្កើនការយល់ដឹង និងកម្មវិធីអប់រំបរិស្ថាន | ផ្តល់កិច្ចសហប្រតិបត្តិការក្នុងការទទួលបាននូវព័ត៌មាន ទិន្នន័យ ជុំវិញការគ្រប់គ្រង និងការពារធនធានធម្មជាតិ និងបរិស្ថានតំបន់ ទន្លេសាប គាំទ្រដល់ការកសាងសមត្ថភាព |

| | | | |
|---|---|---|---|
| ៤ | ក្រសួងទេសចរណ៍ (Minsitry of Tourism) | រៀបចំគោលនយោបាយ និងផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា | ផ្តល់កិច្ចសហប្រតិបត្តិការក្នុងការទទួលបាននូវព័ត៌មាន ទិន្នន័យក្នុងការពង្រឹងវិស័យទេសចរណ៍ធម្មជាតិនៅតំបន់សំខាន់ៗជុំវិញបឹងទន្លេសាប |
| ៥ | ក្រសួងអភិវឌ្ឍន៍ជនបទ (Ministry of Rural Development) | ផ្តល់នូវសេវាជាមូលដ្ឋានតាមតំបន់ជនបទ បូករួមទាំងការផ្គត់ផ្គង់ទឹក និងអនាម័យ | ផ្តល់កិច្ចសហប្រតិបត្តិការក្នុងការទទួលបាននូវព័ត៌មាន ទិន្នន័យ ជុំវិញនៃការផ្តល់សេវាកម្មជាមូលដ្ឋាន រួមជាមួយនឹងការផ្គត់ផ្គង់ទឹក និងអនាម័យនៅតំបន់ ទន្លេសាបគាំទ្រដល់ការកសាងសមត្ថភាព |
| ៦ | ក្រសួងរ៉ែ និងថាមពល (Ministry of Mines and Energy) | គ្រប់គ្រងវិស័យ ធនធានរ៉ែ និងថាមពល | ផ្តល់កិច្ចសហការដល់អាជ្ញាធរទន្លេសាបក្នុងការទទួលបាននូវព័ត៌មានទិន្នន័យពាក់ព័ន្ធនឹងធនធាន រ៉ែ និងសក្តានុពលនៃការផលិតថាមពលនៅតំបន់សំខាន់ៗជុំវិញបឹងទន្លេសាប |
| ៧ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (Ministry of Land Management Urban Planning and Construction) | គ្រប់គ្រងការងាររៀបចំដែនដី នគររូបនីយកម្ម សំណង់ សូរិយោដី និងភូមិសាស្ត្រ | ផ្តល់កិច្ចសហប្រតិបត្តិការក្នុងការទទួលបាននូវព័ត៌មាន ទិន្នន័យពាក់ព័ន្ធ នឹងការងាររៀបចំដែនដី នគររូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ និងគាំទ្រដល់ការកំណត់ដែនវិសាលភាពតំបន់ទន្លេសាប |
| ៨ | លេខាធិការដ្ឋានឋបនីយជីវមណ្ឌលបឹងទន្លេសាប | ការពារបរិស្ថាន និងគុណប្រយោជន៍ក្នុងការផ្តល់ជាចំណីអាហារសម្រាប់បឹង និងតំបន់ជុំវិញ | បន្តគាំទ្រនូវគោលនយោបាយ និងទិសដៅរបស់ឋបនីយជីវមណ្ឌលបឹងទន្លេសាប ក្នុងការការពារនូវប្រព័ន្ធអេកូឡូស៊ី ជាពិសេសផលិតភាពធនធានជលផល និងជីវៈចម្រុះ តាមរយៈនៃជម្រកធម្មជាតិ |
| ៩ | រដ្ឋបាលជលផល | គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយចិរភាព សម្រាប់ជាវិភាគទានដល់សន្តិសុខស្បៀង និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងការលើកកម្ពស់ការទ្រទ្រង់ជីវភាពរស់នៅ និងវិបុលភាពប្រជាជន | ផ្តល់កិច្ចសហប្រតិបត្តិការក្នុងការទទួលបាននូវព័ត៌មាន ទិន្នន័យ ជុំវិញការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយចិរភាពនៅតំបន់ទន្លេសាបបន្តការគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រ និងគោនយោបាយ កម្មវិធីតំបន់ទន្លេសាបគាំទ្រដល់ការកសាងសមត្ថភាព |
| ១០ | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | ស្ថាប័នស្នូលក្នុងការផ្សាភ្ជាប់រវាងគណៈកម្មការទន្លេមេគង្គជាមួយនឹងរាជរដ្ឋាភិបាល ក្នុងតួនាទីសម្របសម្រួលអន្តរវិស័យ និងកិច្ចសហប្រតិបត្តិការអន្តរភ្នាក់ងារទៅលើបញ្ហាធនធានទឹក ក្នុងកម្រិតជាតិ និងថ្នាក់តំបន់ | ផ្តល់កិច្ចសហប្រតិបត្តិការក្នុងការទទួលបាននូវព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងបញ្ហាធនធានទឹក បម្រែបម្រួលអាកាសធាតុ ក្នុងកម្រិតថ្នាក់ជាតិ និងតំបន់ជួយគាំទ្រ និងជម្រុញឲ្យមានផែនការអភិឌ្ឍន៍អាងទន្លេតំបន់ទន្លេសាបជួយគាំទ្រដល់ការកសាងសមត្ថភាពក្នុងការយល់ដឹងពីការគ្រប់គ្រងធនធានទឹកចម្រុះ និងការគ្រប់គ្រងអាងទន្លេ |

| | | | |
|---|---|---|---|
| ១១ | ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សម្របសម្រួលការអភិវឌ្ឍគោលនយោបាយពាក់ព័ន្ធដល់វិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ក្នុងកម្រិតក្រសួង | ផ្តល់កិច្ចសហប្រតិបត្តិការក្នុងការទទួលបាននូវព័ត៌មាន ទិន្នន័យ ជុំវិញការអភិវឌ្ឍគោលនយោបាយពាក់ព័ន្ធដល់វិស័យកសិកម្ម និងការអភិវឌ្ឍជនបទនៅតំបន់ទន្លេសាបគាំទ្រដល់ការកសាងសមត្ថភាព |
| ១២ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ( National Committee of Disaster Management ) | សម្របសម្រួលគ្រប់គ្រងការងារ គ្រោះមហន្តរាយ | ផ្តល់កិច្ចសហប្រតិបត្តិការក្នុងការទទួលបាននូវព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងភាពងាយរងគ្រោះរបស់ប្រជាជននៅជុំវិញតំបន់ទន្លេសាប បង្ករឡើងដោយគ្រោះមហន្តរាយផ្សេងៗ |

## ៧. ថវិកាសម្រាប់ផែនការយុទ្ធសាស្ត្រ

ថវិកាប៉ាន់ស្មាន សម្រាប់អនុវត្តន៍ផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ ត្រូវបានសង្ខេបនៅក្នុងតារាងទី ៤ ខាងក្រោម ។ ថវិកាប៉ាន់ស្មានសរុបចំនួន ២៧,០២៥,០០០,០០០ រៀល (ប្រហែល ៦,៧៥៦,២៥០ ដុល្លារសហរដ្ឋអាមេរិក) ដែលក្នុងនោះថវិកា អាចរកបានសរុបចំនួន ១២,០០០,០០០,០០០ រៀល (ប្រហែល ៣,០០០,០០០ ដុល្លារសហរដ្ឋអាមេរិក) ត្រូវជា ៤៤% ពីប្រភពថវិការដ្ឋ ។ ដោយឡែកថវិកានៅសល់សរុបចំនួន ១៥,០២៥,០០០,០០០ រៀល (ប្រហែល ៣,៧៥៦,២៥០ ដុល្លារសហរដ្ឋអាមេរិក) ត្រូវជា ៥៦% នឹងត្រូវខិតខំស្វែងរកការគាំទ្របន្ថែមពីដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធនានា ។

អាជ្ញាធរទន្លេសាប នឹងរៀបចំនូវតារាងប៉ាន់ស្មានតម្រូវការថវិកាលម្អិតប្រចាំឆ្នាំ ដោយយោងទៅនឹងសកម្មភាពការងារជាមូលដ្ឋាន ។ សកម្មភាពការងារនេះ នឹងត្រូវកំណត់ច្បាស់លាស់នៅក្នុងផែនការសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដោយបន្សុីគ្នាទៅនឹងទិសដៅជាយុទ្ធសាស្ត្រ (ដូចក្នុងតារាង ២) នៃផែនការយុទ្ធសាស្ត្រ ដែលនឹងត្រូវបានគាំទ្រថវិកាតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការកៀងគរទាំងជំនួយបច្ចេកទេស ថវិកាពីដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ អង្គការជាតិ និងអន្តរជាតិសំខាន់ៗ ។

# តារាង ៤ សង្ខេបការប៉ាន់ស្មានថវិកា

| សកម្មភាព/គម្រោង | ការប៉ាន់ស្មានថវិកា (គិតជា លានរៀល) | | | | | | |
|---|---|---|---|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | សរុប | ភាគរយ |
| ១. ពង្រឹងគោលនយោបាយ បទបញ្ញត្តិ និងស្ថាប័ន | ១,១២៥ | ១,១២៥ | ១,១១០ | ១,២៥០ | ១,៣២០ | ៥,៩៣០ | ២៣% |
| ២. ពង្រឹងការយល់ដឹងជាមូលដ្ឋានអំពីការគ្រប់គ្រងតំបន់ទន្លេសាប | ១,៣៦០ | ១,៣៤៥ | ១,៣០៥ | ១,៣០៥ | ១,៣០៥ | ៦,៦២០ | ២៤% |
| ៣. សម្របសម្រួល កសាងផែនការ និងគ្រប់គ្រង | ៤៧០ | ៤៧០ | ៦៦០ | ៧៩០ | ៨៨០ | ៣,២៧០ | ១២% |
| ៤. ការទំនាក់ទំនង និងការកសាងសមត្ថភាពភាគីពាក់ព័ន្ធ | ៣៩៥ | ៣៦៥ | ៣៣៥ | ២៥០ | ២៥០ | ១,៥៩៥ | ៦% |
| ៥. ការប្រតិបត្តិរបស់អាជ្ញាធរទន្លេសាប ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព | ២,០២២ | ១,៨៣៧ | ១,៨៧២ | ១,៨៨២ | ១,៩៩៧ | ៩,៦១០ | ៣៥% |
| **សរុប** | **៥,៣៧២** | **៥,១៤២** | **៥,២៨២** | **៥,៤៧៧** | **៥,៧៥២** | **២៧,០២៥** | **១00%** |
| | | | | | | | |
| ថវិកាដែលអាចរកបាន (ថវិការដ្ឋ) | **៤,000** | **៤,000** | **៤,000** | **0** | **0** | **១២,000** | **៤៤%** |
| ថវិកាកៀងគរបំពេញបន្ថែម | **១,៣៧២** | **១,១៤២** | **១,២៨២** | **៥,៤៧៧** | **៥,៧៥២** | **១៥,០២៥** | **៥៦%** |

## ៨. តាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រ

អាជ្ញាធរទន្លេសាប នឹងទទួលខុសត្រូវសម្រាប់ការរៀបចំ និងដាក់ស្នើសុំការអនុម័តនូវរបាយការណ៍ដូចខាងក្រោម ដែលជាទម្រង់បែបបទផ្នែកមួយនៃដំណើរការតាមដានត្រួតពិនិត្យ ៖

ការតាមដានត្រួតពិនិត្យនូវវឌ្ឍនភាពការអនុវត្ត នឹងត្រូវទទួលខុសត្រូវដោយអាជ្ញាធរទន្លេសាប ផ្អែកលើផែនការសកម្មភាពប្រចាំឆ្នាំ និងលទ្ធផលរំពឹងទុកជាមួយនឹងការគាំទ្រពី**ក្រុមការងារបង្គោលថ្នាក់ជាតិ** ។ អាជ្ញាធរទន្លេសាប នឹងជូនព័ត៌មានដល់គណៈកម្មការជំនាញអំពីការខកខាន (ការពន្យាពេល) ឬការលំបាកប្រឈមនៅពេលអនុវត្តន៍ ការដែលធ្វើបែបនេះ គឺអាចគាំទ្រ ឬអាចមានមធ្យោបាយកែសម្រួលដែលអាចអនុម័តបានទាន់ពេលវេលា ។

រយៈពេលតាមដានត្រួតពិនិត្យនូវវឌ្ឍនភាពក្នុងការអនុវត្ត នឹងត្រូវបានកំណត់ដោយអាជ្ញាធរទន្លេសាប តាមរយៈការផ្តល់នូវរបាយការណ៍នៅពាក់កណ្តាលឆ្នាំ (៦មាស) នីមួយៗ ដើម្បីដាក់ស្នើសុំការអនុម័តទៅគណៈកម្មការជំនាញ និងដៃគូសំខាន់ៗ ។

ការតាមដានត្រួតពិនិត្យប្រចាំឆ្នាំ នឹងអនុវត្តន៍តាមរយៈការរៀបចំនូវរបាយការណ៍ប្រចាំឆ្នាំ ដោយអាជ្ញាធរទន្លេសាប ។

របាយការណ៍បញ្ចប់៖ ក្នុងអំឡុងពេល ៣ ខែចុងក្រោយ នៃការអនុវត្តផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប នឹងរៀបចំនូវរបាយការណ៍បញ្ចប់ផែនការយុទ្ធសាស្ត្រ ។ របាយការណ៍ប្រកបដោយខ្លឹមសារ នឹងសង្ខេបរាល់សកម្មភាព លទ្ធផលសម្រេចបាន និងធាតុចេញ (Output) នៃផែនការយុទ្ធសាស្ត្រ បទពិសោធន៍ទិសដៅ ឬក៏ភាពមិនអាចសម្រេចតាមទិសដៅ រចនាសម្ព័ន្ធ និងប្រព័ន្ធការងារ ដែលបានអនុវត្តន៍ ។ល។ វានឹងទៅជាការរៀបរាប់បរិយាយពីសកម្មភាពរបស់ផែនការ ក្នុងអំឡុងពេលកម្មវិធីការងារ ហើយក៏នឹងត្រូវបានស្នើសុំឲ្យមានជាអនុសាសន៍សម្រាប់ជំហានបន្តបន្ទាប់ទៀត ដែលអាចទាមទាឲ្យមានការយកចិត្តទុកដាក់ចំពោះរាល់សកម្មភាពរបស់អាជ្ញាធរទន្លេសាប ។

របាយការណ៍បច្ចេកទេស ៖ របាយការណ៍បច្ចេកទេស ត្រូវតែជាឯកសារបច្ចេកទេសលម្អិតគ្របដណ្តប់ដោយចំនុចវិភាគសំខាន់ៗ ឬភាពសំខាន់មានលក្ខណៈបច្ចេកទេស ស្ថិតក្នុងផែនការយុទ្ធសាស្ត្រទាំងស្រុង ។ របាយការណ៍បច្ចេកទេស នឹងត្រូវរៀបចំឡើងដោយអាជ្ញាធរទន្លេសាប និងទីប្រឹក្សាខាងក្រៅ ដែលប្រកបដោយខ្លឹមសារ ត្រូវបានធ្វើការវិភាគច្បាស់លាស់ ដោយបានកំណត់នូវតំបន់សិក្សាស្រាវជ្រាវ ស្ថិតក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រ ។ របាយការណ៍បច្ចេកទេស នឹងបង្ហាញពីនូវខ្លឹមសារសំខាន់ៗប្រកបដោយអត្ថន័យសមរម្យ ការផ្តល់នូវភាពជាក់លាក់របស់ផែនការយុទ្ធសាស្ត្រ ដើម្បីកំណត់ពីតំបន់នីមួយៗ ហើយនឹងត្រូវយកទៅប្រើប្រាស់ក្នុងការផ្សព្វផ្សាយជាព័ត៌មានដល់អ្នកពាក់ព័ន្ធ ។

ការបោះពុម្ពផ្សព្វផ្សាយ អាជ្ញាធរទន្លេសាប ៖ ការបោះពុម្ពផ្សព្វផ្សាយ នឹងត្រូវរៀបចំឡើងជាទម្រង់ទ្រឹស្តីគន្លឹះប្រកបដោយភាពជាក់លាក់ ផ្សព្វផ្សាយពីលទ្ធផល និងការសម្រេចបាននូវផែនការយុទ្ធសាស្ត្រ ។ ការបោះពុម្ពផ្សព្វផ្សាយ អាចជាឯកសារមានលក្ខណៈបច្ចេកទេស ដែលមានព័ត៌មានជាក់លាក់ ស្តីពីសកម្មភាព និងការសម្រេចបាននូវផែនការយុទ្ធសាស្ត្រ ក្នុងទម្រង់បែបបទជាមាតិកាសារព័ត៌មាន ការបោះពុម្ពផ្សព្វផ្សាយទៅគ្រប់

បណ្តាញព័ត៌មាន ។ល។ ការបោះពុម្ពផ្សព្វផ្សាយនេះ ត្រូវផ្អែកលើរបាយការណ៍បច្ចេកទេស អាស្រ័យលើ របាយការណ៍ដែលពាក់ព័ន្ធ និងខ្លឹមសារសារៈសំខាន់ ដែលមានលក្ខណៈជាវិទ្យាសាស្ត្រ ។ល។ ឬអាចធ្វើជាសង្ខេប ឬភាពប្រទាក់ក្រឡាគ្នានៃរបាយការណ៍បច្ចេកទេស ។ អាជ្ញាធរទន្លេសាប នឹងកំណត់ច្បាស់លាស់ ប្រសិនបើរបាយការណ៍ណាមួយមានលក្ខណៈត្រឹមត្រូវ បោះពុម្ពផ្សព្វផ្សាយជាផ្លូវការ ហើយក៏នឹងស្ថិតក្នុងការប្រឹក្សាយោបល់ជាមួយនឹងរាជរដ្ឋាភិបាល និងក្រុមការងារភាគីពាក់ព័ន្ធផ្សេងៗទៀតផងដែរ ដែលគ្រោង និងផលិតនូវការបោះពុម្ពផ្សព្វផ្សាយក្នុងទម្រង់ដែលមានការស្រុះស្រួល និងទទួលស្គាល់ជាផ្លូវការ ។

ផែនការយុទ្ធសាស្ត្រ នឹងក្លាយជាប្រធានបទវាយតម្លៃឯករាជ្យខាងក្រៅយ៉ាងហោចណាស់ ចំនួន ២ ដូចខាងក្រោម ៖

- ការវាយតម្លៃពាក់កណ្តាលអាណត្តិ ៖ ការវាយតម្លៃឯករាជ្យពាក់កណ្តាលអាណត្តិ នឹងត្រូវកំណត់នៅចុងឆ្នាំទី ៣ នៃការអនុវត្ត ។ ការវាយតម្លៃពាក់កណ្តាលអាណត្តិ នឹងកំណត់ពីវឌ្ឍនភាពដែលបានអនុវត្តន៍ សំដៅឆ្ពោះទៅសម្រេចឲ្យបាននូវលទ្ធផល (Outcome) ហើយនឹងកំណត់ពីដំណើរការកែសម្រួល ប្រសិនបើចាំបាច់ ។ វា នឹងផ្តោតលើប្រសិទ្ធភាព ប្រសិទ្ធផល និងពេលវេលានៃការអនុវត្តផែនការយុទ្ធសាស្ត្រ ហើយនឹងកំណត់ពីបញ្ហា ក្នុងការទាមទាឲ្យមានការសម្រេចចិត្ត និងសកម្មភាពដ៏ត្រឹមត្រូវ ហើយនឹងបង្ហាញពីការផ្តួចផ្តើមនូវបទពិសោធន៍ អំពីការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងផែនការយុទ្ធសាស្ត្រ ។ របកគំហើញចេញពីការត្រួតពិនិត្យឡើងវិញ នឹងត្រូវបញ្ចូលជាអនុសាសន៍ សម្រាប់ពង្រឹងការអនុវត្តបន្តក្នុងដំណាក់កាលពាក់កណ្តាលចុងបញ្ចប់នៃការអនុវត្តផែនការយុទ្ធសាស្ត្រ ។
- ការវាយតម្លៃចុងបញ្ចប់ ៖ ការវាយតម្លៃឯករាជ្យចុងបញ្ចប់ នឹងអនុវត្តន៍ក្នុងរយៈពេល ៣ ខែ មុននឹងបញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រ ។ ការវាយតម្លៃចុងបញ្ចប់ នឹងត្រូវគិតគូរពិចារណា ផងដែរ ចំពោះផលប៉ះពាល់ និងលទ្ធផលប្រកបដោយនិរន្តរភាព រួមបញ្ចូលទាំងការសម្រេច បាននូវបេសកកម្មការងាររបស់អាជ្ញាធរទន្លេសាប ។ ការវាយតម្លៃចុងបញ្ចប់ នឹងផ្តល់ជូនបន្ថែមនូវអនុសាសន៍ សម្រាប់តាមដានរាល់សកម្មភាពអនុវត្តន៍ ។

## ឧបសម្ព័ន្ធ ១ ៖ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ស្ដីពីការបង្កើតអាជ្ញាធរទន្លេសាប

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៧០៥

### ស្ដីពី

### ការបង្កើតអាជ្ញាធរទន្លេសាប

### យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

- ១ -

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាប
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតអាជ្ញាធរមួយ សម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប មានឈ្មោះថា **អាជ្ញាធរទន្លេសាប** ដែលហៅជាអក្សរកាត់ថា **អ.ទ.ស.** ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល។

**មាត្រា ២.-**

វិសាលភាពនៃតំបន់ទន្លេសាប ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ជំពូកទី ២
## សមាសភាព

**មាត្រា ៣.-**

**អ.ទ.ស.** មានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| - ឧបនាយករដ្ឋមន្ត្រី ឬ ទេសរដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី | | ប្រធាន |
| - ឥស្សរជនជាន់ខ្ពស់មួយចំនួន | | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងផែនការ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | សមាជិក |
| - អនុប្រធាន ឬអគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ០១រូប | សមាជិក |
| - ប្រធាន ឬអនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | ០១រូប | សមាជិក |
| - ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | | សមាជិក |
| - អគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | | សមាជិក |
| - អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា | | សមាជិក |

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- អគ្គនាយកអាជ្ញាធរអប្សរា សមាជិក
- អភិបាលខេត្តកំពង់ឆ្នាំង សមាជិក
- អភិបាលខេត្តពោធិ៍សាត់ សមាជិក
- អភិបាលខេត្តបាត់ដំបង សមាជិក
- អភិបាលខេត្តបន្ទាយមានជ័យ សមាជិក
- អភិបាលខេត្តសៀមរាប សមាជិក
- អភិបាលខេត្តកំពង់ធំ សមាជិក
- អភិបាលខេត្តកំពង់ចាម សមាជិក
- អភិបាលខេត្តកណ្តាល សមាជិក។

សមាសភាពជាក់ស្តែងរបស់ **អ.ទ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី ៣
## ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ អ.ទ.ស.

**មាត្រា ៤._**

**អ.ទ.ស.** មានតួនាទី ភារកិច្ច សម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប ដូចតទៅ៖

- ជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាលលើរាល់គម្រោង ដោយធ្វើការសិក្សាស្រាវជ្រាវ ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងផ្សេងៗ
- សម្របសម្រួលរាល់សកម្មភាព ដែលកំពុងអនុវត្ត គ្រោងនឹងអនុវត្ត របស់ក្រសួងស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា ដែលមាននៅក្នុងតំបន់ទន្លេសាប ដើម្បីឱ្យការងារមានភាពរលូនជាមួយគ្នាប្រកបដោយប្រសិទ្ធភាព
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនានា ដើម្បីជំរុញឱ្យប្រតិបត្តិករពាក់ព័ន្ធអនុវត្តស្របតាមយុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាល
- ធ្វើជាតំណាងរាជរដ្ឋាភិបាលក្នុងសកម្មភាពការងាររួមមាន កិច្ចប្រជុំ ការចរចា និងការដោះស្រាយរាល់បញ្ហាដែលអាចកើតមានជាយថាហេតុ
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ កិច្ចសន្យាទាំងឡាយ ក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ជាសមភាគីជាមួយគ្រប់ដៃគូអភិវឌ្ឍទាំងអស់ក្នុងការរួមគ្នាពិចារណា ដើម្បីកំណត់សកម្មភាពដែលត្រូវអនុវត្ត
- ប្រមូល វិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យ ដើម្បីផ្សព្វផ្សាយ និងចែករំលែកដល់អ្នកពាក់ព័ន្ធ
- អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធ
- រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីសកម្មភាពការងារសំខាន់ៗ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា ៥.-**

**អ.ទ.ស.** មានគណៈកម្មាធិការប្រតិបត្តិមួយ សម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ដោយមានការណែនាំ និងចង្អុលទិសពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាព ដូចតទៅ៖

| | |
|---|---|
| - ប្រធាន អ.ទ.ស. | ប្រធាន |
| - អនុប្រធាន អ.ទ.ស. | អនុប្រធាន |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក |
| - អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក។ |

**មាត្រា ៦.-**

**អ.ទ.ស.** ដឹកនាំដោយប្រធានមួយរូប មានឋានៈទាបបំផុតស្មើរដ្ឋមន្ត្រីជាអ្នកទទួលខុសត្រូវរួមចំពោះមុខរាជរដ្ឋាភិបាល អមដោយអនុប្រធាន និងទីប្រឹក្សាមួយចំនួនជាជំនួយការ។

**មាត្រា ៧.-**

**អ.ទ.ស.** មានអគ្គលេខាធិការដ្ឋានមួយ សម្រាប់ដំណើរការការងារប្រចាំថ្ងៃ និងចាត់ការទូទៅលើការងារសម្របសម្រួល ទំនាក់ទំនង និងសហការរវាង ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព។

អគ្គលេខាធិការដ្ឋាន **អ.ទ.ស.** ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើរដ្ឋលេខាធិការអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ។

អគ្គលេខាធិការដ្ឋានត្រូវអនុវត្តការងារទៅតាមការណែនាំរបស់ប្រធាន។

**មាត្រា ៨.-**

ដើម្បីបំពេញការងាររបស់ខ្លួន ជូនរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ **អ.ទ.ស.** ត្រូវមានតំណាង[illegible]ជាន និងផ្តល់យោបល់នៅក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងអង្គប្រជុំអន្តរក្រសួងផ្សេងៗ ពាក់ព័ន្ធនឹង[illegible]ការងារទន្លេសាបដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី ឬដោយក្រសួង ស្ថាប័ននានា។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

**អ.ទ.ស.** មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់នៃក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធនានា ឬឥស្សរជនដែលមានបទពិសោធ និងសមត្ថភាពខ្ពស់ ដើម្បីចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួន។

ក្នុងរយៈពេល ៣ (បី) ខែ **អ.ទ.ស.** ត្រូវកោះប្រជុំសាមញ្ញម្តង។ ក្នុងករណីចាំបាច់ ប្រធាន **អ.ទ.ស.** ឬគណៈកម្មាធិការប្រតិបត្តិនៃ **អ.ទ.ស.** អាចកោះប្រជុំវិសាមញ្ញ។ ករណីប្រធានអវត្តមាន អនុប្រធានមានសិទ្ធិពេញលេញក្នុងការដឹកនាំកិច្ចប្រជុំតាមការណែនាំរបស់ប្រធាន។

ក្នុងរយៈពេល ១ (មួយ) ខែ គណៈកម្មាធិការប្រតិបត្តិនៃ **អ.ទ.ស.** ត្រូវប្រជុំសាមញ្ញម្តង។

**មាត្រា ៩.-**

ការតែងតាំងមន្ត្រីរាជការ ការរៀបចំប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន **អ.ទ.ស.** ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ១០.-**

**អ.ទ.ស.** មានសិទ្ធិប្រើត្រាដោយឡែក និងមានទីស្នាក់ការកំណត់ដោយទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ១១.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ទ.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី ៤
## ប្រភពធនធានថវិកា

**មាត្រា ១២.-**

ប្រភពធនធានថវិការបស់ **អ.ទ.ស.** សម្រាប់បំពេញការងាររបស់ខ្លួន បានមកពី ៖

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល។

**អ.ទ.ស.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពក្នុង ឬក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការ ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ជំពូកទី ៥

អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

ព្រះរាជក្រឹត្យនេះជំនួសព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការបង្កើតអាជ្ញាធរអាងទន្លេសាប ដែលត្រូវបាននិរាករណ៍។

**មាត្រា ១៤.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.០៩០៦.៧៦៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៧៤០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

- ៧ -

**ឧបសម្ព័ន្ធ ២ ៖ ព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ស្តីពីការកែសម្រួល មាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប**

## ព្រះរាជក្រឹត្យ

នស/រកត/០៣១០/២៥៩

**ស្តីពី**

**ការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២**
**នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩**
**ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

ROYAUME DU CAMBODGE · MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

១

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងបំរុងជីវមណ្ឌលបឹងទន្លេសាប

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ.-**

ត្រូវបានកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប ដូចតទៅ ៖

**មាត្រា៣ថ្មី.-**

**អ.ទ.ស.** មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| -ឧបនាយករដ្ឋមន្ត្រី ឬ ទេសរដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី | | ប្រធាន |
| -ឥស្សរជនជាន់ខ្ពស់មួយចំនួន | | អនុប្រធាន |
| -ឥស្សរជនជាន់ខ្ពស់ | ០១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១រូប | សមាជិក |

២

| | | |
|---|---|---|
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងផែនការ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | សមាជិក |
| -រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| -អនុប្រធាន ឬអគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ០១រូប | សមាជិក |
| -ប្រធាន ឬអនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | ០១រូប | សមាជិក |
| -តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | | សមាជិក |
| -អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | | សមាជិក |
| -អគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | | សមាជិក |
| -អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា | | សមាជិក |
| -អគ្គនាយកអាជ្ញាធរអប្សរា | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកណ្តាល | | សមាជិក |

សមាសភាពជាក់ស្តែងរបស់ **អ.ទ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា៥ថ្មី.-**

**អ.ទ.ស.** មានគណៈកម្មាធិការប្រតិបត្តិមួយ សម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| -ប្រធាន អ.ទ.ស. | ប្រធាន |
| -អនុប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ អ.ទ.ស. | អនុប្រធាន |
| -អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក |
| -អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក។ |

**មាត្រា៦ថ្មី.-**

**អ.ទ.ស.** ដឹកនាំដោយប្រធានមួយរូប ជាអ្នកទទួលខុសត្រូវរួមចំពោះមុខរាជរដ្ឋាភិបាល អមដោយអនុប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ ព្រមទាំងទីប្រឹក្សាមួយចំនួនជាជំនួយការ។

**មាត្រា៩ថ្មី.-**

ការតែងតាំងមន្ត្រីរាជការ ការរៀបចំប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន **អ.ទ.ស.** ជាបន្ទុករបស់ក្រសួងធនធានទឹក និងឧតុនិយម។

**មាត្រា១០ថ្មី.-**

**អ.ទ.ស.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន។

**មាត្រា១២ថ្មី.-**

ប្រភពធនធានថវិការបស់ **អ.ទ.ស.** សម្រាប់បំពេញការងាររបស់ខ្លួន បានមកពី ៖

-ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំ របស់ក្រសួងធនធានទឹក និងឧតុនិយម

-អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា

-ជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល។

**អ.ទ.ស.**មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពក្នុងស្រុកនិងក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មាត្រា៧.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ២០១០

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

៣/ល.១០០៣.២៦១

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**លេខ: ៧៥៨ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មិនា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**យុន ជិនគេន**

## ឧបសម្ព័ន្ធ ៣ ៖ អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការនៃអាជ្ញាធរទន្លេសាប

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:..១១៦...អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តទៅ**

**របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៦០៩ / ៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរទន្លេសាប

**សម្រេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ( **អ.ទ.ស** ) ។

## ជំពូកទី ២
## តួនាទី និង ភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ( **អ.ទ.ស** ) មានតួនាទី និង ភារកិច្ច ដូចតទៅ :

- ទទួលបន្ទុកដឹកនាំ ចាត់ចែង និងសម្របសម្រួល រាល់សកម្មភាពការងារ ប្រចាំថ្ងៃរបស់ **អ.ទ.ស**
- សិក្សាស្រាវជ្រាវ អំពីសក្តានុពលធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ ត្រួតពិនិត្យ វាយតម្លៃ និងតាមដាន លើការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ និងធ្វើវិភាគនូវរាល់ព័ត៌មាន និងសកម្មភាពជាក់ស្តែង ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ ចំពោះមុខ និងយូរអង្វែង ជូនរាជរដ្ឋាភិបាល ក្នុងការកំណត់ទិសដៅគោលដៅបម្រើដល់កិច្ចអភិវឌ្ឍន៍ និងអភិរក្ស
- រៀបចំគោលនយោបាយ ទស្សនវិស័យ បេសកកម្មរបស់អាជ្ញាធរទន្លេសាប
- សម្របសម្រួល និងសហការ ជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា លើរាល់សកម្មភាពទាក់ទងនឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ ក្នុងតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព
- សហការ ជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីគម្រោងអភិរក្ស អភិវឌ្ឍន៍ផ្សេងៗ ដែលមាននៅក្នុងតំបន់ទន្លេសាប
- រៀបចំចងក្រងឯកសារទិន្នន័យ ព័ត៌មាន ដើម្បីអប់រំផ្សព្វផ្សាយ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនប្រធាន **អ.ទ.ស**
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាន **អ.ទ.ស** ប្រគល់ជូន ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ និង ការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ( **អ.ទ.ស** ) មានរចនាសម្ព័ន្ធ ដូចខាងក្រោម :

១- នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ

២- នាយកដ្ឋានធនធានធម្មជាតិ

៣- នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស

៤- នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ។

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

**មាត្រា ៤.-**

នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ មានតួនាទី និងភារកិច្ច ដូចតទៅ :

- ទទួលខុសត្រូវលើសេវាកម្មរដ្ឋបាលទូទៅ និងសម្របសម្រួលការងាររដ្ឋបាល ជូនគ្រប់អង្គភាពនៅក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស**
- ទទួលខុសត្រូវលើការងារសំណុំលិខិត ឯកសារ លិខិតបទដ្ឋានគតិយុត្តិ ឯកសារសម្ងាត់ ការងារតម្កល់ឯកសារ ពិធីការ សណ្តាប់ធ្នាប់ និងអនាម័យ
- គ្រប់គ្រងឯកសារ និងក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិក និងរៀបចំប្រវត្តិរូប ប្រាក់ឧបត្ថម្ភផ្សេងៗ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារ: និងបញ្ជីសារពើភ័ណ្ឌ របស់ **អ.ទ.ស**
- រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្ស
- រៀបចំគម្រោងផែនការថវិកា សម្ភារ: និងមធ្យោបាយនានា របស់ **អ.ទ.ស**
- រៀបចំគោលនយោបាយយុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាព រយៈពេលខ្លី មធ្យម និងវែង សម្រាប់បម្រើដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព
- តាមដាន វាយតម្លៃ ប្រសិទ្ធិភាពនៃការអនុវត្តផែនការសកម្មភាព
- សម្របសម្រួល សហការ ជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ
- រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៥.-**

នាយកដ្ឋានធនធានធម្មជាតិ មានតួនាទី និងភារកិច្ច ដូចតទៅ :

- សិក្សាស្រាវជ្រាវពីសក្តានុពលទឹក និងការប្រែប្រួលអាកាសធាតុ ព្រមទាំងកត្តាផ្សេងៗទៀតដែលនាំឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីធនធានមច្ឆជាតិ ធនធានព្រៃលិចទឹក ធនធានរ៉ែ និងធនធានជីវចម្រុះផ្សេងៗទៀត ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីសក្តានុពលទឹក-ដី ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ពិនិត្យ និងផ្តល់យោបល់ លើការស្នើសុំប្រើប្រាស់ទូវរាល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៦.-**

នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស មានតួនាទី និងភារកិច្ច ដូចតទៅ :

- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ លើការធ្វើអាជីវកម្មធនធានទឹក-ដី ធនធានមច្ឆជាតិ ធនធានរ៉ែ ធនធានជីវចម្រុះផ្សេងៗទៀត ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ លើការប្រើប្រាស់រាល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ ព័ត៌មាន វិភាគ ដើម្បីកំណត់តំបន់អភិរក្សធនធានទឹក ធនធានព្រៃលិចទឹក ធនធានមច្ឆជាតិ ធនធានរ៉ែ និងធនធានជីវចម្រុះផ្សេងៗទៀត ដើម្បីបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំផែនទី សម្រាប់បម្រើដល់ការគ្រប់គ្រង ការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៧.-**

នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ មានតួនាទី និងភារកិច្ច ដូចតទៅ :

- ប្រមូលចងក្រង និងសិក្សាស្វែងយល់នូវរាល់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលមានការពាក់ព័ន្ធ
- ទទួលពាក្យបណ្តឹង និងសម្រុះសម្រួលនូវរាល់វិវាទនានា ដែលកើតមានឡើងក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ចូលរួមផ្តល់យោបល់ លើការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ ដែលមានការពាក់ព័ន្ធ
- រៀបចំពិធីសារ អនុស្សរណៈ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ
- ផ្សព្វផ្សាយព័ត៌មាន ទាំងវិជ្ជមាន ទាំងអវិជ្ជមាន សំដៅបម្រើឱ្យកិច្ចអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព
- សហការ ជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស** មានមន្ត្រីបម្រើការងារ មកពីក្របខ័ណ្ឌមុខងារសាធារណៈ ។ ក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស** អាចមានអ្នកជំនាញការ ឬបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងាររបស់ខ្លួន ។

ការបែងចែកលំអិត អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ទ.ស** ។

**មាត្រា ៩.-**

ការរៀបចំ និងការប្រព្រឹត្តទៅ របស់បណ្តានាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស** ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន **អ.ទ.ស** ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរទន្លេសាប រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ ៤ ៖ ប្រកាសលេខ ០២៥ អទស ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ ការិយាល័យចំណុះបណ្តានាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរទន្លេសាប**

លេខ :...០២៥...អទស

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០០៩

**ប្រកាស**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តិទៅ របស់ការិយាល័យចំណុះបណ្តានាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប**

**ប្រធានអាជ្ញាធរទន្លេសាប**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញសេចក្តីសម្រេចលេខ ៤១ សសរ ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពី ការតែងតាំងសមាសភាពរបស់អាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- យោងតាមការចាំបាច់របស់អាជ្ញាធរទន្លេសាប

**ស ម្រេ ច**

**ប្រការ ១.**

ត្រូវបានកំណត់អំពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់បណ្តានាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប រួមមាន :

- នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ
- នាយកដ្ឋានធនធានធម្មជាតិ
- នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស
- នាយកដ្ឋានទីតិកម្ម និងផ្សព្វផ្សាយ ។

១

**ប្រការ ២.**

នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ មានរចនាសម្ព័ន្ធ ដូចខាងក្រោម :

ក- ការិយាល័យរដ្ឋបាល

ខ- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

គ- ការិយាល័យផែនការ និងសហប្រតិបត្តិការ

ឃ- ការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ក-ការិយាល័យរដ្ឋបាល** មានភារកិច្ច :

- ផ្តល់សេវាកម្មរដ្ឋបាល និងសម្របសម្រួលការងាររដ្ឋបាលក្នុងអគ្គលេខាធិការដ្ឋាននៃ អ.ទ.ស
- រៀបចំតាក់តែងលិខិតរដ្ឋបាល ទទួលចុះលេខលិខិតចេញ-ចូល និងបែងចែកឯកសារ
- គ្រប់គ្រងរាល់សំណុំលិខិត ឯកសារ លិខិតបទដ្ឋានគតិយុត្តិ និងឯកសារសម្ងាត់នានា
- សម្របសម្រួលរៀបចំចាត់ចែងកិច្ចប្រជុំនានារបស់ អ.ទ.ស
- គ្រប់គ្រងបណ្តាញទំនាក់ទំនង ទឹក-ភ្លើង សណ្តាប់ធ្នាប់ និងអនាម័យក្នុងអគ្គលេខាធិការដ្ឋាននៃ អ.ទ.ស
- រៀបចំរបាយការណ៍បូកសរុបសកម្មភាពការងាររបស់នាយកដ្ឋាន
- បំពេញការងារចាំបាច់តាមការណែនាំពីប្រធាននាយកដ្ឋាន ឬអគ្គលេខាធិការ អ.ទ.ស
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ខ- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ** មានភារកិច្ច :

- រៀបចំគម្រោងផែនការថវិកា សម្ភារៈ និងមធ្យោបាយនានារបស់ អ.ទ.ស
- គ្រប់គ្រង និងរៀបចំបញ្ជីចំណូល និងចំណាយ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌ
- រៀបចំឯកសារលទ្ធកម្ម និងផ្គត់ផ្គង់សម្ភារៈការិយាល័យ និងបរិក្ខាចាំបាច់សម្រាប់ដំណើរការការងារក្នុង អ.ទ.ស
- រៀបចំ និងដោះស្រាយប្រាក់បេសកកម្មសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី អ.ទ.ស
- ទទួលខុសត្រូវចំពោះមុខប្រធាននាយកដ្ឋានលើរាល់បែបបទប្រើប្រាស់ថវិកា
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**គ- ការិយាល័យផែនការ និងសហប្រតិបត្តិការ** មានភារកិច្ច :

- សិក្សា និងប្រមូលចងក្រងឯកសារគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធ
- ប្រមូល និងចងក្រងគម្រោងអភិវឌ្ឍន៍នានាដែលបានបញ្ចប់ និងកំពុងដំណើការ ព្រមទាំងគម្រោងជាប់កិច្ចសន្យា ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាព រយៈពេលខ្លី មធ្យម និងវែង សម្រាប់បម្រើដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ប្រកបដោយនិរន្តរភាព
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព និងប្រសិទ្ធភាពនៃការអនុវត្តគម្រោងផែនការសកម្មភាពគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សម្របសម្រួល និងជម្រុញកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ឃ- ការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល** មានភារកិច្ច :

- គ្រប់គ្រងឯកសារ ក្របខ័ណ្ឌ និងរៀបចំប្រវត្តិរូបរបស់មន្ត្រីរាជការ
- រៀបចំឯកសារចាត់តាំង និងតែងតាំងមន្ត្រីរាជការក្នុង អ.ទ.ស
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាព និងសមត្ថភាពការងាររបស់មន្ត្រីរាជការ
- រៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់អភិវឌ្ឍន៍ធនធានមនុស្សក្នុង អ.ទ.ស
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ប្រការ ៣.-**

នាយកដ្ឋានធនធានធម្មជាតិ មានរចនាសម្ព័ន្ធដូចខាងក្រោម :

ក-ការិយាល័យធនធានទឹក

ខ-ការិយាល័យធនធានរ៉ែ

គ-ការិយាល័យជីវចម្រុះ

ឃ-ការិយាល័យកសិកម្មចម្រុះ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ក- ការិយាល័យធនធានទឹក** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីសក្តានុពលធនធានទឹកក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ ព្រមទាំងកត្តាផ្សេងៗទៀត ដែលនាំឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សា និងកំណត់តំបន់អភិរក្ស និងអភិវឌ្ឍធនធានទឹក
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ធនធានទឹក ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និង អនុសាសន៍ផ្សេងៗ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានទឹក
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**ខ- ការិយាល័យធនធានរ៉ែ** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីសក្តានុពលធនធានរ៉ែក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានរ៉ែ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពរុករករ៉ែគ្រប់ប្រភេទ ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និង អនុសាសន៍ផ្សេងៗ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**គ- ការិយាល័យជីវចម្រុះ** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីធនធានមច្ឆជាតិ ធនធានព្រៃលិចទឹក និងធនធានជីវចម្រុះផ្សេងៗទៀត ដើម្បីបង្កើតឡើងនូវផែនការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ ប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាព
- សិក្សាស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ ដែលធ្វើឱ្យប៉ះពាល់ដល់ជីវចម្រុះ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រែប្រួលធនធានមច្ឆជាតិ និងព្រៃលិចទឹក ដែលបណ្តាលមកពីកត្តាធម្មជាតិ និងកត្តាមនុស្ស ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និងអនុសាសន៍ផ្សេងៗ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងជីវចម្រុះ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**ឃ- ការិយាល័យកសិកម្មចម្រុះ** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីសក្តានុពលទឹក-ដី សម្រាប់បម្រើឱ្យវិស័យកសិកម្ម
- ប្រមូល និងរៀបចំព័ត៌មានស្តីពីការប្រើប្រាស់ដី
- កំណត់តំបន់អភិវឌ្ឍវិស័យកសិកម្ម
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ទឹក-ដី កសិកម្ម ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និងអនុសាសន៍ផ្សេងៗ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងកសិកម្មចម្រុះ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ប្រការ ៤.-**

នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស មានរចនាសម្ព័ន្ធ ដូចខាងក្រោម :

ក-ការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ

ខ-ការិយាល័យអភិរក្ស

គ-ការិយាល័យព័ត៌មានភូមិសាស្ត្រ និងផែនទី

ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ក- ការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ** មានភារកិច្ច :

- សិក្សា ប្រមូល ចងក្រងព័ត៌មានពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម លើរាល់ធនធានធម្មជាតិក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការធ្វើអាជីវកម្មធនធានទឹក ដី មច្ឆជាតិ រ៉ែ និងជីវចម្រុះផ្សេងៗទៀត ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និងអនុសាសន៍ផ្សេងៗ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ខ- ការិយាល័យអភិរក្ស** មានភារកិច្ច :

- ប្រមូល រៀបចំ និងចងក្រងទិន្នន័យជាប្រចាំ នូវព័ត៌មានពាក់ព័ន្ធនឹងតំបន់អភិរក្ស និងតំបន់ការពារក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- កំណត់តំបន់អភិរក្សធនធានទឹក ព្រៃលិចទឹក មច្ឆជាតិ រ៉ែ និងធនធានជីវចម្រុះផ្សេងៗទៀត
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**គ- ការិយាល័យព័ត៌មានភូមិសាស្ត្រ និងផែនទី** មានភារកិច្ច ៖

- ប្រមូល រៀបចំ និងចងក្រងទិន្នន័យជាប្រចាំ នូវព័ត៌មានភូមិសាស្ត្រ ដើម្បីបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំផែនទីសម្រាប់បម្រើដល់ការងារសម្របសម្រួលការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**ប្រការ ៥.-**

នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ មានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

ក-ការិយាល័យនីតិកម្ម

ខ-ការិយាល័យសម្របសម្រួលវិវាទ

គ-ការិយាល័យផ្សព្វផ្សាយព័ត៌មាន

ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ក-ការិយាល័យនីតិកម្ម** មានភារកិច្ច ៖

- ប្រមូលចងក្រង ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
- សិក្សា និងរៀបចំលិខិតបទដ្ឋានគតិយុត្តិចាំបាច់សម្រាប់ដំណើរការការងាររបស់ អ.ទ.ស
- ចូលរួមផ្តល់មតិយោបល់លើការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
- រៀបចំពិធីសារ អនុស្សរណៈ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិនានា
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**ខ-ការិយាល័យសម្របសម្រួលវិវាទ** មានភារកិច្ច ៖

- ប្រមូលនិងចងក្រង គម្រោងអភិវឌ្ឍន៍នានាដែលបានបញ្ចប់ និងកំពុងដំណើការ ព្រមទាំងគម្រោងចប់កិច្ចសន្យាក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ទទួលពាក្យបណ្តឹង និងសម្របសម្រួលនូវរាល់វិវាទដែលកើតមានឡើងក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**គ-ការិយាល័យផ្សព្វផ្សាយព័ត៌មាន** មានភារកិច្ច :

- ប្រមូលចងក្រង និងរៀបចំព័ត៌មាន ទិន្នន័យ ដែលពាក់ព័ន្ធដល់កិច្ចការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ផ្សព្វផ្សាយព័ត៌មានបម្រើដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល ពាក់ពន្ធ័នឹងការគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ប្រការ ៦.**

គ្រប់ការិយាល័យចំណុះនាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ត្រូវអនុវត្តន៍ការងារតាមភារកិច្ច ដែលបានកំណត់ និងតាមឋានានុក្រម ស្របតាមគោលការណ៍រដ្ឋបាលសាធារណៈ ។

**ប្រការ ៧.**

អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ថ្នាក់ដឹកនាំប្រធាននាយកដ្ឋាន និងការិយាល័យនៃអាជ្ញាធរទន្លេសាប ត្រូវអនុវត្តន៍ប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រធានអាជ្ញាធរទន្លេសាប**

**លឹម គានហោ**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័ន ជាសមាជិករបស់ អ.ទ.ស
- គ្រប់សាលារាជធានី -ខេត្ត ក្នុងតំបន់ទន្លេសាប
  " ដើម្បីជូនជ្រាប "
- ដូចក្នុងប្រការ ៧ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ ៥ ៖ អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ស្តីពីការកំណត់ដែនព្រៃលិចទឹក ចំនួន ៦៤៧.៤០៦ ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៩៧ អនក្រ.បក

អាជ្ញាធរទន្លេសាប
ចូល ថ្ងៃទី 02 ខែ កញ្ញា ឆ្នាំ 2011
ម៉ោង 04:30 នាទី
លេខ 133 អ.ទ.ស/រដ្ឋ

# អនុក្រឹត្យ

ស្តីពី

ការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧.៤០៦ ហិកតា ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប
( ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ )

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងតំបន់ជីវមណ្ឌលបឹងទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពី ការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១០ ស្តីពី ការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពី ការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានកំណត់ដែនព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ ដែលមានផ្ទៃសរុបចំនួន ៦៤៧.៤០៦ ហិកតា រួមមាន ៨០២ ចំណុច ដូចមានក្នុងឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យនេះ ។

**មាត្រា ២ :** ផែនទីបង្ហាញទីតាំងដែនព្រៃលិចទឹក (ដោយមានភ្ជាប់ជូនទាំងនិយាមកា) ក្នុងខេត្តទាំងប្រាំមួយខាងលើជាឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣ :** អំពីភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវ លើការគ្រប់គ្រង ការការពារ និងការថែរក្សាដែនព្រៃលិចទឹក និងព្រៃលិចទឹក :

- អភិបាល នៃគណៈអភិបាលខេត្តទាំងប្រាំមួយជុំវិញបឹងទន្លេសាប រួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ មានភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវលើការគ្រប់គ្រង ការការពារ និងការថែរក្សាដែនព្រៃលិចទឹក និងព្រៃលិចទឹក ដូចខាងក្រោម :
  - ១- មានភារកិច្ចគ្រប់គ្រងដោយផ្ទាល់ លើដែនព្រៃលិចទឹកដែលមាននៅក្នុងខេត្តនីមួយៗ
  - ២- មានកាតព្វកិច្ចការពារឱ្យខាងតែបានទូវដែនព្រៃលិចទឹក និងព្រៃលិចទឹកដែលមាននៅក្នុងខេត្តនីមួយៗ
  - ៣- ការបាត់បង់ដែនព្រៃលិចទឹក និងព្រៃលិចទឹក ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចនៃខេត្តណា គណៈអភិបាលនៃខេត្តនោះ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខរាជរដ្ឋាភិបាល ។
- រដ្ឋបាលជលផល ត្រូវធ្វើការត្រួតពិនិត្យជាប្រចាំលើសកម្មភាពថែរក្សា ការពារដែនព្រៃលិចទឹក និងព្រៃលិចទឹករបស់អាជ្ញាធរខេត្តទាំង ០៦ ខាងលើ និងត្រូវចាត់វិធានការតាមច្បាប់ជាបន្ទាន់ ក្នុងករណីពិនិត្យឃើញថា មានសកម្មភាពដែលនាំឱ្យប៉ះពាល់ដល់ដែនព្រៃលិចទឹក និងព្រៃលិចទឹក ។
- អាជ្ញាធរទន្លេសាបមានភារកិច្ចធ្វើអធិការកិច្ចលើគ្រប់សកម្មភាពពាក់ព័ន្ធនឹងដែនព្រៃលិចទឹក និងព្រៃលិចទឹក និងត្រូវធ្វើសេចក្តីរាយការណ៍ពីសកម្មភាពទាំងនោះ ជូននាយករដ្ឋមន្ត្រី ដើម្បីមានវិធានការសម្រេច ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានអាជ្ញាធរទន្លេសាប រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ